ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 04-Jul-2017, 14:04
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពិរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៨នាទី**

**សវនាការលើកទី២៥៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រមនិលណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ម៉ាដាលេណា ហ្គេហ្សុី
*(Ms. Maddalena Ghezzi)*

លោកស្រី សែ កុលវុឌ្ឍី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក សេង លាង

លោក ស្រ៊ា រតនៈ

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទនួន ជា៖**

លោក សុនអរុណ

លោក សួន វិសាល

លោក វិចទ័រកូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន *(Mr. Arthur VERCKEN)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក វ៉ែន ពៅ

លោកស្រី ទី ស្រីនណា

លោក ហុង គឹមសួន

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន(ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោក ឡោ ជុនធី | ខ្មែរ |
| លោក នុត នូវ (2-TCW-948) | ខ្មែរ |
| លោក វៀល សន (2-TCW-860) | ខ្មែរ |

# ខ្លឹមសារ

## ការសួរសំណួរទៅសាក្សី៖ លោកនុត នួន (2-TCW-948)

សួរបន្តដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្ដើមពី .................................................ទំព័រ ៣

សួរដោយលោក ឡោ ជុនធី ផ្ដើមពី.........................................................................ទំព័រ ១៨

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ...............................................................ទំព័រ ២២

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី.........................................................................ទំព័រ ២៥

សួរដោយលោក គង់ សំអុន ផ្ដើមពី .........................................................................ទំព័រ ៤៥

សួរដោយលោក អាកទួរ វែកគែន ផ្ដើមពី ..................................................................ទំព័រ ៦០

## ការសួរសំណួរទៅសាក្សី៖ លោករឿល សន (2-TCW-860)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី .............................................................................ទំព័រ ៧០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៨:២៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី នុត នូវ។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះ គឺលោក នុត នូវ លោកនិងមេធាវីប្រឹក្សាលោក ឌុច ផារី មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ នៅថ្ងៃនេះមានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-860។សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីនឹងធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែកនៅវេលាម៉ោងដប់ព្រឹកនេះ ហើយសាក្សីបម្រុងរូបនេះមានមេធាវីប្រឹក្សាលោក ឌុច ផារីផងដែរ។ សូមអរគុណលោកប្រធាន។

[០៩:១០:១៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយមុននឹងផ្តល់វេទិកាជូនទៅភាគី អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

ដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥។ ដោយគាត់អះអាងថាមេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំព្យាបាលសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥។ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈឈឺចង្កេះជាប្រចាំ និងអាចឈឺកាន់តែខ្លាំងពេលអង្គុយយូរ និងបានផ្ដល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

[០៩:១១:៤១]

ផ្អែកលើមូលៗដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រមនិងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

ហើយបង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះអាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតៗនៅក្រោមសាលសវនាការនេះ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី រួមនឹងមេធាវី --សហាៗព្រះរាជអាជ្ញា រួមនឹងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានរយៈពេលមួយវគ្គនៃសវនាការព្រឹកនេះ គឺពេលនេះទៅរហូតដល់ម៉ោងឈប់សម្រាក។ សូមអញ្ជើញ!

[០៩:១២:៥១]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម! ជម្រាបសួរភាគីទាំងអស់! ជម្រាបសួរលោកសាក្សី!

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំនឹងបន្តសំណួររបស់ខ្ញុំតទៅទៀត។ ជាដំបូង ខ្ញុំចង់ទាញចំណាប់ៗអារម្មណ៍របស់លោក ពាក់ព័ន្ធទៅនឹងចម្លើយខ្លែងគ្នារបស់លោក កាលពីថ្ងៃព្រហស្បតិ៍ សប្តាហ៍កន្លងទៅ គឺម៉ោង<> ដប់ប្រាំម្ភៃប្រាំមួយ ទៅដល់ម៉ោងដប់ប្រាំម្ភៃប្រាំពីរ <នៅក្នុងចម្លើយ>ពេល<>គេសួរថា៖ "តើលោកជាបក្ខជននៃបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ នៅពេលដែលលោក<ធ្វើ>ជាមេឃុំស្រែរនោងនោះ?" លោកបានឆ្លើយថា៖ "ខ្ញុំ<>ជាបក្ខជនត្រៀម មិនទាន់<ក្លាយ>ជាបក្ខជនពេញសិទ្ធិទេ"។ ហើយនៅក្នុងកំណត់ហេតុរបស់លោកគឺ E319.1.17 នៅសំណួរ-ចម្លើយទី២៦ គេសួរថា៖ "<ស៖>តើលោកមានទំនាក់ទំនងជាមួយបក្ស<កុម្មុយនីស្តកម្ពុជា>ទេ? <ឆ៖> ខ្ញុំជាមេឃុំ អ៊ីចឹងខ្ញុំជាសមាជិកបក្ស។" សូមបញ្ចប់ការដកស្រង់។

ដូច្នេះ តើត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថា លោកពិតជាបក្ខជននៃបក្សកុម្មុយនីស្តកម្ពុជា នៅពេលដែលលោកធ្វើជាមេឃុំនោះ?

[០៩:១៤:១៣]

**លោក នុត នូវ៖**

**ឆ៖** បាទអរគុណ។ ជាបឋមខ្ញុំសូមគោរពលោកប្រធានចៅក្រមជាទីគោរព និងសូមគោរពអស់លោក លោកស្រី ក្នុងសវនាការទាំងមូលជាទីគោរពរាប់អាន។ ចម្លើយដែលខ្ញុំឆ្លើយនេះ គឺពិតប្រាកដណាស់។ ខ្ញុំកាលនោះ ជាគណ:ឃុំស្រែរនោងមែន ប៉ុន្តែជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាត្រៀមបម្រុង។ សូមអរគុណ ពិតប្រាកដ។

**ស៖** នៅក្នុងកំណត់ហេតុរបស់លោកគឺ E3/5521 នៅចម្លើយទី៦៨ គេសួរថា៖ "<ស៖> តើអ្នកណាជាអ្នកចាត់តាំងលោកឲ្យធ្វើគណ:ឃុំស្រែរនោង? <ឆ៖> តាជឹម តាសាន <និងតាកិត> ជាអ្នកចាត់តាំងខ្ញុំ។" តើលោកអាចបញ្ជាក់បានទេថា ក្នុងចំណោមអ្នកទាំងបីហ្នឹង តាជឹម <តាកិត> ឬក៏

តាសានហ្នឹង <នរណា>ជាគណៈស្រុក<ខណៈ>ពេលដែល<>លោក<ធ្វើ>ជាមេឃុំស្រែរនោងហ្នឹង?

**ឆ៖** បាទ អរគុណណាស់។ គណៈ -- ឈ្មោះទាំងបីហ្នឹងគឺ លោក<តាកិត>ជាប្រធានស្រុក, លោកតាសាន ជាសមាជិកនៅក្នុងស្រុកត្រាំកក់។ គាត់បានចាត់តាំងខ្ញុំឲ្យក្តាប់នៅឃុំស្រែរនោងជំនួសលោកតាឃុន។ បាទ សូមអរគុណ។

[០៩:១៦:២១]

**ស៖** តើតាសាន មានត្រូវបានតែងតាំងជាមេស្រុកទេនៅពេលណាមួយនោះ នៅពេលដែលលោកជាមេឃុំនោះ?

**ឆ៖** តាសាន កាលណោះគាត់ជាសមាជិកមិនទាន់ឡើងជាមេស្រុកទេ សុំជម្រាបសវនាការជាទីគោរពជ្រាប។

**ស៖** លោកនិយាយអំពីតាឃុន កាលពី<ថ្ងៃព្រហស្បតិ៍>សប្តាហ៍មុន គឺនៅម៉ោងដប់បួន ម្ភៃប្រាំបីនាទី លោក<និយាយ>ថា "នៅពេលដែលខ្ញុំទៅឃុំស្រែរនោងនោះ គឺមេឃុំចាស់ហ្នឹងគាត់បានធ្វើការបោសសម្អាតរួចទៅហើយ។ ដូច្នេះ នៅពេលដែលខ្ញុំទៅដល់នោះគឺអត់មានធ្វើការចាប់ខ្លួន<នរណាគេ>ទេ។ ពេលនោះគឺនៅឆ្នាំ១៩៧៨"។

<តើ>លោកអាចប្រាប់បានទេហេតុអីបានជា<អង្គការបានសម្រេចដក>តាឃុន<>ចេញពីព្រោះថា គាត់បានធ្វើការបោសសម្អាត<នៅក្នុងឃុំស្រែរនោងនោះ>ស្អាតរួចទៅហើយ<>?

**ឆ៖** បាទ អរគុណចម្លើយនេះ តាមខ្ញុំដឹង ហើយខ្ញុំបានឮ ដោយលោកតាសាន ហៅខ្ញុំទៅជួបប្រាប់ថា តាឃុនហ្នឹងគឺប្រើអំពើឃោរឃៅនៅក្នុងឃុំស្រែរនោង គឺមិនស្តាប់ថ្នាក់លើ។ អ៊ីចឹងបានគេដកគាត់ឲ្យទៅអង្គរបូរីឲ្យធ្វើស្រែប្រាំង ហើយគាត់ឲ្យខ្ញុំទៅជំនួសឆ្នាំ១៩៧៨ ប្រហែលជាខែ៣ ខ្ញុំមិនបានចាំប្រាកដទេ ប៉ុន្តែទៅជំនួសនៅក្នុងឃុំស្រែរនោង។ បាទ សូមអរគុណ។

[០៩:១៨:៣៥]

**ស៖** <នៅក្រោមសម្បថនៅឡើយ> លោកនិយាយថា <មិន>មានការចាប់ខ្លួនខ្លាំងទេនៅពេលដែលលោកធ្វើជាមេឃុំស្រែរនោងនោះ<។> ហើយ<ក្នុងសវនាការថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥ នៅម៉ោង១៤:១៥នាទី>លោកនិយាយថា សេចក្តីសម្រេចឲ្យចាប់ និងកម្ទេច<>គឺធ្វើឡើងដោយថ្នាក់លើ<។> លោកនិយាយ<ថា>អំពីថ្នាក់តំបន់ <ឬ>ថ្នាក់ភូមិភាគ <ជាអ្នក>មានសិទ្ធិសម្រេចឲ្យមានការចាប់ខ្លួន និងការកម្ទេច<>។ ដូច្នេះ ខ្ញុំអាចនិយាយបានទេថា ការចាប់ ហើយនិងការកម្ទេចនោះ គឺមិន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ស្ថិតនៅលើ<ថ្នាក់ឃុំ ឬ>មេឃុំទេ <ផ្ទុយទៅវិញវា>គឺ<ជាការ>សម្រេច<>មកពីថ្នាក់លើ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ សូមអរគុណ ការណ៍នេះគឺពិតណាស់ គឺខាងឃុំគ្មានតួនាទីសម្រេចទេ មានតែតំបន់ ឬក៏ភូមិភាគមាននាទីសម្រេច ចាប់ចងអ្នកដែលត្រូវយកទៅសម្លាប់។ បាទ សូមអរគុណ។

**ស៖** តើ<ក្នុងឆ្នាំ១៩៧៨មាន>អ្នក<>មកពីថ្នាក់លើ<ដូចជាមកពីថ្នាក់ស្រុក មកពីថ្នាក់តំបន់ ឬមកពីថ្នាក់ភូមិភាគ>ចុះ<មក>ចាប់ខ្លួន <ឬ>កម្ទេច<មនុស្សដែរឬ>ទេ<>?

[០៩:២០:០៩]

**ឆ៖** ស្រុកអ្នកតំបន់ អ្នកភូមិ -- អ្នកស្រុក អ្នកតំបន់ អ្នកភូមិភាគ កាលនោះមិនចុះផ្ទាល់ទេ មានសន្តិសុខបានយកមកផ្ទាល់។ បាទ សូមអរគុណ។

**ស៖** ដូច្នេះ <តើលោកចង់មានន័យថាម៉េច>លោកនិយាយថាលោកខ្លួនឯងផ្ទាល់ហ្នឹងមិនបានចាប់ខ្លួនមនុស្សទេ គឺថ្នាក់លើជាអ្នកចុះមកចាប់<ដោយខ្លួនឯងនៅក្នុង>ឃុំស្រែរនោងហ្នឹង<>?

**ឆ៖** នៅក្នុងៗឃុំស្រែរនោងនេះ ក្រោយពីខ្ញុំចូលទៅគឺគ្មានការចាប់ខ្លួនទេ មានតែគេដាក់បញ្ជាឲ្យខ្ញុំដឹកនាំធ្វើស្រូវដើម្បីដោះស្រាយជីវភាពប្រជាជនឲ្យបាន៣តោនក្នុង១ហិកតា។ អ៊ីចឹងខ្ញុំគិតតែមមាញឹកខាងចុះប្រឡូកជាមួយប្រជាជននៅក្នុងការដ្ឋាន។បាទ អត់មានការចាប់ចងទេកាលជំនាន់ខ្ញុំទៅសូមជម្រាបដោយស្មោះត្រង់។ សូមអរគុណ។

**ស៖** <ប្រសើរណាស់ កាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុន នៅមុនម៉ោង១៥:១៣នាទី>លោកបាននិយាយថាបាន<>ឮឈ្មោះតាអាន់ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ<>។ អ៊ីចឹងខ្ញុំចង់ដឹងថាតើតាអាន់ ហ្នឹងមានធ្លាប់ផ្ញើសារទៅឲ្យឃុំស្រែរនោងទេ នៅឆ្នាំ១៩៧៨?

**ឆ៖** បាទពិតណាស់ ខ្ញុំធ្លាប់ឮឈ្មោះតាអាន់ នៅក្នុង ហៅថាសន្តិសុខក្រាំងតាចាន់ ឮ ប៉ុន្តែមិនដែលមានផ្ញើសារអីមកឲ្យខ្ញុំទេ គ្រាន់តែឮ ប៉ុន្តែមិនបានស្គាល់ដិតដល់ទេ ក្នុងនាមគណៈឃុំ មិនអាចទៅក្បែរកន្លែងសន្តិសុខក្រាំងតាចាន់ទេ គ្រាន់តែបានដឹងថាទីនោះជាកន្លែងសន្តិសុខ។ បាទ សូមអរគុណ។

[០៩:២២:៣៦]

**ស៖** <ត្រង់ចំណុចនេះ> ខ្ញុំចង់លើកឡើងនូវឯកសារមួយ គឺឯកសារ E319/12.3.2 គឺឯកសារហ្នឹងគេប្រគល់ជូនលោក<មើល>កាលពីថ្ងៃព្រហស្បតិ៍រួចហើយ <ហើយ>លោក<ក៏បានបង្ហាញកម្មាភិបាលម្នាក់ដែលត្រូវគេសួរចម្លើយ តែលោកមិនត្រូវបានអនុញ្ញាតឲ្យនិយាយឈ្មោះគាត់ឡើយ។

លោកបញ្ជាក់ថាបុគ្គលនោះគឺ>ជាមេឃុំ<ម្នាក់>នៅស្រុកត្រាំកក់។ ខ្ញុំនឹងអាន<សម្រង់>ជាភាសាអង់គ្លេស គឺនៅសំណួរ២០២ និង២១០។ <ខ្ញុំនឹងចាប់ផ្តើមផ្តល់ជាបរិបទ។>មេឃុំនេះគាត់បាននិយាយពាក់ព័ន្ធនឹងសំបុត្រដែលផ្ញើដោយតាអាន់ពីមន្ទីរសន្តិ<>សុខក្រាំងតាចាន់។ ខ្ញុំសូម<អានសម្រង់>ជាភាសារអង់គ្លេស<ដូចតទៅ៖>

[០៩:២៣:២៧]

<“ស.២០២៖> នៅពេលដែលលោកបានទទួលលិខិតបែបនេះ តើលោកធ្វើការ<ចាត់ចែង> បែបណាដែរ? <ឆ>៖ ខ្ញុំ<បាន>បញ្ជូនមនុស្សទៅអាន់ ហើយអាន់ជាអ្នកអនុវត្តបន្ត។ បន្ទាប់ពីបានទទួលលិខិត ខ្ញុំឱ្យគេស្រាវជ្រាវទៅរកឈ្មោះ<មនុស្សនៅក្នុងលិខិត>ហ្នឹងនៅក្នុងភូមិ<>។ បន្ទាប់មកប្រសិនបើភូមិរកឃើញឈ្មោះហ្នឹង ខ្ញុំបញ្ជូនពួកគេទៅមន្ទីរស្រុក។ ខ្ញុំមិនដឹងថាតើខាងស្រុកគេធ្វើយ៉ាងដូចម្តេចទេ។ <ឆ.២១០>៖ យើងអាចនិយាយបានថាគេបញ្ជូនមនុស្សហ្នឹងទៅគុកដោយផ្ទាល់<តែម្តងហើយទើប>រាយការណ៍ទៅ<>ស្រុក ឬ<>ក៏ប្រហែលជាបញ្ជូនទៅស្រុក<ជាមុនសិន ព្រោះ>ខ្ញុំមិនច្បាស់អំពីបញ្ហានេះទេ។” សូមបញ្ចប់ការដកស្រង់។

[០៩:២៤:២២]

ដូច្នេះ យើងមានមេឃុំ<ម្នាក់>បញ្ជាក់ថាគាត់ទទួលបានសំបុត្រពីតាអាន់ បន្ទាប់មកមានការ<ចាត់ចែង>ចាប់ខ្លួន<មនុស្សនោះ>ហើយបញ្ជូន<>ទៅមន្ទីរស្រុក ឬទៅ<គុក>របស់ តាអាន់។ <> តើការអានរបស់ខ្ញុំហ្នឹងធ្វើឱ្យលោកចងចាំទេ<ថាឃុំ>ទទួល<សារ>មកពីមន្ទីរសន្តិសុខ<ស្រុកឈ្មោះ>ក្រាំងតាចាន់<ដែរឬទេ>?

**ឆ៖** បាទ អរគុណណាស់។ ក្នុងបញ្ហានេះខ្ញុំមិនបានដឹងថាឃុំរបស់គេផ្សេងនោះមានសារលិខិតបញ្ជូនមក ឬយ៉ាងម៉េចទេ។ ចំពោះខ្ញុំអត់បានដឹងទេ សូមជ្រាប។

**ស៖** ពាក់ព័ន្ធនឹងការបង្កបង្កើនផលស្រូវកាលពី<សវនាការថ្ងៃ>ព្រហស្បតិ៍សប្តាហ៍មុន គឺនៅម៉ោង <១៤:១៦:៣២>វិនាទីលោកនិយាយថា<>ប្រសិនបើមេដឹកនាំ<ណា>មិនអាច<សម្រេចបាន> ទិន្នផលស្រូវ៣តោន ក្នុង១ហិកតាបានទេ គេដកមេដឹកនាំហ្នឹងចេញ<យកទៅកន្លែងផ្សេង ឬក៏ដកគាត់ចេញពីមន្ទីរគាត់>”។ លោកក៏នៅឆ្លើយនៅចម្លើយ៨០ នៃកំណត់ហេតុ<នៃការស្តាប់ចម្លើយសាក្សី> របស់លោកគឺ E3/5521 ថា<>លោកអាចលាក់ទិន្នផលស្រូវពាក់កណ្តាល ប្រសិនបើទិន្នផលស្រូវនោះល្អ ហើយទុកក្នុងជម្រុកសម្រាប់បែងចែកទៅឱ្យប្រជាជននៅពេលខ្វះខាត<ស្បៀង។ បើសិនជាតាមការ

គណនារបស់ខ្ញុំត្រឹមត្រូវនោះ> អ៊ីចឹងមានន័យថា លោកអាចសម្រេចបានដល់ទៅ៦តោន ក្នុង១ហិកតា <នៅក្នុងឃុំរបស់លោក>មែនទេ? ព្រោះថាលោកបែងចែក៣តោនទៅបក្ស<ដើម្បីកុំឱ្យគេដកលោក> ហើយលោកដកទុកខ្លួនឯងហ្នឹងលាក់ទុកក្នុងជម្រុក៣តោនសម្រាប់ចែកឱ្យប្រជាជនខ្វះខាត។ មានន័យថាអ៊ីចឹងមែនទេ<>?

[០៩:២៦:៣៥]

**ឆ៖** បាទ អរគុណណាស់សំណួរនេះ។ ធ្វើស្រែមិនបានទេ៦តោន បើ៣តោន ពីរតោនកន្លះហ្នឹងអាចបាន។ ប៉ុន្តែការលាក់ទុក អានេះជាបច្ចេកទេសរបស់ខ្ញុំផ្ទាល់ទេ ដោយយល់ប្រជាជននៅក្នុងឃុំមានការខ្វះខាត។ អ៊ីចឹងបើកាលណាយើងរាយការណ៍ទាំងអស់ យើងមិនអាចដោះស្រាយជីវភាពប្រជាពលរដ្ឋនៅក្នុងឃុំបាន ប្រជាជននៅក្នុងឃុំបាន។ អាហ្នឹងវាមានបញ្ហាដល់រូបខ្ញុំ។អ៊ីចឹងជាបច្ចេកទេសជាមួយអ្នកកាន់ឃ្លាំង។ អ៊ីចឹងស្រូវយើងទុកជារួម របាយការណ៍ ឧទាហរណ៍ថាយើងបានក្នុងឆ្នាំហ្នឹង ១.០០០តោនអ៊ីចឹងចុះ ឧទាហរណ៍ក្នុងមួយសហករណ៍ មួយឃុំហ្នឹង យើងរាយការណ៍ថា បានតែ៧០០ ទេយើងទុកមួយភាគសម្រាប់ដោះស្រាយជីវភាពប្រជាជនពេលដែលខ្វះខាត។ នេះជាបច្ចេកទេសដើម្បីលាក់ជួយប្រជាជននៅក្នុងឃុំ។ សូមអរគុណ។

**ស៖** លោកបាននិយាយថា នៅពេលដែលលោកនៅឃុំហ្នឹង គឺ<ពុំ>មាន<>ចាប់ខ្លួន<មនុស្សណាម្នាក់>ទេ ហើយលោកបានផ្តល់ស្បៀងអាហារឱ្យប្រជាជន ហើយប្រជាជនហ្នឹងមិនរាយការណ៍ទេ នៅពេលដែលលោកលាក់ស្រូវនោះ។ នៅក្នុង<សំណួរ>ចម្លើយទី៨៤របស់លោក គឺឯកសារលេខ E3/5521 លោកនិយាយថា <>ប្រជាជនហ្នឹងគឺចូលចិត្តនិងស្រឡាញ់លោកណាស់។ នៅក្នុង<សំណួរ>ចម្លើយទី៧៦ លោកបាន<និយាយ>ថា លោកបាន<យក>អង្ករ<ឱ្យប្រជាជននៅក្នុងឃុំរបស់លោក>ម្នាក់មួយកំប៉ុង សម្រាប់<ហូប>មួយពេល <ហើយពួកគេមានសាច់ហូបរៀងរាល់១០ថ្ងៃម្តង>។ ហើយនៅក្នុង<សំណួរ>ចម្លើយ៨១ហ្នឹងលោក បានបញ្ជាក់ថាលោក<យកម្សៅដំឡូងមី>ធ្វើនំប៉ុង<> ហើយចែកឱ្យ<ប្រជាជននៅក្នុង>ឃុំរបស់លោក<រៀងរាល់១០ថ្ងៃម្តងទៀតផង>។ តើអ៊ីចឹងត្រឹមត្រូវ<ដែរឬ>ទេ<>?

[០៩:២៩:០៦]

**ឆ៖** បាទ អរគុណណាស់។ នៅក្នុងឃុំរបស់ខ្ញុំហ្នឹងគឺមានធ្វើឡនំប៉ុងមួយ ឆ្នាំ១៩៧៨ហ្នឹង វាខ្ទង់ខែមិនចាំទេ បើថាពាក់កណ្តាលឆ្នាំ បានបង្កើតជាឡនំប៉ុងនេះ។ នំប៉ុងនេះគឺដំឡូងមី ម្សៅដំឡូងមី ឬដំឡូង

មីយកមកស្ងោរលាបជាមួយពងមាន់ពងទា ដាក់ស្ករឡែមៗសម្រាប់ដោះស្រាយជូនប្រជាជនពេលធ្វើការពេលព្រឹក ម្នាក់យ៉ាងហោចណាស់បានមួយ ហើយជ្រលក់ជាមួយស្ករត្នោត ព្រោះស្ករត្នោតនៅក្នុងឃុំខ្ញុំ វាសម្បូរណាស់។ នេះជាការពិត។

**ស៖** យើងនឹងពិនិត្យផ្ទៀងផ្ទាត់ចំណុចទាំងអស់ហ្នឹងជាមួយនឹងសំណុំឯកសារត្រាំកក់និងសំណុំឯកសារមន្ទីរក្រាំងតាចាន់។ <ជាមថម ហើយសំខាន់បំផុត យើងនឹង>មើលថាតើមានអ្នកឃុំស្រែរនោងត្រូវបានចាប់ខ្លួននិងបញ្ជូនទៅក្រាំងតាចាន់ដែរឬទេ នៅឆ្នាំ១៩៧៨។ ជាដំបូងខ្ញុំចង់ប្រគល់ឯកសារមួយជូនលោកនិងសូមការអនុញ្ញាតពីលោកប្រធានបញ្ចាំងឯកសារនៅលើអេក្រង់កុំព្យូទ័រ គឺឯកសារលេខ E3/4092 –គឺ<>សៀវភៅ<សរសេរមួយក្បាល>មកក្រាំងតាចាន់– ដែលសង្ខេបអំពីចម្លើយសារភាពរបស់អ្នកទោសដែលត្រូវបានចាប់ខ្លួននៅចម្លើយខែមីនា និងខែកក្កដា ឬខែសីហា ឆ្នាំ១៩៧៨។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមលោកប្រធានមេត្តាអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[0៩:៣0:៥៤]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

**ស៖** ជាភាសាខ្មែរ 00271136 ទៅដល់ 37 ខ្ញុំបាន<បិទក្រដាសស្អិត>ពណ៌ខៀវ<នៅលើនោះ>, ជាភាសាអង់គ្លេសគឺ00834796-97,ជាភាសាបារាំងគឺ 00721277។ ក្នុងនេះគេនិយាយអំពី "អ្នកទោសពីរនាក់មកពីឃុំស្រែរនោងឈ្មោះ ជឹម ហុក អាយុ៤៤ឆ្នាំ មកពីភូមិត្រាច និង ទូច លន់ អាយុ៤៦ឆ្នាំ មកពីភូមិត្រពាំងថ្នល់ដែលមានឋានៈជាកាប៉ូរ៉ាល់សែប នៅបន្ទាយក្រុងស្ទឹងភ្នំពេញ <គឺមានន័យថា>អ្នកទាំងពីរ<>មកនៅស្រែរនោងក្រោយថ្ងៃ<រំដោះ>ទី១៧ <ខែមេសា ឆ្នាំ១៩៧៥>។ របាយការណ៍សួរចម្លើយនៅក្រាំងតាចាន់ បញ្ជាក់ថា <>អាពីរនាក់<>នេះ បានព្យាយាមរត់ទៅវៀតណាមជាមួយអ្នកផ្សេងទៀត ហើយត្រូវបានចាប់ខ្លួននៅតំបន់៣៥ ហើយបន្ទាប់មកបញ្ជូនទៅស្រុក១០៥វិញ។ ពួកវាបាននិយាយថា ពួកវាមិនអាចរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ពីព្រោះថារបបមុន ពួកវា<មាន>ប្រាក់ខែ ហើយអាចទៅផ្សារបាន ហើយស៊ីអីក៏បានតាមចង់នៅពេលដែលឃ្លាន"។

លោកសាក្សី លោកចាំឈ្មោះអ្នកទាំងពីរហ្នឹងទេគឺ ជឹម ហុក និង ទូច លន់ ដែលព្យាយាមរត់

ចេញឃុំស្រែរនោង ដែលនៅពេលនុ៎ង លោកជាមេឃុំ ហើយបន្ទាប់មកគេចាប់ខ្លួន ហើយបញ្ជូនទៅមន្ទីរក្រាំងតាចាន់?

**ឆ៖** បាទសូមពិភាក្សាជាមួយមេធាវី។ រឿងនេះ វាមុន--

*(សាក្សីពិភាក្សាជាមួយមេធាវីប្រឹក្សា)*

[០៩:៣៤:០៩]

**ប្រធានអង្គជំនុំ៖**

បាទអញ្ជើញសាក្សីឆ្លើយតបនឹងសំណួរ។

**លោក នុត នួវ៖**

**ឆ៖** បាទសូមអរគុណ ហើយសូមជម្រាបលោកប្រធានជ្រាបផងដែរ ចំពោះឈ្មោះពាក់ព័ន្ធទាំងប៉ុន្មាននេះ មុនខ្ញុំចូលទៅដល់ស្រែរនោង គឺមានសភាពមានអ្នករត់មានខ្ញុំបានដឹង ប៉ុន្តែឈ្មោះ ជឹម ហុន, ទូច លន់ នេះ ខ្ញុំមិនបានដឹងទេ គ្រាន់តែដឹងថាមាន គេចាប់បញ្ជូនមុនខ្ញុំទៅដល់។ បាទសូមអរគុណ ហើយអក្សរនេះ ក៏មិនមែនជាអក្សររបស់ខ្ញុំ ជាអក្សរឈ្លប ឬអក្សរនរណា ក៏ខ្ញុំមិនអាចស្គាល់បានណា សូមជ្រាបដោយពិតប្រាកដ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

**ស៖** សៀវភៅហ្នឹងគឺចេញមកពីមន្ទីរសន្តិសុខក្រាំងតាចាន់។ អ៊ីចឹង<>វាត្រឹមត្រូវហើយដែលលោកមិនស្គាល់អក្សរនោះ។ ឯកសារមួយទៀត ដែលខ្ញុំចង់ -- សូមទោស គឺខ្ញុំនៅតែនិយាយពីឯកសារហ្នឹងដដែលទេ គឺតែនៅទំព័រផ្សេងទៀត <ជាភាសាខ្មែរ>គឺនៅទំព័រ 00271141, ជាភាសាអង់គ្លេស 00834801, ជាភាសាបារាំងគឺ00721283។ នេះជារបាយការណ៍មកពីក្រាំងតាចាន់ ពាក់ព័ន្ធនឹងអ្នកទោសឈ្មោះ វ៉ាត់ ថន អាយុ៤២ឆ្នាំ ជាលេខានៅក្នុងធនាគារពាណិជ្ជនៅភ្នំពេញ ក្រោយថ្ងៃទី១៧ មេសា គាត់ទៅរស់នៅស្រុកគីរីវង់ បន្ទាប់មកអង្គការបញ្ជូនគាត់ទៅឃុំស្រែរនោង ហើយគាត់ត្រូវគេចាប់ខ្លួននៅទីនោះ។ ខ្ញុំសូមដកស្រង់របាយការណ៍នេះ គឺមកពីក្រាំងតាចាន់ "អានេះវាបន្ទុះបង្អាប់ មើលងាយយើង វាថានំបុ័ងឥឡូវធ្វើមិនដូចនំបុ័ងពីមុនទេ បើទុកនំដំឡូងឲ្យគេស្ងោរស៊ីលេងវិញគ្រាន់បើជាង"។ សូមបញ្ចប់ការដកស្រង់។

[០៩:៣៦:៥៨]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

ហើយខ្ញុំសូមប្រគល់ឯកសារមួយទៀត ដែលនិយាយពីមនុស្សដដែលនេះ គឺឯកសារលេខ E3/4122។

ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះ ពីលោកប្រធាន ដើម្បីបញ្ចាំងឯកសារនេះ នៅលើអេក្រង់ គឺជាភាសាខ្មែរ 00271085។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ជាភាសាបារាំងគឺ 00729669, ជាភាសាអង់គ្លេស 00779252 របាយការណ៍នេះគឺនិយាយអំពីអ្នកទោសដដែលហ្នឹង គឺឈ្មោះ វ៉ាត់ ថន។ នេះជា<សៀវភៅសរសេរ>មកពីក្រាំងតាចាន់ ចុះខែឧសភា ឬមិថុនា ឆ្នាំ១៩៧៦ <>តាម<រយៈ>ខ្លឹមសារ<> របាយការណ៍នេះផ្តល់អំពីព័ត៌មានលម្អិតពាក់ព័ន្ធទៅនឹងអ្នកទោសរូបនេះ ដែលត្រូវបានសួរចម្លើយនៅមន្ទីរក្រាំងតាចាន់។ ខ្ញុំសូមដកស្រង់៖ “អាមួយនេះ វាប្រឆាំងនឹងបដិវត្តន៍ វារិះគន់យើង ដោយវានិយាយថាអង្ករមួយកំប៉ុងចែកគ្នាបួននាក់ គ្មានអ្នកណាអាចហូបឆ្អែតទេ។ ចំពោះដំឡូង គឺគេធ្វើជានំប៉ុង គឺដូចជានំដុត<ខ្លោច>អ៊ីចឹង។ បើសិនជាយកដំឡូងមកស្ងោរស៊ីហ្នឹង វាគ្រាន់បើជាង”។ ដូច្នេះ យើងឃើញហើយថាមើលទៅប្រជាជនឃុំស្រែរនោងហ្នឹង ដូចជាមិនចូលចិត្តនំប៉ុងដែលលោកឲ្យហ្នឹងទេ ហើយ<>ក៏មិនពេញចិត្តរបបអង្ករ របបបាយដែលលោកចែកជូនដែរ។ អ៊ីចឹងលោកអាចជម្រាប<អង្គជំនុំជម្រះ>បានទេ ថាមានអ្នកដែលត្រូវបានគេចាប់ខ្លួន និងបញ្ជូនទៅក្រាំងតាចាន់ បន្ទាប់មកសួរចម្លើយដោយសារតែបានរិះគន់របបអាហារ ហើយដែលបានរិះគន់ថា នំប៉ុងហ្នឹង មើលទៅដូចជានំដុត<ខ្លោច>អីអ៊ីចឹងមានករណីហ្នឹងកើតឡើងទេលោក?

[០៩:៣៩:២២]

**លោក នុត នូវ៖**

**ឆ៖** បាទ នៅក្នុងឯកសារនេះ ខ្ញុំបើនៅក្នុងឃុំតែម្តង មិនដែលប្រជពលរដ្ឋ -- ប្រជាជននៅក្នុងឃុំមានការប្រឆាំងទេ គឺចេះតែហូបទៅ ត្រង់ពេញចិត្ត មិនពេញចិត្តអាហ្នឹងខ្ញុំមិនអាចសន្និដ្ឋានបាន ហើយកន្លែងនេះមួយទៀត ក្រែងនៅការដ្ឋានធ្វើទំនប់នៅទួលគ្រួស ខ្ញុំមិនបានដឹងបាទ គ្រាន់ធ្វើ -- គេរបាយការណ៍នៅខាងទួលគ្រួស។ បាទសូមអរគុណ ព្រោះមានប្រជាជនពីស្រែរនោងទៅធ្វើទំនប់ទួលគ្រួស។ បើខ្ញុំចាំប្រហែលជាអ៊ីចឹង បើក្នុងមូលដ្ឋានគឺអត់មានទេ។ សូមអរគុណ។

**ស៖** អ៊ីចឹង<ការដ្ឋាន>ហ្នឹង<>ស្ថិតនៅក្នុងឃុំស្រែរនោង <>មែនទេ?

**ឆ៖** ការដ្ឋាននៅទួលគ្រោះហ្នឹងមិនមានស្ថិតនៅក្នុងឃុំស្រែរនោងទេ គឺស្ថិតនៅខាងស្រុកអ្នកគ្រប់គ្រង។ ប៉ុន្តែមានប្រជាជនពីឃុំ គ្រប់ឃុំនៅក្នុងស្រុកទៅធ្វើទំនប់ហ្នឹង។ បាទ សូមអរគុណ។

**ស៖** អម្បាញ់មិញនេះ លោកនិយាយអំពីការនិយាយពីរសជាតិ តែអម្បាញ់មិញនេះ ខ្ញុំ<មិនបាននិយាយពីរសជាតិវានោះទេ គឺខ្ញុំ>និយាយអំពីការរិះគន់<ពីចំណីអាហារ បន្ទាប់មកក៏ត្រូវគេចាប់ខ្លួនហើយយកទៅសួរចម្លើយ ហើយប្រហែលជាអាចត្រូវគេសម្លាប់ផងក៏មិនដឹង។>។ អ៊ីចឹង ខ្ញុំចង់ដឹងថាលោកជាអ្នកសម្រេចក្នុងការចាប់ខ្លួនមនុស្ស<ដែលគ្រាន់តែរិះគន់តែប៉ុណ្ណឹង> ឬក៏ការសម្រេចហ្នឹងមកពីថ្នាក់<ស្រុក ឬថ្នាក់តំបន់>?

[០៩:៤១:២៣]

**ឆ៖** បាទ ការមនុស្សទាំងអស់នេះ ខ្ញុំបាទនៅទទួលខុសត្រូវមិនបានដឹង ប្រហែលជាខាងស្រុកឬយ៉ាងណាដូចខ្ញុំបានជម្រាបរួចហើយ ព្រោះការដ្ឋាននេះនៅឯទួលគ្រួសឯណោះ ឆ្ងាយពីសាលាឃុំ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ខ្ញុំមានឯកសារមួយទៀតមកពីក្រាំងតាចាន់ គឺឯកសារលេខ E3/4083 ខ្ញុំប្រើ<ប្រាស់វាក្នុងគោលបំណងចំនួន>ពីរ។ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបញ្ចាំងឯកសារនេះលោកប្រធាន។ <ខ្ញុំនឹងជម្រាបជូនលេខ ERN ឥឡូវនេះតែម្តង។>

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** នេះជា<សៀវភៅសរសេរ>មួយ<ក្បាល>ទៀត មកពីក្រាំងតាចាន់ដែលមានបញ្ជីឈ្មោះអ្នកទោសដែលត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៨។ បញ្ជីហ្នឹងគឺមានអ្នកទោសយ៉ាងហោចណាស់ប្រាំមួយនាក់ ដែលបញ្ជូនមកពីឃុំស្រែរនោង <ខណៈពេលដែល>លោក<ធ្វើ>ជាមេឃុំ។ ជាដំបូងគឺទំព័រជាភាសាខ្មែរ 00068025, ជាភាសាអង់គ្លេស 00323944 ទំព័រទី២, ជាភាសាបារាំង 00778852។ នៅក្នុងនេះ យើងឃើញមានឈ្មោះយើងឃើញមាន<ឈ្មោះ ឬមិនមានឈ្មោះតែមានតួនាទីជា>អតីតលេខាធនាគារពាណិជ្ជ<> ដែលបានឃុំនៅថ្ងៃទី១៩ <ខែមីនា> ឆ្នាំ១៩៧៨ <កម្ទេចចោល>នៅថ្ងៃទី២៩ មីនា ១៩៧៨។ ប្រហែលជាឈ្មោះហ្នឹង ឈ្មោះ វ៉ាត់ ថន ហ្នឹងហើយដែលខ្ញុំបាន

រៀបរាប់អម្បាញ់មិញហ្នឹងហើយ ព្រោះគាត់ជាអតីតលេខាធនាគារពណិជ្ជ<>។

[០៩:៤៣:៣០]

នៅទំព័រដដែលជាភាសាខ្មែរហ្នឹង គឺនិយាយអំពីអ្នកដែលមកពីស្រែរនោងគឺចូលទៅក្រាំងតាចាន់ នៅថ្ងៃទី២៩ <ខែមេសា> ប្រហែលជាឆ្នាំ១៩៧៨។ ជាភាសាអង់គ្លេសគឺ 00323946, ជាភាសាបារាំង គឺ 00778853។ បន្ទាប់មកទៀតមានឈ្មោះ សៀវ អាយុ៤៣ឆ្នាំ មកពីភូមិត្រពាំងរនោង ឃុំស្រែរនោង ។ នៅទំព័រ<ជាភាសាខ្មែរ>គឺ 00068027, ជាភាសាអង់គ្លេសគឺទំព័រទី១០ គឺ ERN00323952,ជាភាសាបារាំង 00778860។ បន្ទាប់មកទៀតមានគ្រូបង្រៀនម្នាក់ និងអតីតពលបាល<ពីររូបពីរបបលន់ នល់> គឺនៅទំព័រជាភាសាខ្មែរ 00068029, ជាភាសាអង់គ្លេស <ទំព័រ១៥ មានលេ ខERN> 00323957, ជាភាសាបារាំង 00778863 គឺគ្រូបង្រៀនហ្នឹងត្រូវបានចាប់ខ្លួននៅថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៧៨។នៅខាងក្រោមទំព័រដដែលមានអតីតកាប៉ូរ៉ាល់នៅស្រែរនោង ដែលចូលមកថ្ងៃទី៥ <ខែមីនា> ហើយស្លាប់ដោយសារជំងឺនៅថ្ងៃទី១៩ <ខែមីនា> ឬក៏<ខែឧសភា> ឆ្នាំ១៩៧៨ <តាមរយៈការបកប្រែនេះ>។ <ហើយចុងក្រោយគឺ>អតីតកាប៉ូរ៉ាល់<ម្នាក់>ទៀត ដែលត្រូវបានឃុំនៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៧៨ និងត្រូវបានកម្ទេចនៅថ្ងៃទី២៩ <ខែមីនា> ឆ្នាំ១៩៧៨។ ជាភាសាខ្មែរគឺដដែលគឺ 00068029, ជាភាសាបារាំង 00778864, ជាភាសាអង់គ្លេសគឺ 00323958។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[០៩:៤៥:៥២]

**លោក វ៉ិចទ័រ កូប៉េ៖**

អរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម ខ្ញុំសូមជំទាស់ទៅនឹងពាក្យថា “<កម្ទេច>”។ ខ្ញុំគិតថា ជាការប្រសើរប្រសិនបើព្រះរាជអាជ្ញាប្រើប្រាស់>ពាក្យ“<កម្ទេចដោយចោទប្រកាន់>” ដោយសារ<តែគាត់យោងទៅលើគំនូសលើទំព័រឯកសារហ្នឹង តែ>យើងមិនដឹងថា <វា>ជាឯកសារមកពីក្រាំងតាចាន់ ឬក៏អត់នោះទេ។ ហើយមិនដឹងថាតើការគូសខ្វែងនេះ បញ្ជាក់ថាជាការម្ទេច ឬក៏អត់នោះទេ។ <ដូច្នេះ ខ្ញុំគិតថាក្នុងខណៈនេះគាត់គួរតែប្រើពាក្យ “កម្ទេចដោយចោទប្រកាន់” ដើម្បីកុំឲ្យសាក្សីវង្វេងវង្វាន់នឹងការប្រើប្រាស់ពាក្យនេះ។>

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

សូមអរគុណ។ ខ្ញុំមិននិយាយអំពីការលើកឡើងរបស់គាត់ដែរថា<>“ឯកសារហ្នឹង<ប្រហែល> មិនមែនមកពីក្រាំងតាចាន់ទេ”<។> ក៏ប៉ុន្តែឯកសារហ្នឹង<>អង្គជំនុំជម្រះ<បានសម្រេចទទួលយក> ហើយ <លើសពីនេះទៀត មាន>សាក្សីមួយចំនួនបានផ្តល់យថាភាពទៅលើឯកសារនេះរួចទៅ<ហើយដែរ>។ អ៊ីចឹង ខ្ញុំគ្រាន់តែប្រើប្រាស់ពាក្យពេចន៍ដែលបកប្រែមក<ពីភាសាខ្មែរ ទៅជាភាសាអង់គ្លេស ហើយនៅភាសាបារាំងសរសេរច្បាស់ថា “*អេលីមីណេ*”>។ មិនមែនខ្ញុំជាអ្នកបង្កើតពាក្យហ្នឹងទេ គឺការបកប្រែមក គេដាក់មកអ៊ីចឹង គេដាក់ពាក្យថា “កម្ទេច”។ នេះជាការបកប្រែតែប៉ុណ្ណោះ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្កាឯល៖**

**ស៖** លោកសាក្សី ប្រសិនបើមិនមានអ្នកណាមួយត្រូវបានចាប់ខ្លួននៅក្នុងឃុំរបស់លោកទេ អ៊ីចឹងតើលោកពន្យល់យ៉ាងម៉េចបានថា <មានមនុស្ស>ប្រាំមួយនាក់ហ្នឹង ត្រូវ<គេចាប់>បញ្ជូនទៅមន្ទីរសន្តិសុខនោះ ឆ្នាំ១៩៧៨?

[០៩:៤៧:៣១]

**លោក នុត នួវ៖**

**ឆ៖** បាទ សូមអរគុណ។ ឈ្មោះទាំងអស់នេះ ប្រហែលជាមុនខ្ញុំទៅ គេបញ្ជូនទៅក្រាំងតាចាន់បានជាខ្ញុំមិនបានដឹង ព្រោះខ្ញុំចូលទៅអត់មានការបញ្ជូនទេនៅក្នុងឃុំស្រែរនោង ដូចបានជម្រាបរួចមកហើយ ហើយឈ្មោះទាំងអស់ ក្រែងគេបញ្ជូនទៅនៅមន្ទីរសន្តិសុខក្រាំងតាចាន់ហ្នឹងពីមុនខ្ញុំចូលទៅ។ នេះសូមអរគុណ។

**ស៖** លោកបានឆ្លើយថា លោកទៅដល់នុ៎ង គឺឆ្នាំ<១៩៧៨> ឬចុង<ឆ្នាំ១៩៧៧> ហើយ<បើខ្ញុំចាំមិនខុសទ គឺ>អ្នកទាំងអស់នោះ<ត្រូវគេចាប់យក>ចូលទៅក្រាំងតាចាន់ហ្នឹង គឺខែមីនា ឆ្នាំ១៩៧៨។ អ៊ីចឹង ពេលហ្នឹងគឺលោកនៅទី<នោះ>ហើយ។ អ៊ីចឹងសំណួរនេះ ប្រហែលជាសំណួរចុងក្រោយពាក់ព័ន្ធនឹងចំណុចនេះ។ តើនៅក្នុងឃុំផ្សេងៗដែលលោកបានធ្វើការនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ មាន<គេធ្វើ>បញ្ជីឈ្មោះជនជាតិវៀតណាម ឬ<>កម្ពុជាក្រោម<>ហើយ<>បញ្ជូនទៅ<ឲ្យ>ស្រុក<ដែរឬ>ទេ<នៅពេលនោះ>?

**ឆ៖** បាទ នៅក្នុងឃុំផ្សេងៗ ក៏ដូចជាឃុំខ្ញុំអ៊ីចឹងដែរ។ ការសម្រង់បញ្ជីតែងតែមាន ប៉ុន្តែធ្វើនេះទុកក្នុងថ្នាក់ឃុំ គ្រាន់តែសម្គាល់ បើមានហេតុការណ៍អីក៏នៅជាធម្មតា គ្រាន់តែជំរឿនប្រជាជន។ សូមអរគុណ។

[០៩:៤៩:៣០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមលើកឡើងចំពោះ<ការជំទាស់របស់ខ្ញុំទៅនឹង>ឯកសារ E3/4083។ ខ្ញុំនៅក្នុងអត្ថបទ<ជាភាសាអង់គ្លេស>នេះ ខ្ញុំអត់មានឃើញពាក្យជាភាសាអង់គ្លេសថា "<*អេលីមីណេ*>" ហ្នឹងទេ។ សូមឲ្យសហព្រះរាជអាជ្ញារងបញ្ជាក់នៅត្រង់ណានៃឯកសារ E3/4083 ហ្នឹង ដែលមានពាក្យថា "កម្ទេច" ហ្នឹង? <ខ្ញុំឃើញមានពាក្យគេនិយាយថា "ស្លាប់ដោយសារជំងឺ" ចំពោះអ្នកទោស។>ប្រហែលជាមានការបកប្រែខុសគ្នាទៅជាភាសាបារាំង និងជាភាសាអស់គ្លេស។ <ខ្ញុំគ្រាន់តែចង់បញ្ជាក់ឲ្យបានច្បាស់តែប៉ុណ្ណោះ>។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ប្រហែលជាមានភាពខុសគ្នានៃភាសាបកប្រែ<បន្តិចបន្តួច>ហើយ ក៏ប៉ុន្តែនៅក្នុងសំណៅជាភាសាបារាំងគឺមានប្រើពាក្យថា "កម្ទេច" <នៅក្នុងឯកសារភាសាបារាំងពាក់ព័ន្ធនឹង>កម្ទេចអតីតលេខាធនាគាពាណិជ្ជខ្មែរ<។ មានជាភាសា>អង់គ្លេសគឺទំព័រ២<។ លើសពីនេះ ERNជាភាសាអង់គ្លេសលេខ 00323958>។ ហើយនៅ<ក្នុងភាសាអង់គ្លេសគេសំដៅទៅ>អតីតកាប៉ូរ៉ាល់ហ្នឹង<។ ពាក្យនេះជាភាសាបារាំងគេប្រើអ៊ីចឹង>។ <ខ្ញុំយល់>ថា<ការ>បកប្រែភាសាផ្សេងៗ<ប្រាកដជាមានភាពខុសគ្នាបន្តិចបន្តួចមិនខានឡើយ>។ <លោកប្រធាន >ខ្ញុំ<សល់>ពេល<មិន>ច្រើនទៀតទេ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំគិតថាប្រហែលជាមានការលំបាកពាក់ព័ន្ធ<>នឹងការយោងទៅនឹងឯកសារនេះ។ កាលពីព្រឹកមិញនេះ ខ្ញុំឮសហព្រះរាជអាជ្ញាយោងទៅលើឯកសារលេខ E3/4083 ហើយខ្ញុំឮលោកមេធាវី កូប៉េហ្នឹង គាត់លើកឡើងឯកសារ E3/4093។ អ៊ីចឹងប្រហែលជា<យើងកំពុងតែជជែកគ្នាលើ>ឯកសារ<ពីរ>ផ្សេងគ្នាហើយ<>។ អ៊ីចឹងតើមួយណាត្រឹមត្រូវ E3/4083 ឬក៏ <E3/4093>?

**លោក វ៉ិចទ័រ កូប៉េ៖**

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

គឺឯកសារ <>E3/4083។ សហព្រះរាជអាជ្ញាបាននិយាយថា អាចមាន<>ភាពខុសគ្នា។ <សម្រាប់ខ្ញុំមានពាក្យ “*អេលីមីណេធីត*” និងពាក្យគ្មាន “*អេលីមីណេធីត*” នោះគឺវាមិនមែនជារឿងខុសគ្នាតិចតួចនោះទេ វាខុសគ្នាឆ្ងាយណាស់។ ជាថ្មីម្តងទៀតនេះ>គឺឯកសារ E3/4083 ជាភាសាអង់គ្លេសអត់មានឃើញពាក្យថា “<*អេលីមីណេតធីត*>” នោះទេ។ <សូមជួយប្រាប់ខ្ញុំផងប្រសិនបើមានពាក្យនេះមាននៅត្រង់កន្លែងណាក្នុងឯកសារភាសាបារាំងនោះ>។

[០៩:៥២:១០]

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ ទំព័រជាភាសាបារាំង<ពិតជាមាន គឺនៅត្រង់ទំព័រ> 00778852 គឺនិយាយអំពីអតីតលេខាធនាគាពាណិជ្ជខ្មែរ។ ប្រហែលជាភាសាអង់គ្លេសបកមិនអស់ន័យសេចក្តីជាភាសាដើមខ្មែរ ឬក៏យ៉ាងម៉េច<ទេ។ លោកប្រធាន សម្រាប់សំណួរនេះ> ខ្ញុំគិតថាមិនគួរជជែកគ្នាអីវែងឆ្ងាយ<នៅក្នុងពេលនេះ>ទេ ខ្ញុំគ្រាន់តែចង់ឱ្យសាក្សីមើលថា <>មានមនុស្សត្រូវ<>គេចាប់ខ្លួន ហើយបញ្ជូនទៅក្រាំងតាចាន់ហើយ<ត្រង់ថាកម្មេច ឬមិនកម្មេចនោះ> យើងអាចនិយាយពេលក្រោយ នៅពេលដែលយើងពិភាក្សាគ្នាទៅលើបញ្ហាឯកសារ។ អ៊ីចឹងពេលនេះ មិនគួរមានការតតាំងគ្នាទៅលើចំណុចនេះទេ លោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ឥឡូវនេះ ខ្ញុំចង់ ខ្ញុំយកដូចជាយកម៉ោងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅហើយ ក៏ប៉ុន្តែខ្ញុំចង់យោងទៅឯកសារដដែលហ្នឹងគឺ E3/4083 គឺមានទំព័រពីរជាភាសាខ្មែរគឺ 00068033 និងរំលងមួយទំព័រចូលទៅ 00068035 គឺពីរទំព័រគឺជាបញ្ជីបន្តគ្នា ក៏ប៉ុន្តែមានទំព័រមួយនោះយកមក<ដាក់>ចូល<ចន្លោះទំព័រទាំងពីរនោះ>។ ជាភាសាអង់គ្លេសគឺ 00323966 ទៅដល់ 68 ហើយបន្ទាប់មកគឺនៅលេខចុងគឺ 70 ទៅដល់ 72។ ជាភាសាបារាំង 00778870 ទៅដល់ 71 និង 00778873 ទៅដល់ 74។ នេះគឺជាបញ្ជីឈ្មោះមកពីឃុំស្រែរនោង ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៧ <ដែលជាបញ្ជីឈ្មោះ រួមទាំងឋានន្តរសក្តិ> ខ្មែរក្រោម ឬអតីត<ទាហាន> ឬមន្ត្រីរដ្ឋការរបប លន់ នល់<ចំនួន៣៧គ្រួសារ>។ <>

លោកសាក្សី លោកឆ្លើយថានៅក្នុងឃុំរបស់លោកនោះ មានការធ្វើបញ្ជី ហើយគេរក្សាទុកបញ្ជីនោះ។ អ៊ីចឹងខ្ញុំចង់ដឹងថា ហេតុអ្វីបានជា<នៅ>ឃុំស្រែរនោង ស្រុកត្រាំកក់ហ្នឹង ធ្វើបញ្ជីឈ្មោះខ្មែរក្រោម ឬអតីតយោធាទាហាន លន់ នល់ នៅខែមេសា ឆ្នាំ១៩៧៧ នោះ?

[០៩:៥៥:០២]

**លោក នុត នូវ៖**

**ឆ៖** បាទ អរគុណណាស់។ ក្នុងឆ្នាំ១៩៧៧ ខ្ញុំដឹងថាគេសម្រង់ប្រជាជនដែលមកមានសញ្ជាតិជាវៀតណាម ឬក៏ជាអ្នកមកពីកម្ពុជាក្រោមគេធ្វើទុក តម្កល់ទុកនៅក្នុងឃុំរបស់គេ។ ឯលិខិតនេះ ខាងស្រែរនោងធ្វើនេះប្រហែលជាជំនាន់លោកតាឃុន បាទលោកធ្វើនេះ។ ខ្ញុំអត់មានធ្វើទេនៅស្រែរនោងគឺគេធ្វើរួមរាល់អស់ហើយ ដូចបានជម្រាបខាងដើម។ បញ្ជីនេះ ប្រហែលជាជំនាន់តាឃុនគាត់ធ្វើ។ ខ្ញុំមិនបានដឹងទេ។

**ស៖** តើមានរឿងអ្វីកើតឡើងចំពោះអ្នកដែលត្រូវបានគេចុះឈ្មោះនៅក្នុងបញ្ជីហ្នឹង <ដែលមកពីឃុំផ្សេងៗ ថាតើពួកគេជា>ជាជនជាតិវៀតណាម <ឬក៏>ខ្មែរក្រោម<ទេ>។ អ៊ីចឹង តើ<មានអ្វីកើតឡើងដល់អ្នកទាំងនោះបន្ទាប់មកទៀតទេ>?

**ឆ៖** បាទ គេធ្វើហើយ គេគ្រាន់តែតម្កល់ទុកជាសារតាំងមួយដើម្បីឲ្យបានដឹងនៅក្នុងឃុំ។ បាទ សូមអរគុណ។

[០៩:៥៦:៣៦]

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៀតទៅ លោក វ៉ិចទ័រ កូប៉េ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំ<សូមអធ្យាស្រ័យ ដូចថាខ្ញុំមានៈបន្តិចហើយ។ ខ្ញុំត្រូវតែនិយាយពីឯកសារនេះឡើងវិញហើយ ព្រោះថាឥឡូវនេះទាំងទំព័រជាភាសាបារាំង និងទំព័រជាភាសាអង់គ្លេសមាននៅពីមុខខ្ញុំហើយ>។ ទំព័រជាភាសាបារាំងគឺ E3/4083, ERN 00778852 ដែលបាននិយាយថា <"ថ្ងៃទី១៩ ខែមីនា "*អេលីមីណេ*" ហើយចុះកាលបរិច្ឆេទ> នៅ<ថ្ងៃទី២៩>ខែមីនា <ឆ្នាំ១៩៧៨។ កាលបរិច្ឆេទនេះ និង>ពាក្យថា "*<អេលីមីណេ ឬអេលីមីណេធីត>*"នេះមិនមាននៅក្នុងអត្ថបទជាភាសាអង់គ្លេសទេ<។ ឥឡូវនេះហាក់ដូចជាច្បាស់ហើយថា សាក្សីមិនអាចនិយាយពីបញ្ហានេះឡើយ ប៉ុន្តែបើមានការ>ខុសគ្នា<ខ្លាំងក្នុងការបកប្រែក្នុងឯកសារសំខាន់យ៉ាងនេះ ខ្ញុំគិតថាយើងពិតជាមានបញ្ហាហើយ>។

[០៩:៥៧:៥០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥៩:១៥]

**ប្រធានអង្គជំនុំ៖**

ឯកសារនេះ គឺមកពីភាសាខ្មែរពិតណាស់ភាសាខ្មែរហ្នឹងគឺប្រើពាក្យ "ក.ទ"។ "ក.ទ" ហ្នឹងគឺដែលឯកសារបង្ហាញនេះមានន័យថា អក្សរកាត់នៃពាក្យថា "កម្ទេច" ហើយនៅក្នុងចំណុចដែលលើកឡើងដោយសហព្រះរាជអាជ្ញារងអម្បាញ់មិញនេះ វាមិនសរសេរដដែលឡើងវិញទេ ប៉ុន្តែនៅខាងលើគេសរសេរថា "កម្ទេច" ថ្ងៃទី២៩ ខែ៣ ៧៨។ ហើយនៅខាងក្រោមបន្តបន្ទាប់គេដាក់ សរសេរគូសជាបន្ទាត់ ហើយដាក់ធ្មេញកណ្ដុរ មានន័យដូចគ្នា បានន័យថាដូចគ្នា "កម្ទេច" ថ្ងៃទី២៩ ខែ៣ ឆ្នាំ៧៨ ដូចគ្នា។ នេះជាភាសាខ្មែរ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធានដែលបានពន្យល់។ ចំណុចនេះ ខ្ញុំមិនដឹងថាៗតើ<អក្សរកាត់> "ក.ទ", "ខេ.ធី" នេះ<ពិតជាមានន័យ> "កម្ទេច" <ឬក៏>យ៉ាងម៉េច<ទេ។ ប៉ុន្តែបើយើងពិចារណាបន្តិច> ហេតុអ្វីបានជាអត្ថបទជាភាសាអង់គ្លេសមិនមានឃើញចុះកាលបរិច្ឆេទ<> ហេតុអ្វីបានជាអ្នកបកប្រែទៅជាភាសាអង់គ្លេសមិន<អាច>បកប្រែ<ពាក្យនេះបាន> ហើយ<ហេតុអ្វីបាន>ជា<អ្នកបកប្រែ>ភាសាបារាំង<អាច>បក<បានទៅវិញ។>

[១០:០០:៥០]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:០១:០៥]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដើម្បីសន្សំសំច័យពេលវេលា អង្គជំនុំជម្រះសម្រេចថាឯកសារនេះ អង្គជំនុំជម្រះនឹងឱ្យខាងអង្គភាពបកប្រែភាសាបកប្រែបញ្ជាក់សាឡើងវិញលើបញ្ហានេះឱ្យបានច្បាស់លាស់ ហើយនឹងជម្រាបជូនភាគីបានជ្រាប។ សូមអញ្ជើញតសហព្រះអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

<ខ្ញុំគ្រាន់តែជម្រាបថា យើងខ្ញុំពុំមានសំណួរអ្វីសួរបន្ថែមទៀតទេ លោកប្រធាន ហើយ> ពេលវេលា<របស់យើង>ខ្ញុំ<ក៏>ផុតទៅហើយ<ដែរ>លោកប្រធាន។ អ៊ីចឹងខ្ញុំចប់ត្រឹមនេះចុះ ហើយបញ្ជូនសូមអនុញ្ញាតប្រគល់វេទិកានេះជូនតាមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ <អរគុណ

ហើយលោកប្រធាន។>

**ប្រធានអង្គជំនុំ៖**

បាទសូមអញ្ជើញ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោក ឡោ ជុនធី៖**

បាទ ជាបឋម--

**ប្រធានអង្គជំនុំ៖**

លោកមេធាវីប្រើពេលសួរតែម្តងទៅ ជៀសវាងបត់បែនច្រើន មិនបាច់គួរសមច្រើនទេ ពេលវេលាលោកមានតែ១០នាទីប៉ុណ្ណោះ។

បើកក្បាលមីក្រូហ្វូន!

**លោក ឡោ ជុនធី៖**

អរគុណលោកប្រធាន ខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** សូមជម្រាបសួរទៅលោកសាក្សីនៅពេលនេះ។ អម្បាញ់មិញគឺខាងសហព្រះរាជអាជ្ញាបានលើកឡើងអំពីបញ្ហាមួយចំនួនហើយ ឥឡូវខ្ញុំសូមជម្រាបសួរនូវចំណុចដើមមួយចំនួនដែលពាក់ព័ន្ធគឺថា តើពេលដែលប្រជាជនជម្លៀសដែលទៅដល់មូលដ្ឋានខាងលោកសាក្សីហ្នឹង តើមានការធ្វើប្រវត្តិរូបហ្នឹងប៉ុន្មានដងដែរ?

[១០:០៣:១៤]

**លោក នុត នូវ៖**

**ឆ៖** បាទសូមអរគុណ។ ពេលដែលប្រជាជនជម្លៀសចូលដល់មូលដ្ឋាន កាលនោះខ្ញុំគ្មានសិទ្ធិធ្វើបញ្ជីទេ ព្រោះខ្ញុំនៅតែមន្ទីរសេដ្ឋកិច្ចនៅញ៉ែងញ៉ងហ្នឹង ធ្វើបញ្ជីលើគណៈឃុំគេអ្នកធ្វើ។ ប៉ុន្តែប៉ុន្មានដងៗខ្ញុំបាទមិនបានដឹងទេ ហើយខ្ញុំគិតគួរតែពីរកស្បៀងជូនសមរភូមិមុខ។ សូមអរគុណ។

**ស៖** ចុះថាតើកាលនោះមានការកោះប្រជុំក្នុងគណៈឃុំ គណៈអី ដែលផ្សព្វពីការធ្វើប្រវត្តិរូបហ្នឹងដែរអត់ទេបាទ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

**លោក នុត នូវ៖**

**ឆ៖**បាទ ពិតជាមានប្រជុំតាមមេភូមិគ្រប់ភូមិជាមួយជាមេឃុំ ក្នុងការធ្វើបញ្ជីនេះពិតជាមាន ប៉ុន ខ្ញុំមិនដែលបានចូលរួមធ្វើទេ។

**សួរដោយលោក ឡៅ ជុនធី៖**

**ស៖** លោកបានលើកឡើងអំពីថា មានការបោសសម្អាតក្នុងជួរ និងក្រៅជួរ។ ខ្ញុំចង់ដឹងថា តើការដាក់ផែនការមកឲ្យភូមិឃុំដែលអនុវត្តហ្នឹង តើមានការដាក់ប្រជុំនៅលើផែនការហ្នឹងមកលើឃុំហ្នឹងដែរអត់ទេ បានជាយើងអាចធ្វើជាបញ្ជី ឬមួយធ្វើជាអីបានបាទ?

[១០:០៥:៣៧]

**ឆ៖** បាទ ខាងផែនការ ហៅថាបោសសម្អាតខ្មាំងក្នុងជួរ និងក្រៅជួរនេះពិតជាមានប្រកាសពីគណៈស្រុក ពីតំបន់មក។ នៅក្នុងជួរ គឺខ្មាំងជាកម្មាភិបាល តែអ្នកធ្វើខុស គេហៅថាខ្មាំងហើយ ទោះជាកម្មាភិបាលអីក៏ដោយចុះ។ បាទ ឃើញបាត់ជាបណ្តើរៗ គេដកទៅកន្លែងនេះ គេដកទៅកន្លែងនោះ ឯខ្មាំង អ្នកដែលប្រឆាំងនឹងសហករណ៍គឺក្រៅជួរ។ មិនមានតែប្រជាពលរដ្ឋពេញសិទ្ធិ ប្រជាពលរដ្ឋត្រៀម ប្រជាពលរដ្ឋបញ្ញើទេ គឺអ្នកណាដែលប្រឆាំង អ្នកនោះជាខ្មាំង។ ពិតប្រាកដណាស់។ សូមអរគុណ។

**ស៖** បាទ អរគុណ។ ត្រង់ចំណុចនេះ តើអ្នកណាដែលធ្វើជារបាយការណ៍ដែលពាក់ព័ន្ធនឹងព័ត៌មានរឿងខ្មាំងក្នុងជួរ និងក្រៅជួរនេះ?

**ឆ៖** បាទ អ្នកធ្វើរបាយការណ៍គឺពីឃុំទៅថ្នាក់ស្រុក ឡើងទៅតំបន់ ប៉ុន្តែអ្នកសរសេរ ជួនក៏មេឃុំសរសេរ ជួនក៏ហៅថាមានលេខានៅក្នុងមន្ទីរឃុំជាអ្នកសរសេរ។ បាទ សូមអរគុណ។

[១០:០៧:២៦]

**ស៖** បាទ អរគុណ។ ចំណុចនេះ លោកបានលើកឡើងអំពីថាមានលេខា ឬមួយស្មៀនឃុំ។ តើខ្ញុំចង់ឲ្យលោកជម្រាបអង្គជំនុំជម្រះថា តើលេខា ឬស្មៀនឃុំហ្នឹង គាត់មានសិទ្ធិប៉ុនណា ដែលគាត់អាចសរសេរដោយខ្លួនគាត់ ឬមួយគាត់មានសិទ្ធិយ៉ាងម៉េច?

**ឆ៖** បាទ លេខា ឬស្មៀនឃុំនេះមានសិទ្ធិត្រឹមសរសេរតាមរបាយការណ៍ពីភូមិ។ មិនមានសិទ្ធិសម្រេចទេ គ្រាន់តែសរសេរតាមរបាយការណ៍ពីភូមិមួយៗមក ហើយបញ្ជូនទៅថ្នាក់ស្រុក។ បាទ សូម

អរគុណ។

**ស៖** តើនៅពេលដែលលោកធ្វើជាគណៈ បានន័យថាគណៈឃុំដែលពាក់ព័ន្ធដូចជាឃុំញ៉ែងញ៉ង ឃុំស្រែរនោង ហើយឃុំអង្គតាសោមហ្នឹង សុទ្ធតែមានស្មៀន ហើយជួយការងារនេះរហូត ឬមួយយ៉ាងម៉េច?

**ឆ៖** ការពិតនោះ ក្នុងឃុំនីមួយៗតែងតែមានស្មៀនជួយការងារភារកិច្ចនៅក្នុងឃុំ។ ព្រោះជួនគណៈឃុំ លោកចុះតាមការដ្ឋានទៅអត់បានដឹងទេ គិតតែពីធ្វើ។ ដូចខ្ញុំនេះពីឆ្នាំ៧៧មក ខ្ញុំទៅតែការដ្ឋាននៅកំពង់យោលអង្គរកា ទួលសង្កែ ឯណោះ។ បាទ អ៊ីចឹងនៅខាងឃុំនេះ គឺមានអ្នកជំនួសនៅឃុំ។ អ៊ីចឹង ១ឆ្នាំធ្វើការដ្ឋានជីកប្រឡាយផង ទៅចូលរួមធ្វើស្រែប្រាំងនៅឯកំពង់យោលផង។ ហ្នឹង១ឆ្នាំពេញ ឆ្នាំ៧៧។ កាលណោះ ខ្ញុំនៅជាសមាជិកឃុំនៅឡើយ។

[១០:១០:០០]

**ស៖** បាទ អរគុណ។ លោកបានលើកឡើងអំពីថាការដ្ឋាន បានន័យថាការដ្ឋានមានកងចល័តទៅទីនោះ។ ខ្ញុំចង់ដឹងថាតើកងចល័តដែលបញ្ជូនទៅការដ្ឋានហ្នឹង មានការបែងចែកដូចជាប្រភេទប្រជាជនដែលបែងចែកប្រភេទប្រជាជនជាបីប្រភេទហ្នឹងដែរអត់ នៅការដ្ឋានបាទ?

**ឆ៖** បាទអរគុណ ការទៅចូលការដ្ឋានអត់មានបែងចែកជាប្រភេទទេ គឺធ្វើរួមគ្នាតែម្តង។ គណៈឃុំក៏ចូលរួមធ្វើ ប្រជាពលរដ្ឋគឺរួមគ្នាធ្វើទាំងអស់គ្នាបាទ នៅក្នុងការដ្ឋានជីកប្រឡាយ ក៏ដូចជាស្រែប្រាំង ប៉ុន្តែមានចែកក្រុមទទួលភារកិច្ចខាងទឹកអ៊ីចឹងទៅ ខាងស្ទូងអ៊ីចឹងទៅ ខាងភ្ជួរអ៊ីចឹងទៅ បាទមានចែកអ៊ីចឹង មានពិតប្រាកដមែន។

**ស៖** បាទអរគុណ។ តើកុមារដែលនៅក្មេងៗហ្នឹង ថាតើគេចាត់ឲ្យពួកគាត់ធ្វើអីដែរ នៅក្នុងឃុំរបស់លោកនោះ?

**ឆ៖** កុមារា កុមារី នៅជំនាន់នោះ គេចាត់តាំងឲ្យប្រមូលអាចម៍គោយកមកដាក់ឃ្លាំង។ ថ្ងៃឲ្យរៀន១ម៉ោង ឬ២ម៉ោង រៀនជាអក្សរ។ ពេលចន្លោះការងារ គឺឲ្យដើរប្រមូលអាចម៍គោ ឬកាប់ទន្រ្ទានខែត្រយកមកធ្វើជីធម្មជាតិ។

[១០:១២:២៣]

**ស៖** តើកុមារដែលគេឲ្យរៀននៅក្នុងសម័យនោះ មានជាសាលារៀន ឬមួយមានជាកន្លែងបង្រៀនអីត្រឹមត្រូវទេ? ហើយមានគ្រូដែលមានការបណ្តុះបណ្តាលដែរអត់ទេបាទ?

**ឆ៖** បាទការពិត ការរៀនជំនាន់នោះគ្មានសាលាត្រឹមត្រូវទេ រៀននៅក្រោមម្លប់ឈើ ឬក្រោមផ្ទះ។ ហើយគ្រូបង្រៀនហ្នឹង គឺគ្រូគ្រាន់តែចេះអាន ចេះសរសេរអក្សរខ្មែរទេ មិនមានការបណ្តុះបណ្តាលអីឲ្យជ្រៅជ្រះទេ មានគ្រូសល់ពីសង្គមខ្លះ ឬក៏ក្មេងដែលចេះអក្សរហ្នឹង អាចបង្រៀនកុមារជាបន្ត។

**ស៖** បាទអរគុណ។ តើនៅក្នុងឃុំដែលលោកបានកាន់កាប់ ហើយនិងធ្វើនោះ មានផ្នែកហៅថាសុខាភិបាលព្យាបាលយ៉ាងម៉េច ប្រសិនបើប្រជាជនមានការឈឺថ្កាត់ហ្នឹង ត្រូវយកទៅព្យាបាលនៅឯណា? ហើយមានពេទ្យអីសម្រាប់ព្យាបាលដែរអត់ទេបាទ?

**ឆ៖** បាទ នៅក្នុងឃុំនីមួយៗ ពិសេសនៅឃុំខ្ញុំមានបុគ្គលិកពេទ្យប្រាំ ប្រាំមួយនាក់សម្រាប់ព្យាបាលប្រជាពលរដ្ឋ។ ហើយបើជំងឺមិនអាចព្យាបាលបាន គេបញ្ជូនទៅពេទ្យតំបន់នៅអង្គរនាប នៅកន្លែងវត្តអង្គរនាប ដើម្បីព្យាបាលបន្ត។ ឯថ្នាំពេទ្យហ្នឹង គឺតិចតួចណាស់ មិនមានជាច្រើនទេ។ សូមអរគុណ។

[១០:១៩:៣៨]

**ស៖** ថ្នាំពេទ្យដែលយកមកព្យាបាលហ្នឹងជាឱសថផ្នែកបុរាណ ឬមួយឱសថបែបយ៉ាងម៉េចយកមកព្យាបាលហ្នឹងបាទ?

**ឆ៖** ថ្នាំពេទ្យយកមកព្យាបាលមានតិចណាស់ជាឱសថបុរាណ មានប៉េនីសាលីន មានស្ត្រឹបតូមានអីផ្សេងៗហ្នឹង គឺបើកមកពីមន្ទីរពេទ្យស្រុក ហើយភាគច្រើន គឺថ្នាំពេទ្យដែលស្លដាក់ដបប្រហែលជាកន្លះៗលីត្រហ្នឹងទេ។ ខ្ញុំមិនបានយល់ជាសេរ៉ូមប្រៃ ជាសេរ៉ូមផ្អែមអី ក៏ខ្ញុំមិនមានបច្ចេកទេសខាងពេទ្យប៉ុន្តែបានឃើញ។ នេះសូមអរគុណ។

**ស៖** តើអ្នកដែលឈឺថ្កាត់ហ្នឹង ហើយដោយសារផ្នែកវេជ្ជសាស្ត្រនៅខ្សោយអីចឹង មានការស្លាប់ច្រើនដែរអត់ទេ?

**ឆ៖** បាទ ការស្លាប់ពិតជាមាន។ មានជាបន្តបន្ទាប់។ សក្ខីកម្មនៅឃុំស្រែរនោងក្រោយដែលខ្ញុំចូលទៅបានហូបគ្រប់គ្រាន់អត់សូវមានជំងឺស្លាប់ទេ គ្រាន់តែមានជំងឺតិចតួច។ បើពីមុនហ្នឹងគឺមានការបញ្ជូនទៅពេទ្យតំបន់នៅឯអង្គរនាបហ្នឹងមានការស្លាប់ជាបន្តបន្ទាប់។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់សាមសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និង អ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងដប់ និងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៧ នាទី ដល់ម៉ោង ១០:៣៣ នាទី)*

[១០:៣៣:៥២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាបន្តតទៅនេះ សួរអស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីចង់សួរទៅសាក្សីរូបនេះដែរឬទេ? បើសិនមានសូមអញ្ជើញបាទ!

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** បាទ ខ្ញុំមានសំណួរតិចទេ ខ្ញុំសូមឲ្យលោកសាក្សីធ្វើការបំភ្លឺ។ លោកនិយាយពី តាសាន ដែលជាកម្មាភិបាលនៅថ្នាក់ស្រុក។ តើ<>តាសាន<មាន>ឈ្មោះផ្សេងទៀតទេ? <តើគេហៅឈ្មោះគាត់ថា> តាអ៊ួច <ដែរឬទេ>?

**លោក នុត នូវ៖**

**ឆ៖** បាទ កាលជំនាន់នោះ ខ្ញុំអត់បានស្គាល់ឈ្មោះ តាអ៊ួច ទេ ស្គាល់តែ តាសាន។ ហើយតាសាន ហ្នឹងស្គាល់ពិតប្រាកដ ប៉ុន្តែបច្ចុប្បន្នមិនដឹងគាត់នៅឯណាទេ ព្រោះបែកគ្នា តាសានហ្នឹងឈ្មោះតាសាន ហើយបើឈ្មោះក្រៅ តាអ៊ួច មិនដែលឮផង។ បាទ សូមអរគុណ។

[១០:៣៥:២០]

**ស៖** តើមានកម្មាភិបាលផ្សេងទៀតនៅក្នុងស្រុកត្រាំកក់ <>មានឈ្មោះ តាសាន ដែរឬទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<>

**ឆ៖** គឺ តាសាន នៅស្រុកត្រាំកក់ឈ្មោះ តាសាន ហ្នឹងតែម្តង ជាសមាជិកគណៈស្រុក។

**ស៖** ក៏ប៉ុន្តែនៅពេលដែលខ្ញុំអានសក្ខីកម្មរបស់លោកគឺឯកសារ E3/5521 នៅ<ត្រង់សំណួរ> ចម្លើយ៦៧ លោករៀបរាប់ពី<បុគ្គលម្នាក់>ឈ្មោះ តាសាន ដែលជាសមាជិកឃុំស្រែរនោង។ តើលោកចាំចម្លើយលោកនេះ លោកបានឆ្លើយអ៊ីចឹង?

**ឆ៖** តាសាន ខ្ញុំអត់បានឆ្លើយថា ជាសមាជិកឃុំស្រែរនោងទេ។ គឺ តាសាន ជាសមាជិកស្រុកត្រាំកក់បាទ។ គាត់មកដល់ គាត់នៅស្រុកត្រាំកក់តែម្តង។

**ស៖** បាទ ខ្ញុំសូមអានចម្លើយលេខ៦៧ហ្នឹង សំណួរគេសួរថា៖ <"ស>៖ តើអនុប្រធានលោកនៅស្រែរនោងមានឈ្មោះអ្វី<>? <ឆ.៦៧>៖ មានឈ្មោះ សោម ភៅ (ស្លាប់) <>ជាអនុប្រធាន <> និង តាសាន ជាសមាជិក<ធម្មតា>។" <តើនរណា>ជាសមាជិក<គណៈឃុំ>ស្រែរនោង<>?

[១០:៣៧:០០]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមទោសដែលខ្ញុំត្រូវកាត់ គឺយើងមានឈ្មោះ សន – គឺអេស-អូ-អ័រ-អ៊ិន។

**ប្រធានអង្គជំនុំ៖**

បាទ ច្បាស់ហើយឈ្មោះ សន ចាំរង់ចាំសាក្សីឆ្លើយសិន។ បាទ អាចយល់ច្រឡំ ដំបូងយល់ច្រឡំថា សាន ដែរ ប៉ុន្តែ សន ទេ។ ខ្មែរគឺច្បាស់លាស់។ ហើយបកប្រែអំមិញគឺឈ្មោះ សន ច្បាស់លាស់ហើយសាក្សីគាត់ស្តាប់ សន។ ឱ្យគាត់ឆ្លើយសិនថាតើឈ្មោះ សន ហ្នឹងជានរណាគេនៅក្នុងឃុំរនោង? អញ្ជើញសាក្សី!

**លោក នុត នួវ៖**

**ឆ៖** ឈ្មោះ សន ហ្នឹងជាសមាជិកឃុំស្រែរនោង បច្ចុប្បន្ននេះគាត់ស្លាប់បាត់ហើយ។ សោម ភៅ ជាអនុឃុំស្រែរនោង ប៉ុនស្លាប់បាត់អស់ហើយ។ មិនមែន តាសាន ទេគឺ តាសន។ បាទសូមជ្រាប។

[១០:៣៨:២៨]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** បាទ ខ្ញុំសូមអរគុណដែលបានឆ្លើយបំភ្លឺ។ ខ្ញុំមានសំណួរមួយចំនួនទៀតដែលទាក់ទងទៅនឹងកម្មាភិបាល<នៅថ្នាក់>ស្រុក។ តើលោកមានធ្លាប់ឮ<គេហៅមនុស្សម្នាក់>ឈ្មោះ អៀប ឌុច ដែរ

ឬទេ<? គាត់>ជា<អ្នកទទួលខុសត្រូវខាង>យុវជននៅស្រុក<នោះ>?

**ឆ៖** បាទ អរគុណ។ អៀប ឌុច នេះ មានស្គាល់ពិតប្រាកដ។ អៀប ឌុច ហ្នឹងជាប្រធានយុវជនស្រុកត្រាំកក់ពីមុន ក្រោយមកឮថាមកនៅមន្ទីរក្រាំងតាចាន់។ ក្រោយមកទៀតថា ផ្លាស់ទៅនៅភូមិភាគឧត្តរ ប៉ុន្តែមិនដឹងទទួលការងារអី ប៉ុន្តែបច្ចុប្បន្ននេះគាត់ស្លាប់ ដោយខ្យល់គស្រវឹងស្រា ស្លាប់ប្រហែលជា៣-៤ឆ្នាំហើយ។ ខ្ញុំចាំមិនប្រាកដ។

**ស៖** តើលោកមានបានឮគេនិយាយពីឈ្មោះ ផាន់ ឆេន ដែរឬទេ?

**ឆ៖** ផាន់ ឆេន ហ្នឹងគេធ្វើលោក ផាន់ ឆេន ហ្នឹងធ្វើការមុន ឮ បាទធ្លាប់ឮ ប៉ុន្តែបច្ចុប្បន្នមិនដឹងឯណា ប៉ុន្តែគាត់ធ្វើការខាងឃុំគុសពីដើមមក។ បាទ សូមអរគុណ។

**ស៖** តើផាន់ ឆេន នេះ<>ធ្វើការនៅក្រាំតាចាន់ដែរឬទេ?

**ឆ៖** បាទ អរគុណ។ ខ្ញុំមិនដែលបានឮថាធ្វើការនៅក្រាំងតាចាន់ទេ មិនបានដឹងទេ។

**ស៖** តើលោកមានធ្លាប់ឮឈ្មោះកម្មាភិបាលម្នាក់ដែលឈ្មោះ ភី ហើយដែលគាត់ហ្នឹងពិការជើង ថាជើងគាត់ហ្នឹងដើរបុំងពៀចបាទ?

**ឆ៖** បាទ ឈ្មោះ ភី ខ្ញុំក៏ធ្លាប់ស្គាល់ដែរ ពិការជើងបុំងពៀច ពីមុនគាត់នៅមន្ទីរស្រុកត្រាំកក់ក្រោយមក គេឲ្យទៅធ្វើគណៈឃុំនៅខាង១០៧ ប៉ុន្តែមិនដឹងឃុំរកា ឬឃុំរនាម ខ្ញុំចាំមិនច្បាស់។

[១០:៥១:២០]

**ស៖** <លោកសាក្សី> នេះជាសំណួរចុងក្រោយរបស់ខ្ញុំ។ តើលោកធ្លាប់ធ្វើសំណើទៅស្រុកដើម្បីឲ្យគេ<ផ្តល់>ស្បៀងមក<ឲ្យ>ឃុំលោក<> នៅពេល<>ឃុំលោក<>ខ្វះស្បៀង<ដែរឬទេ>? លោកធ្លាប់ធ្វើសំណើហ្នឹងបែបហ្នឹង<ដែរឬទេ>?

**ឆ៖** បាទ អរគុណណាស់។ ពេលដែលវាខ្វះស្បៀង ឬខ្វះសម្លៀកបំពាក់សម្រាប់ប្រជាជន ខ្ញុំធ្លាប់ធ្វើស្បៀង -- ធ្លាប់ធ្វើរបាយការណ៍ សូមភ័យទោស ធ្លាប់ធ្វើរបាយការណ៍ទៅស្រុក។
បាទ សូមអរគុណ។

**ស៖** <>ជាទូទៅ តើលោកធ្លាប់បានទទួលបានសម្លៀកបំពាក់ ឬក៏ស្បៀង នៅពេលដែលលោកដាក់សំណើទៅដែរឬទេ? <>

**ឆ៖** បាទ កាលណាធ្វើរបាយការណ៍ទៅ វាមាន ប៉ុន្តែមកមិនមានជាសម្លៀកបំពាក់ទេ មកជាក្រណាត់។ ជាក្រណាត់ដុំៗហ្នឹងមានជាបន្តបន្ទាប់ ប៉ុន្តែឲ្យគ្រប់គ្រាន់នៅក្នុងឃុំតែម្តង មិនអាចគ្រប់គ្រាន់

បានទេ។

**សៈ** ចុះស្បៀង តើលោកមានធ្លាប់ទទួលស្បៀងដែលស្រុក<ផ្តល់ឲ្យដែរឬ>ទេ?

[១០:៤៣:១០]

**ឆៈ** បាទ ខាងសេដ្ឋកិច្ចបានទៅទទួលជាអង្ករអីបន្តិចបន្តួច ទៅតាមលទ្ធភាពដែលស្រុកផ្តល់មកមានជាបណ្តើរៗ។

**សៈ** តើហេតុអ្វីបានជាលោក<ត្រូវ>លាក់<ស្រូវ>អ៊ីចឹង បើនៅពេលដែល<>លោកស្នើសុំទៅស្រុក <គឺស្រុកឲ្យមកវិញដែលហ្នឹង>?

**ឆៈ** បាទ ខ្ញុំលាក់នេះ លាក់ដើម្បីបំពេញការខ្វះខាត ហើយកាលណាដូចជាអស់ស្បៀងនៅក្នុងឃុំទៅ ខ្ញុំស្នើទៅស្រុកដើម្បីជួយបន្ថែម ដើម្បីឲ្យប្រជាពលរដ្ឋ ប្រជាជនមានកម្លាំងក្នុងការធ្វើការងារហូបបានគ្រប់គ្រាន់។ អានេះជាបច្ចេកទេសរបស់ខ្ញុំផ្ទាល់ទេ។ បាទ សូមអរគុណ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ លោកសាក្សី ខ្ញុំសូមអរគុណ ខ្ញុំអស់សំណួរហើយ។

អរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ដែលដំបូងនេះគឺផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី នួន ជា ដែលមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

[១០:៤៥:០៤]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោកសាក្សី។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**សៈ** ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរលោក។ ខ្ញុំសូមអានឲ្យលោកស្តាប់នូវចម្លើយដែលលោកបានផ្តល់ឲ្យទៅអ្នកស៊ើបអង្កេតគឺ <D118/34> សំណួរ-<ចម្លើយ>ទី២០។ សំណួរបានសួរដូចតទៅនេះ៖ <"សៈ> តើ<>គេធ្វើការបោសសម្អាត<នៅឆ្នាំណា>? ហើយលោកបានឆ្លើយថា <ឆ.២០៖>

នៅពេលនោះ លេខាតំបន់១៣<ដំបូងគេនោះ>គឺតាសំ <>គេ<>ហៅ<ទៅរៀនសូត្រនៅ>ភ្នំខ្ពែង <ហើយបាត់រហូត> ជាមួយនឹងប្រធានគណៈឃុំពីរបីនាក់<ទៀត>។ ខ្ញុំ<គិត>ថា<ពួកនោះត្រូវគេបោសសម្អាតហើយ> ប៉ុន្តែខ្ញុំមិនដឹងថា គេយកទៅទីណានោះទេ។ គេគ្រាន់តែនិយាយថា គេហៅបុគ្គលនោះទៅរៀនសូត្រតែប៉ុណ្ណោះ ហើយខ្ញុំមិនដឹងថានៅឆ្នាំណានោះទេ។" ហើយនៅក្នុងឯកសារមួយទៀត E3/5521 នៅក្នុងសំណួរ-<ចម្លើយ>១១៩<>គេសួរថា <"ស>៖ តើ<លោកនៅចាំទេថា>អ្នកណាជាគណៈស្រុក? ហើយលោកនិយាយថា <ឆ៖> <ឈ្មោះ សោម (មិនដឹងថាគាត់ស្លាប់ហើយឬនៅទេ)> លោកមិនដឹងច្បាស់ថាអ្នកណាទេ លោកថាឈ្មោះ សោម ហើយក្រោយមកទៀតតាប្រាក់ ហើយនិងតារ៉ន។ ហើយលោកមិនដឹងថា គាត់ស្លាប់ឬក៏រស់នោះទេ ហើយក្រោយមកទៀត តាទិត្យ ស្រុកកំណើតនៅភូមិត្រពាំងធំ ស្រុកត្រាំកក់ ហើយក្រោយមកទៀត តា<កិត> ឡើងជាគណៈតំបន់។"

[១០:៤៦:៥៧]

លោកសាក្សី ខ្ញុំជាដំបូងចង់សួរថាឈ្មោះតាសោម នេះ នៅក្នុងចម្លើយដែលខ្ញុំទើបតែអាន គឺគេហៅឱ្យលោកទៅរៀននៅភ្នំខ្ពែង។ តើលោកដឹងដោយរបៀបណាអំពីព័ត៌មានទាំងអស់នេះ?

**លោក នុត នូវ៖**

**ឆ៖** បាទ សូមសូមអរគុណ។ ពេលគេហៅទៅរៀន គឺលិខិតចេញពីស្រុកឱ្យទៅរៀននៅភ្នំខ្ពែង កន្លែងសាលារបស់តំបន់ គឺមាន តសោម មានទទួលគ្រប់គ្រងនៅទីនោះ។ សូមអរគុណ។

**ស៖** ចុះភ្នំខ្ពែងហ្នឹងនៅកន្លែងណាដែរ?

**ឆ៖** ភ្នំខ្ពែងនៅខាងត្បូងទីរួមខេត្តតាកែវ នៅក្នុងស្រុកទ្រាំង ចម្ងាយស្មានប្រហែលជា ៣គីឡូម៉ែត្រពីទីរួមខេត្ត។

**ស៖** តើលោកដឹងថាគាត់ទទួលបានលិខិតពីស្រុក<>ហៅគាត់ទៅរៀនសូត្រហ្នឹង<>ដោយរបៀបណា?

**ឆ៖** ជំនាន់នោះដឹងដោយនីរសារយកលិខិតមកឱ្យតាមឃុំ។

**ស៖** នៅក្នុងចម្លើយរបស់លោក លោកនិយាយថា គាត់បាត់ខ្លួនជាមួយមេឃុំពីរបីនាក់ទៀត។ តើលោកដឹងថា តើមេឃុំពីរបីនាក់ទៀតហ្នឹង ជា<នរ>ណាដែរ?

**ឆ៖** ក្រោយពីបានប្រជុំចប់ គេធ្វើជាជីវទស្សន៍នៅក្នុងសាលាហ្នឹង។ អ៊ីចឹងតាមរយៈបាត់ខ្លួននេះកាលនោះស្រុកអង្គរជ័យ។ ស្រុកអង្គរជ័យហ្នឹងវានៅក្នុងខេត្តតាកែវ ជាស្រុកឈ្មោះស្រុក១០៦ ហើយ

មានការឃើញបាត់ខ្លួនហ្នឹងគេហៅខ្ញុំមិនស្គាល់ឈ្មោះទេ ប៉ុនថាខ្ញុំដឹងឃុំសំឡាញក៏មានបាត់ ឃុំម្រោមក៏មានបាត់ ឃុំអង្គរជ័យក៏មានបាត់ខ្លួនក្រោយមក។ ហ្នឹងមេឃុំ។

[១០:៥០:១៥]

**ស៖** តើលោកអាចប្រាប់<អង្គជំនុំជម្រះ>បានទេថា ហេតុអ្វីបានជាលោកគិតថាគាត់បាត់ខ្លួន?

**ឆ៖** បាត់ខ្លួននេះ ក្រោយមកពេលប្រជុំអត់ឃើញគាត់ ហើយឮគេនិយាយថាត្រូវចាប់ខ្លួនបញ្ជូនទៅរៀនសូត្រ។ មេឃុំប៉ុន្មានដែលខ្ញុំបានជម្រាបខាងលើ នេះជាការពិត។

**ស៖** តើលោកដឹងអំពីហេតុផលដែលគេចាប់ខ្លួន តាសោម ដែរឬទេ?

**ឆ៖** ខ្ញុំអត់បានដឹងទេ ព្រោះថ្នាក់តំបន់នោះ ហើយក៏មិនដឹងចាប់ ទើបតែឮថ្ងៃនេះថាចាប់តាសោម។

**ស៖** តើលោកឮអ្វី<ឲ្យប្រាកដ>នៅក្នុងតុលាការនេះ? <>

**ឆ៖** សូមជម្រាបថាឮថាចាប់ តាសោម ខ្ញុំអត់ដែលឮ។

**ស៖** ខ្ញុំគិតថាប្រហែលជាយើងយល់ច្រឡំគ្នាហើយមើលទៅ។ ខ្ញុំគិតថាលោកបាននិយាយនៅក្នុងកំណត់ហេតុ<នៃការ>ស្តាប់ចម្លើយ <ហើយឥឡូវនេះ លោកកំពុងនិយាយម្តងទៀត>។ ដូច្នេះប្រហែលជាមានការ<ច្រឡំ>នៅក្នុងការបកប្រែ ហើយ<។ តើគេចាប់តា សោម ដែរឬទេ? ប្រសិនបើគេចាប់ តើគេចាប់គាត់ដោយសារមូលហេតុអ្វី? ថាតើលោកដឹងដែរឬទេ>?

[១០:៥២:៣៣]

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ អត់ដឹងគេចាប់ខ្លួនគាត់ទេ។ ប៉ុន្តែស្រាប់តែឃើញបាត់ពីតំបន់១៣ បាត់តាសោម។ មិនដឹងដោយកាលនោះ គាត់មានថាមាន រោគា ព្យាធិ ទៅព្យាបាល ហើយបាត់រហូត។ក្រោយពីតាសោម បាត់ទៅ គេដាក់តាប្រាក់ ហើយតាប្រាក់ហ្នឹង ខ្ញុំជម្រាបឲ្យហើយ ដោយគេចាប់ខ្លួនបាត់តាប្រាក់ មកដាក់តារ៉ន ទៅទៀតនៅក្នុងតំបន់១៣ហ្នឹង។ តារ៉ន ហ្នឹងបានឡើងទៅសន្និបាតនៅភ្នំពេញត្រូវរទេះភ្លើងបុកបាក់ជើងទៅ ក៏បាត់តារ៉នទៅ។ ក្រោយមកគេដាក់ តាទិត្យ ក្នុងតំបន់ហ្នឹង តាទិត្យហ្នឹងក៏មិនទាន់បានយូរយារទេ មិនដឹងតាទិត្យហ្នឹងទៅកន្លែងណា ព្រោះខាងលើគេលាក់ការណ៍ គេអត់ប្រាប់ទេ ខាងឃុំ។ ក្រោយមកគេដាក់ <តាកិត> ទៀត។ បាទដាក់<តាកិត> ហ្នឹងគឺនៅជាប់ប្រហែលជាប្រមាណខែហ្នឹង ក៏អាចមានបានរំដោះទៅ។ បាទ សូមអរគុណ។

**ស៖** លោកសាក្សី តើលោកចាំដែរឬទេ ថានៅពេលណា<> តារ៉ន មកជំនួស តាប្រាក់?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ខ្ញុំមិនបានចាំឆ្នាំប្រាកដទេ គ្រាន់តែដឹង។

[១០:៥៤:៤១]

**ស៖** ក្នុងចម្លើយរបស់លោកៗឆ្លើយថា តាប្រាក់ ត្រូវ<>គេចាប់ខ្លួននៅក្នុងឆ្នាំ<១៩៧៧ ឬឆ្នាំ១៩៧៨>។ <តើខ្ញុំយល់ចម្លើយលោកត្រឹមត្រូវដែរឬទេ>ថា តារ៉ន ត្រូវបានគេចាប់ខ្លួនក្រោយតាប្រាក់ ប្រហែលជាក្នុងឆ្នាំ<១៩៧៧ ឬឆ្នាំ១៩៧៨>?

**ឆ៖** ខ្ញុំដូចជាមិនបានចាំប្រាកដទេ ប៉ុន្តែក្រែងថាដឹងថាគេចាប់ខ្លួន។

**ស៖** តើលោកដឹងដែរឬទេថា តាសោមគាត់មានទំនាក់ទំនងអីជាមួយ ជូ ជេតដែរទេ?

**ឆ៖** បាទ អរគុណ។ ថ្នាក់ខ្ពស់ខ្ញុំអត់ដែលបានដឹងទេ អត់ដែលបានដឹង ហើយក៏អត់ដែលឮដែរ។ បាទ សូមអរគុណ។

**ស៖** តើ<លោកដឹងទេថានរណាជា>លេខាភូមិភាគ<>បស្ចិម<>?

**ឆ៖** បាទហ្នឹងក៏ខ្ញុំមិនដែលស្គាល់ដែរ មិនបានដឹងឈ្មោះទៅទៀត។

**ស៖** ប្រសិនបើខ្ញុំនិយាយឈ្មោះ តាស៊ី លោកនឹកឃើញដែរឬទេ?

**ឆ៖** តាស៊ី មានឮគេនិយាយដែរ ប៉ុន្តែមិនដែលឃើញមុខមាត់របស់គាត់ គ្រាន់តែឮឈ្មោះថាគេហៅថាតាស៊ីៗ។

**ស៖** តើលោកធ្លាប់ឮថាតាស៊ី <>និងតាសោម មានទំនាក់ទំនងអីជាមួយគ្នាដែរឬទេ?

**ឆ៖** បាទ ខ្ញុំមិនបានដឹងទេ។

**ស៖** តើលោកអាចប្រាប់<អង្គជំនុំជម្រះបានយ៉ាងដូចម្តេចខ្លះអំពីមនុស្សម្នាក់ដែលមានឈ្មោះ> ថា តា<>គារ<?> តើលោកចាំអី<ខ្លះ>អំពី<គាត់>ហ្នឹង<>?

**ឆ៖** បាទ តាគារ ខ្ញុំស្គាល់ប្រាកដ។ តាគារហ្នឹងស្គាល់ដឹងប្រវត្តិរបស់គាត់ នៅឃុំជាមួយគ្នា។ បាទ ស្គាល់ប្រាកដណាស់។

[១០:៥៨:២៦]

**ស៖** តើលោកដឹងថាមានអីកើតឡើងចំពោះគាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរទេ?

**ឆ៖** ពីដើមគាត់ធ្វើជាលេខាស្រុកត្រាំកក់ ពីឆ្នាំ៧០។ ក្រោយរំដោះ គេដកគាត់ទៅកងចល័តតំបន់នៅឯអង្គរបុរី ហើយនៅកន្លែងណាទេ ប៉ុន្តែនៅម្តុំភ្នំបុរីហ្នឹង ឬនៅខាងត្បូងហ្នឹង។ បាទ ហើយក្រោយមកទៀត ខាងលើគេចាប់គាត់ទៅដាក់នៅភ្នំសន្លុង ប៉ុន្តែហេតុផលអីខ្ញុំមិនបានដឹងទេ។ នៅចុង

ក្រោយ គេបញ្ជូនគាត់មកនៅវិហារខ្ពស់។ ទីបញ្ចប់គឺបញ្ជូនគាត់ទៅភ្នំម្ដុំខាងត្បូងភ្នំពេញនេះ ភ្នំអីទេ មិនស្គាល់ឈ្មោះភ្លេចដូចជាភ្លេចភ្នំហ្នឹង ហើយស្រាប់បាត់ខ្លួនទៅ ពេលបែកហ្នឹង។

**ស៖** តើលោកដឹងទេថា តាគាវ គាត់មានទំនាក់ទំនងអ្វីជាមួយ តាស៊ី ឬក៏ ជូ ជេត ដែរ <ឬទេ>?<នោះជាមនុស្សតែមួយទេ។>

**ឆ៖** បាទ ខ្ញុំមិនបានដឹងទេ។

**ស៖** លោកសាក្សី យើងបាននិយាយអំពីកម្មាភិបាលមួយចំនួន ដែលលោកស្គាល់ ហើយលោកនិយាយថា ពួកគាត់មួយចំនួនត្រូវបានគេចាប់ខ្លួន។ តើលោកដឹងដែរឬទេ អំពីមូលហេតុអ្វីដែលគេចាប់ខ្លួនពួកគាត់<? តើមូលហេតុអ្វីបានជាគេដកអ្នកទាំងនោះចេញពីស្រុក ឬដកចេញពីតំបន់អ៊ីចឹង?>

**ឆ៖** កាលជំនាន់នោះ គេលាក់ការណ៍។ ខ្ញុំអត់បានដឹងទេនូវការងារហ្នឹង។

**ស៖** ខ្ញុំយល់អំពីបញ្ហានេះ ប៉ុន្តែលោកប្រហែលជាឮព័ត៌មានលម្អិត ឬក៏ដឹងព័ត៌មាននៅក្រោយឆ្នាំ ១៩៧៩ តើលោកមានដឹងព័ត៌មាន<អ្វីនៅក្រោយឆ្នាំ១៩៧៩ ដែរឬ>ទេ?

**ឆ៖** ព័ត៌មានផ្សេងៗក្រោយឆ្នាំ៧៩ មានឮបែបស្រពេចស្រពិលថា កម្មាភិបាលដែលចាប់ខ្លួនគឺត្រូវប៉ុល ពត កម្ទេច គឺបោសសម្អាតកម្ទេច សម្លាប់ បានសេចក្ដីថាសម្លាប់អស់ ព្រោះអត់ឃើញគាត់ទៅវិញ ដូចជារូប តាគាវ ផ្ទាល់។

[១១:០២:១៧]

**ស៖** លោកសាក្សី លោកអាចនិយាយឲ្យបានលម្អិតបន្តិចបានទេ អំពីជោគវាសនារបស់ សោម គាវ ហើយនិង តាប្រាក់<?> តើ<លោកគិតថាគេយក>ពួកគាត់<ទៅ>កម្ទេច<ដោយសារមូលហេតុអ្វី>?

**ឆ៖** រឿងហ្នឹង ខ្ញុំមិនបានដឹងថាយ៉ាងម៉េចទេ ប៉ុន្តែក្រោយមកបាត់ខ្លួន ក្រោយពីចាប់មកទៅបាត់ខ្លួន។ ដូចតាគាវ នៅឃុំជាមួយគ្នាហ្នឹង ឃើញទៅតែប្រពន្ធ និងកូន តែពីរនាក់ទេ ដែលទៅជាប់។ កូនតូចៗជាមួយប្រពន្ធរបស់គាត់។ ប៉ុន្តែខ្ញុំមិនបានដេញសួរគាត់ គ្រាន់តែឮគឺពិតប្រាកដថា ពិតជាគេសម្លាប់។

**ស៖** តើលោកធ្លាប់ឮព័ត៌មានអ្វីក្រោយឆ្នាំ<១៩៧៩> ដែល<បញ្ជាក់>ថា សោម គាវ <និង> តាប្រាក់ហ្នឹង គឺជា<ខ្សែរយៈ>របស់ ជូ ជេត ហៅតាស៊ី ហ្នឹងដែរឬទេ?

**ឆ៖** បាទ ក្រោយឆ្នាំ៧៩ ខ្ញុំអត់បានដឹងទេ ព្រោះខាងកងទ័ពវៀតណាមចាត់ខ្ញុំទៅមន្ទីរកែប្រែនៅ

កោះអណ្តែតហ្នឹង៦ឆ្នាំ ព្រោះនៅកន្លែងនោះ ហៅថាមន្ទីរកែប្រែ ង១៦៣។ មុនដំបូងវៀតណាម ក្រោយមកមានខ្មែរទៅទទួលខុសត្រូវនៅកន្លែងហ្នឹង គេបានស្គាល់ខ្ញុំ ខ្មែរធ្វើការហ្នឹង មានគ្នាគេក៏ឲ្យលិខិតសំណុំបែបបទផ្សេងៗមកជួបជុំប្រពន្ធកូនវិញនៅឆ្នាំ១៩៨៦ ប៉ុនមិនដឹងថ្ងៃទេ ដែលរួចពីមន្ទីរឃុំឃាំង ង១៦៣។ ហើយមកដល់នេះ មូលដ្ឋានវិញ គេឲ្យខ្ញុំធ្វើអនុភូមិសព្វថ្ងៃហ្នឹងជាបន្តបន្ទាប់មក ដោយថាយល់ថាខ្ញុំធ្វើការងារ។ កាលជំនាន់នោះ មិនល្អទាំងអស់ទេ ប៉ុនថាវាមានការល្អប្រហែលជា៦០ទៅ៧០ភាគរយ។ អ៊ីចឹងខាងគណ:ស្រុក គេចាត់តាំងឲ្យធ្វើជាអនុប្រធានភូមិអង្គរនាប។ ហើយក្រោយមកទៀតគេក៏ឲ្យខ្ញុំឈរបេក្ខជនក្រុមប្រឹក្សាឃុំ ជាប់ពីពេលនោះរហូតមកដល់សព្វថ្ងៃនេះ នៅធ្វើការងារជាក្រុមប្រឹក្សាឃុំត្រាំកក់រហូត។ សូមអរគុណ។

[១១:០៥:៣៨]

**ស៖** អ៊ីចឹង លោកចង់ផ្តល់សក្ខីកម្មថា ក្រោយឆ្នាំ<១៩៧៩> លោកត្រូវបានគេយកមករៀនសូត្រ ឬក៏<កសាងខ្លួន>ដោយវៀតណាមអស់រយ:ពេល៦ឆ្នាំ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទនេះពិតមែនហើយ។

**ស៖** លោកសាក្សី លោកនិយាយ<ដោយសង្ខេប>អំពីឈ្មោះ ភី ហើយ<ថា>បុគ្គលនេះ<ទទួលរង>គ្រោះថ្នាក់។ មុននេះ លោកផ្តល់ព័ត៌មានលម្អិតខ្លះដែរ ប៉ុន្តែឥឡូវនេះ ខ្ញុំចង់ឲ្យលោកនិយាយឲ្យលម្អិតបន្ថែម។ តើលោកចាំ<បានអ្វីខ្លះអំពី> ភី នោះដែរឬទេ?

**ឆ៖** ចំពោះឈ្មោះ ភី ខ្ញុំអត់បានដឹងអ្វីដែលកើតឡើងចំពោះរូបគាត់ទេ ព្រោះគាត់ធ្វើការនៅស្រុកផ្សេង ឃុំផ្សេងពីគ្នា។

[១១:០៧:០២]

**ស៖** តើលោកធ្លាប់ឮព័ត៌មានដែលគេនិយាយថា<ឈ្មោះ> ភី ត្រូវ<វៀតណាម>សម្លាប់នៅឆ្នាំ<១៩៧៩>ដែរឬទេ?

**ឆ៖** បាទអត់ដឹងទេ។

**ស៖** តើដឹងថា ភី <>មានតួនាទី<ជា>អ្វី<>នៅក្រាំងតាចាន់ ឬក៏មន្ទីរអប់រំកែប្រែ១០៥<ដែរឬទេ>?<>

**ឆ៖** បាទខ្ញុំអត់ដឹងទេ ដឹងតែគាត់ធ្វើគណ:ឃុំនៅស្រុក១០៧ ឃុំរកា ឬក៏ឃុំរនាមបាទ។ ខ្ញុំមិនដឹងច្បាស់។

**ស៖** លោកសាក្សី មានសាក្សីផ្សេងទៀតដែលមកផ្តល់សក្ខីកម្ម គាត់បាននិយាយថា ភី គឺជា <ថ្នាក់លើ>របស់ តាអាន់ ដែលនៅគ្រប់គ្រងក្រាំងតាចាន់។ តើលោកចាំអំពីបញ្ហានេះទេ?

**ឆ៖** បាទខ្ញុំអត់បានដឹងទេ ដឹងតែ តាអាន់ បាទ។ តាអាន់ ហ្នឹងឮគេនិយាយថា មេសន្តិសុខនៅក្រាំងតាចាន់។

[១១:០៨:៣៨]

**ស៖** តើលោកអាចប្រាប់ខ្ញុំបានទេ ថាតើ ភី គាត់<ទទួលគ្រោះថ្នាក់>អ្វីដែរ<>?

**ឆ៖** តាភី ខ្ញុំអត់បានដឹងជាប់ហេតុអីដែរ អត់បានដឹងទេ។

**ស៖** តើលោកនឹកឃើញទេថា គាត់ត្រូវឡានបុក ឬក៏រថភ្លើងបុក? តើលោកនឹកឃើញអំពីចំណុចនេះទេ?

**ឆ៖** បាទ តាភី គ្មានទេ អត់នឹកឃើញទេ។

**ស៖** សូមអរគុណសាក្សី។ ឥឡូវនេះខ្ញុំចង់បន្តទៅប្រធានបទថ្មី គឺនិយាយអំពី<ការហូបចុក>។ ខ្ញុំចង់ឲ្យលោកពិនិត្យមើលទៅលើចម្លើយលើ E3/5521 គឺសំណួរ-ចម្លើយ<ក>៤៨។ សំណួរ<របស់អ្នកស៊ើបអង្កេត>សួរថា៖ <"ស>៖តើគេយកអង្ករមកពីណាដែរ? ហើយលោកឆ្លើយថា <ឆ.៤៨>៖ខ្ញុំមិនដឹងទេ ប៉ុន្តែខ្ញុំដឹងថា មានជំនួយពីប្រទេសក្រៅ។" តើលោកអាចប្រាប់ឲ្យបានលម្អិតបន្តិចបានដែរឬទេ ថាតើជំនួយពីប្រទេសក្រៅហ្នឹងមកពីប្រទេសណាដែរ? ហើយតើមានជំនួយក្នុងបរិមាណ<>ប៉ុន្មានដែរលោកអាចប្រាប់អីបានលម្អិតបន្តិចបានទេ?

**ឆ៖** បាទ ក្រោយរំដោះឆ្នាំ១៩៧៥ ជំនួយជាអង្ករ ខ្ញុំដឹងថាខាងស្រុកគេហៅតាមឃុំនីមួយៗទៅយកមក ប៉ុន្តែមិនដឹងជំនួយពីប្រទេសណា ព្រោះខ្ញុំមិនបានដេញដោលដែរ ដឹងតែជំនួយពីប្រទេសក្រៅដែលបញ្ជូនមកជួយប្រជាជនកម្ពុជា ក្រោយសង្គ្រាម លន់ នល់។ បាទ សូមអរគុណ។

**ស៖** តើក្រោយមកលោកមានឮសួរថា មានជំនួយពីបរទេសពេលហ្នឹង មកពីប្រទេសណាទេ? តើអាចមកពីប្រទេសចិន ឬក៏អត់ទេ ឬក៏លោកមិនដឹងទេ?

**ឆ៖** បញ្ហានេះ ប្រហែលមកពីប្រទេសចិនបាទ ឬប្រទេសណាទៀតដោយខ្ញុំមិនបានច្បាស់។

[១១:១១:៣០]

**ស៖** តើលោកមាននៅចាំអំពី<>បរិមាណនៃជំនួយបរទេសដែលមកឃុំរបស់លោកទេ វាមកតិចតួច ឬក៏វាមកច្រើន? តើលោកអាចមានយោបល់<អ្វី>អំពីជំនួយបរទេសនេះទេ?

**ឆ៖** ខ្ញុំដូចជាមិនបានមានយោបល់អីទេ ជំនួយនេះមកហ្នឹងវាមិនអាចគ្រប់គ្រាន់ទេ។ វាមកជាបន្តបន្ទាប់ពិតហើយ ប៉ុន្តែមិនអាចគ្រប់គ្រាន់ទេ ក្នុងមួយពេលមកប្អូនដប់បាវប៉ុណ្ណឹង យកមកចែកប្រជាពលរដ្ឋនៅក្នុងឃុំ ប៉ុន្តែជាតួលេខប៉ុន្មានឲ្យពិតប្រាកដ គឺអត់បានដឹងទេ។

**ស៖** តើលោកមានចាំទេ តើ<លោកឃើញអង្ករហ្នឹងមកដំបូងដល់ឃុំរបស់លោកនៅពេលណា> ក្រោយថ្ងៃ១៧ <ខែមេសា ឆ្នាំ១៩៧៥ <>នោះ?

**ឆ៖** ខ្ញុំមិនបានចាំទេ ប៉ុន្តែឃើញអង្ករហ្នឹងខាងសេដ្ឋកិច្ចគេទៅដឹកជញ្ជូនយកមកដាក់ក្នុងឃុំចែកទៅតាមកងបាទ។

**ស៖** តើលោកចាំទេថា ជំនួយជាអង្ករ<មកពី>បរទេសហ្នឹងវាបានផ្តល់មកដល់ឃុំរបស់លោករហូតដល់ពេលណាដែរ<? តើវា>មកដល់ឆ្នាំ៧៦ ឬក៏រហូតដល់ ឆ្នាំ៧៧?

**ឆ៖** ជំនួយនេះអាចបានឆ្នាំ១៩៧៦ ហើយក្រោយពី៧៦គឺយើងបង្កបង្កើតផលនៅក្នុងឃុំនីមួយៗបានជាបណ្តើរៗ។

**ស៖** តើលោកចាំទេ តើវាមានតែអង្ករ<មួយមុខគត់>ដែល<គេ>ផ្តល់មកដល់ឃុំរបស់លោក ឬក៏វាមាន<ស្បៀង>អាហារផ្សេងទៀតដែលគេផ្តល់មកក្នុងទម្រង់ជាជំនួយបរទេស<នៅក្រោយពេលរំដោះនោះ>?

[១១:១៤:២៤]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបសាក្សី!

**លោក នុត នូវ៖**

**ឆ៖** ជំនួយក្រៅពីអង្ករដូចជាគ្មានអីទេ។ បើមានៗជាក្រណាត់យកមកសម្រាប់កាត់ខោអាវជូនប្រជាជន ហើយថ្នាំពេទ្យហ្នឹងតិចតួច មានជាបណ្តើរៗដែរ ប៉ុន្តែជាប្រមាណៗឲ្យប្រាកដ មិនបានចាំទេ ឃើញមកវាមិនជាញឹកញាប់ទេ។ ហ្នឹងសូមជម្រាបដោយស្មោះត្រង់ យូរៗម្តងៗ។ សូមអរគុណ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** <>តាមការចងចាំរបស់លោក<ថាតើ>នៅពេលណាមួយក្រោយថ្ងៃរំដោះ ស្ថានភាពចំណីអាហារស្បៀងអាហារមានលក្ខណៈប្រសើរ <គឺថាមានស្បៀងច្រើនសម្រាប់ចែកឲ្យប្រជាជនដែរឬ>ទេ? <ឧទាហរណ៍ថា> បើយើងប្រៀបធៀបទៅនឹង<ការបង្កបង្កើនផល និងការផ្គត់ផ្គង់ស្បៀង

អាហាររវាងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦ តើលោកអាចប្រៀបធៀបនៅក្នុងឃុំរបស់លោកបានដែរឬទេ>?

**ឆ៖** បាទ អរគុណណាស់សំណួរនេះ។ ស្ថានភាពដោះស្រាយជីវភាពក្នុងឃុំរបស់ខ្ញុំមិនអាចគ្រប់គ្រាន់ទេ ព្រោះម៉្យាងការធ្វើស្រូវហ្នឹងមិនបានផលឲ្យបរិបូរណ៍។ អ៊ីចឹងឃុំខាងលើៗ ជំនាន់នោះគេធ្វើបាន។ អ៊ីចឹងឃុំដែលខ្វះស្នើទៅខាងស្រុកៗគេឲ្យទៅយកឃុំនេះឃុំនោះប៉ុន្មានៗអ៊ីចឹងមក ដឹកយកមកដោះស្រាយជូនប្រជាជន ហើយការហូបចុកគឺយកមកពេលព្រឹកបបរទេ ល្ងាចហ្នឹងមានការដាំខ្លះ ប៉ុន្តែការហូបមិនគ្រប់គ្រាន់ពិតប្រាកដណាស់។ បាទ សូមជម្រាបប៉ុណ្ណឹង។

[១១:១៦:៥៣]

**ស៖** តាមការចងចាំរបស់លោកនៅពេលមួយនៅចន្លោះពីឆ្នាំ១៩៧៥ ទៅដល់ <ឆ្នាំ១៩៧៩> មានពេលណាមួយដែលស្ថានភាព<ស្បៀងអាហារ>មានភាពគ្រប់គ្រាន់ ឬក៏និយាយថា<លែងមានការខ្វះខាតស្បៀង>អាហារ<ទៀតហើយដែរឬទេ>?

**ឆ៖** ការពិតណាស់ ការហូបគ្រប់គ្រាន់ ដូចជាពិបាកណាស់ក្នុងការហូបហ្នឹង។ ពេលគឺមិនទាន់គ្រប់គ្រាន់នៅឡើយទេ គ្រាន់តែមានហៅស្រូវអង្ករ បន្លែបង្ការអី យើងចាត់តាំងកម្លាំងរៀបចំដាំម្ហូបអាហារ គឺយើងរៀបចំចិញ្ចឹមជ្រូក ចិញ្ចឹមមាន់ អ្នកសេដ្ឋកិច្ចទៅរកត្រី យកមកដោះស្រាយបានជាបន្តបន្ទាប់។ ដោយនៅឃុំខ្ញុំៗចុះប្រឡូកផ្ទាល់ ១០ថ្ងៃខ្ញុំកាប់គោ កាប់ជ្រូក ជូនប្រជាជនហូបម្តងគ្រប់សហ-ករណ៍។ ហើយកាប់នេះគឺថ្ងៃណាគោគឺគោតែម្តង មួយពេលហ្នឹងឲ្យគោសុទ្ធ គ្មានគោលាយបន្លែទេ បើថ្ងៃណាកាប់ជ្រូកគឺជ្រូកសុទ្ធ ដោយនៅក្នុងឃុំរបស់ខ្ញុំមានរៀបចំអ្នកចិញ្ចឹមជ្រូក ចិញ្ចឹមមាន់។ មិនជាច្រើន ក៏បានអាចដោះស្រាយមួយពេលៗអ៊ីចឹងដែរ។ បាទ សូមអរគុណ។

[១១:១៨:៤៩]

**ស៖** លោកសាក្សី តើនេះជាការចងចាំរបស់លោកឬ ដែលថាថ្នាក់លើបាន<>ខិតខំប្រឹងប្រែងដើម្បីធ្វើឲ្យស្ថានភាព<ស្បៀង>នៅឃុំរបស់លោក<ឲ្យ>មានភាពប្រសើរឡើងដែរទេ?

**ឆ៖** ថ្នាក់លើគេមានណែនាំជាបន្តបន្ទាប់ថាដោះស្រាយជូនប្រជាជនហូបឲ្យគ្រប់គ្រាន់ ហើយបើដោះស្រាយជូនប្រជាជនហូបមិនគ្រប់គ្រាន់ គណៈឃុំ ឬប្រធានឃុំហ្នឹងគឺមានបញ្ហា។ អ៊ីចឹងខ្ញុំខ្លាចគេប្រឹងប្រែងអ៊ីចឹងទៅ។ ខ្លាចគេចាប់ គេចងដែរ ព្រោះការចាប់ហ្នឹង វាមានជាបណ្តើរៗ ការដកពីនេះទៅនោះ ពីនោះទៅនោះមានបណ្តើរៗ។ ដូចខ្ញុំដកពីលាយបូរ មកស្រែរនោង ពីស្រែរនោងមកអង្គតាសោមរឹតតែព្រួយដែរ។ ការដកនេះមិនដឹងបញ្ហាអី ខ្ញុំមិនបានដឹង។ សូមអរគុណ។

**ស៖** លោកសាក្សី នៅក្នុងចម្លើយរបស់លោកជូនសហចៅក្រមស៊ើបអង្កេតគឺ E3/5521 ត្រង់ <សំណួរ>-ចម្លើយលេខ១00៖ <"ស>៖ តើមានប្រជាជនស្លាប់ដោយសារការអត់អាហារដែរទេ? <ហើយលោកបានឆ្លើយថា>៖ គ្មាន<នរ>ណាម្នាក់ស្លាប់ដោយអត់អាហារទេ។" សំណួររបស់ខ្ញុំថាតើនេះជាចម្លើយរបស់លោកដែល<រាប់បញ្ចូលទាំង>រយៈពេល<លំបាក គឺឆ្នាំ១៩៧៥ អាចដល់ឆ្នាំ១៩៧៦ ថាគ្មាននរណាម្នាក់ស្លាប់ដោយអត់ឃ្លាន> អ៊ីចឹង<មែន>ទេ?

**ឆ៖** ខ្ញុំបានថាដូច្នោះមែន ថាការស្លាប់នោះ មានស្លាប់ដោយជំងឺ។ ជំងឺនេះ គាត់ឈឺដោយប្រជាពលរដ្ឋមួយចំនួន គាត់មិនមាន ហៅថាស្ទាត់ជំនាញក្នុងការងារពលកម្ម ដូចអស់ប្រជាពលរដ្ឋដែលអញ្ជើញទៅពីក្រុងផ្សេងៗ អ៊ីចឹងមានការឈឺ ម្យ៉ាងដោយស្បៀងមិនគ្រប់គ្រាន់ មានជំងឺជាបន្តបន្ទាប់ ជាគ្រុនក្តៅ រងាហ្នឹង។

[១១:២១:៣១]

**ស៖** លោកសាក្សី ខ្ញុំនឹងត្រឡប់ចូលមកប្រធានបទនេះវិញ ប៉ុន្តែដើម្បីយល់ឲ្យកាន់តែច្បាស់ ថាតើ<ចម្លើយរបស់លោកតាមការ>ចងចាំរបស់លោក នៅក្នុងឃុំរបស់លោកពិតជាមិនមាន<នរណាម្នាក់>ស្លាប់ដោយការអត់អាហារមែនឬ ចន្លោះពីឆ្នាំ១៩៧៥ ទៅដល់<ឆ្នាំ១៩៧៦>?

**ឆ៖** បាទ ការពិតណាស់ គឺស្លាប់នេះ ស្លាប់ដោយជំងឺ ដូចខ្ញុំបានជម្រាបហើយ មកពីអត់អាហារក៏យ៉ាងម៉េច អាហារមិនគ្រប់គ្រាន់ ឬយ៉ាងម៉េច ប៉ុនមានជំងឺទៅ វាមានស្លាប់ជាបណ្តើរៗអ៊ីចឹង។

**ស៖** លោកសាក្សី <ខ្ញុំគិតថាលោកក៏យល់ដូចខ្ញុំដែរថាបច្ចុប្បន្ននេះ>នៅក្នុងប្រទេសកម្ពុជា <> ក៏ដូចជាប្រទេស<នានា>នៅលើពិភពលោកគឺថាមាន<មនុស្ស>ស្លាប់ដោយសារជំងឺតម្កាត់<ផ្សេងៗ។ ដូច្នេះនៅក្នុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦ ក៏មានមនុស្សស្លាប់ដោយសារជំងឺដែរ>។ សំណួររបស់ខ្ញុំសួរដូចតទៅនេះ តើលោកអាច<ធ្វើយ៉ាងណាដើម្បី>បង្ហាញឲ្យឃើញថា<>ស្ថានភាពរស់នៅ និង<កង្វះ> ចំណីអាហារ <>និង<ក្រោយមកមនុស្សឈឺនេះមានទំនាក់ទំនងគ្នាយ៉ាងដូចម្តេច>?

**ឆ៖** បាទ ដោយមានការស្លាប់ដោយជំងឺនេះ ដោយម្យ៉ាងប្រជាជនធ្វើការងារលើសកម្លាំង បាក់កម្លាំង ហូបមិនឆ្អែត។ អ៊ីចឹងទៅបណ្តាលឲ្យមានជំងឺប្រចាំកាយ។ បាទ សូមអរគុណ។

**ស៖** ខ្ញុំយល់ហើយលោកសាក្សី <ប៉ុន្តែ >លោក<អាចឯកភាព>ជាមួយខ្ញុំ<ថាមនុស្ស>ស្លាប់ដោយសារតែអាយុហ្នឹងចាស់ <ឬក៏>ដោយសារតែជំងឺ។ សំណួរខ្ញុំចំពោះលោក ថាក្នុងនាមលោកជាមេឃុំ តើលោកអាចពិចារណា<> ថាតើមាន<ផលប៉ះពាល់អ្វីខ្លះរវាង>ក្នុងស្ថានភាពរស់នៅ <ឬក៏

ស្ថានភាពការងារ> និងការស្លាប់ជាបន្តបន្ទាប់របស់ប្រជាជន<>?

[១១:២៤:១២]

**ឆ៖** បញ្ហានេះខ្ញុំដូចជាមិនបានយល់អំពីមូលហេតុទេ។ វាមូលហេតុដូចបានជម្រាបអង្គសវនាការរួចហើយ ដោយធ្វើការលើសកម្លាំង ស្បៀងមិនគ្រប់គ្រាន់ ទឹកន្លែងសម្រាកមិនល្អ វាអាចបណ្តាលឱ្យមានជំងឺ ហើយម្យ៉ាងដោយអ្នកចាស់ជរាហ្នឹងវាឆាប់ មានជំងឺស្លាប់ជាបន្តបន្ទាប់។

**ស៖** <នេះហើយជាសំណួររបស់ខ្ញុំ។> ខ្ញុំយល់លោកមិនមែនជាអ្នកជំនាញ<ប្រជាសាស្ត្រ>ទេ ក៏ប៉ុន្តែតើលោកអាចផ្តល់ព័ត៌មានជូនអង្គជំនុំជម្រះ ថាតើលោកមានការដឹង<ទេថា>ការស្លាប់<របស់ប្រជាជននៅក្នុងឃុំរបស់លោក>ដោយសារ<មូលហេតុអ្វី>ដែរ<ឬ>ទេ? <តើលោកធ្លាប់ពិភាក្សាជាមួយកម្មាភិបាល>មន្ទីរពេទ្យ ឬក៏<ជាមួយអាជ្ញាធរនានា>ពាក់ព័ន្ធទៅនឹង<ជំងឺ និង>ការស្លាប់<របស់>ប្រជាជន<>ដែរ<ឬ>ទេ?

**ឆ៖** បញ្ហានេះខ្ញុំមិនបានដឹងទេ។

**ស៖** <អរគុណលោកសាក្សី។> ខ្ញុំសូមចូលទៅប្រធានបទមួយទៀត គឺសំណួរចម្លើយរបស់លោក គឺនៅក្នុងឯកសារដដែល E3/5521 សំណួរចម្លើយ៣១ <អ្នកស៊ើបអង្កេត>សួរដូចតទៅ៖ <"ស>៖ នៅក្នុងភូមិរបស់លោក តើមានគេហៅប្រជាជនទៅរៀនសូត្រហ្នឹងប៉ុន្មាននាក់? ចម្លើយរបស់លោកថា <ឆ.៣១>៖ ខ្ញុំមិនដឹងហៅប៉ុន្មានទេ <ព្រោះថានេះជារឿងសម្ងាត់។> ហើយសម្រាប់<មនុស្ស>ដែលគេហៅទៅរៀនសូត្រគឺមិនដែលឃើញត្រឡប់<>មកវិញទេ។" តើ<ពាក្យ "វាជារឿងសម្ងាត់" លោកចង់មានន័យថាយ៉ាងដូចម្តេចដែរ? តើ>លោកអាចបញ្ជាក់អំពីចំណុចនេះបានទេ?

[១១:២៦:៤២]

**ឆ៖** បាទអរគុណ។ ចំណុចនេះ ខ្ញុំមិនអាចបញ្ជាក់បានប្រហែលជាប៉ុន្មានៗតួលេខឱ្យពិតប្រាកដទេ ហើយការបញ្ជូនហ្នឹងចេះតែបាត់មិនឃើញមក។ កាលនោះខ្លួនខ្ញុំផ្ទាល់ក៏ដឹងថាគេហៅទៅរៀនសូត្រទៅកែប្រែដែរ ប៉ុនមិនដឹងគេយកទៅសម្លាប់ចោលគឺអត់បានជ្រាបទេ។ នេះសូមជម្រាបដោយស្មោះត្រង់ ប៉ុន្តែក្រោយមក៧៩មក បានទៅកន្លែងក្រាំតាចាន់ហ្នឹងឃើញគួរឱ្យតក់ស្លុត ហើយគួរឱ្យសោកស្តាយ។ នេះជាការពិត។

**ស៖** លោកសាក្សី តើ<>លោក<ទើបតែថ្លោយមាត់ថា>ត្រូវបាន<គេហៅឱ្យទៅ>រៀនសូត្រក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ<មែនដែរឬទេ>?

**ឆ៖** បញ្ហានេះដូចខ្ញុំបានជម្រាបហើយ ជំនាន់ខ្ញុំឡើងធ្វើមេឃុំ ប្រធានឃុំឆ្នាំ៧៨ហ្នឹង ខ្ញុំអត់ដែលមានបញ្ជូនប្រជាជនឱ្យទៅរៀនសូត្រទេ ប៉ុនពីមុនមក គេធ្វើពីមុនមក គេមានបញ្ជូនពិតប្រាកដមែន។ ហើយចំពោះតួនាទីរបស់ខ្ញុំអត់ដែរទេ។

**ស៖** ប្រហែលជាខ្ញុំយល់ចម្លើយរបស់លោកមិនច្បាស់ទេ។ ខ្ញុំ<គិត>ថាខ្លួនលោកផ្ទាល់ហ្នឹងក៏ធ្លាប់គេបញ្ជូនឲ្យទៅរៀនសូត្រដែរ។ <តាមពិតទៅវាមិនមែនអ៊ីចឹងទេ។>

**ឆ៖** ការណ៍ចំពោះខ្លួនខ្ញុំផ្ទាល់ គេឲ្យទៅរៀន ពិតហើយ ប៉ុន្តែរៀនជាឯកសារ ដើម្បីយកមករៀបចំនៅក្នុងឃុំ។ ឧទាហរណ៍ធ្វើស្រែឲ្យបានសម្រេច ដើម្បីដោះស្រាយជូនប្រជាជនពលរដ្ឋប្រជាជនយើងហ្នឹង គឺមានគេហៅទៅរៀនដែរ រូបខ្លួនខ្ញុំផ្ទាល់។

[១១:២៩:១៥]

**ស៖** ដូច្នេះ<>ក្រោយពីលោកបានចូល<>វគ្គរៀនសូត្រ លោកត្រឡប់មក<ធ្វើការងារ>វិញ តើលោក<ដឹងថាមនុស្សដទៃទទួលបាន>បទពិសោធន៍<យ៉ាងដូចម្តេចបន្ទាប់ពីចូលវគ្គរៀនសូត្រ ហើយ>ត្រឡប់មកក្នុងឃុំ<>វិញ<ដែរឬ>ទេ?

**ឆ៖** ក្រោយពីខ្ញុំរៀនសូត្រហ្នឹង ប្រជាពលរដ្ឋដែលទៅរៀនសូត្រហ្នឹង ដែលគេយកទៅហ្នឹងតែម្តង គឺមិនដែលមកទេ ប៉ុនការរៀនសូត្ររបស់ខ្ញុំ គឺរៀនសូត្រដូចខ្ញុំបានជម្រាបហើយ ធ្វើយ៉ាងម៉េចដោះស្រាយប្រជាជននៅក្នុងមូលដ្ឋានរបស់ខ្លួនឱ្យបាន បាទកុំឲ្យមានខ្វះស្បៀង ដោះស្រាយជីវភាពឲ្យប្រជាពលរដ្ឋហូបឲ្យបានគ្រប់គ្រាន់។ ខ្ញុំគិតតែពីជំនាញខាងហ្នឹងទេ។ បាទ ហើយអត់ដូចបានជម្រាបថា ខ្ញុំមិនដែលបញ្ជូនទៅទេក្នុងដំណាក់កាលដែលខ្ញុំធ្វើជាមេឃុំ។

**ស៖** ខ្ញុំសូមសួរលោកបន្ថែមអំពី<ប្រយោគ>ថា "<មិនដែលឃើញពួកគេ>ត្រឡប់មកវិញទេ" ។ តើ<ប្រយោគ "មិនដែលឃើញពួកគេត្រឡប់មកវិញទេ"> លោកចង់<មានន័យ>ថាលោក<មិន>ដឹង<ថាមានអ្វីកើតឡើងចំពោះពួកគេនោះ មែនដែរឬ>ទេ?

[១១:៣១:០១]

**ឆ៖** បាទ ពិតជាមិនឃើញមកវិញ។

**ស៖** <ប៉ុន្តែនៅ>ពេលលោកនិយាយ<ដូច្នោះ> តើលោកមាន<ន័យថាលោក>ដឹងថាមានរឿងអ្វីកើតឡើងចំពោះអ្នកទាំង<នោះ មែនដែរឬ>ទេ?

**ឆ៖** បាទ ខ្ញុំមិនបានដឹងថាមានរឿងអ្វីកើតឡើងទេ។

**ស៖** ដូច្នេះតាមបទពិសោធន៍របស់លោក <តើ>អាច<ទេ>ថាអ្នកទាំងនេះត្រូវបានគេបញ្ជូនទៅឃុំផ្សេងទៀត ឬក៏ស្រុកផ្សេងទៀតនៅក្នុង<>ផ្ទៃប្រទេស<ដែរឬ>ទេ?

**ឆ៖** បញ្ហាហ្នឹងខ្ញុំក៏មិនបានដឹងដែរ បាទអត់បានដឹងទេ ព្រោះជាលាក់ការណ៍របស់គេ ខ្ញុំមិនបានដឹង ប៉ុន្តែកាលណាគេយកទៅហើយ អាចថាយកទៅរៀនសូត្រៗហើយដឹងថាគេយកទៅសម្លាប់ហ្នឹងគឺកាលនោះ គេលាក់ការណ៍មិនបានដឹង ព្រោះគេលាក់ការណ៍ល្អណាស់ អីក៏គេមិននិយាយប្រាប់យើងទេ ទោះជាយើងជាមេឃុំហ្នឹងក៏មិនអាចដឹងបានប៉ុន្តែដឹងថាគេយកទៅរៀនសូត្រ ហើយឃើញចេះតែបាត់ទៅ។ សូមជម្រាបដោយស្មោះត្រង់អ៊ីចឹង។

**ស៖** តើវាត្រឹមត្រូវទេ ដែលថាលោក<>និយាយថា <> "មិនដែលឃើញពួកគេត្រឡប់មកវិញ<ទេ" គឺលោកគ្រាន់តែស្មានៗប៉ុណ្ណោះថា ពួកគេត្រូវបានសម្លាប់ចោលហើយ>?

[១១:៣៣:០០]

**ឆ៖** ការណ៍ហ្នឹងបើមិនឃើញមកវិញអ៊ីចឹងទៅ ការចាប់អារម្មណ៍របស់ខ្ញុំទេ ប្រហែលជាគេសម្លាប់ចោលពិតប្រាកដមែន បាទ។

**ស៖** <អ៊ីចឹង តើមានតែលោកទេដែលគេលើកលែង?> លោកសាក្សី ខ្ញុំសូមចូលទៅនិយាយអំពីក្រាំងតាចាន់។ លោកនិយាយថាលោកមិនដែល<ឃើញ លោកមិនដែលដឹងថាមានមន្ទីរអប់រំនេះទេ។ តើត្រឹមត្រូវទេទាល់តែក្រោយឆ្នាំ១៩៧៩ ទើបលោកបានដឹង>?

**ឆ៖** បាទ ការពិតណាស់។ កាលជំនាន់នោះ ចំពោះក្រាំងតាចាន់ ខ្ញុំស្គាល់ ហើយឮគេនិយាយថាមន្ទីរសន្តិសុខក្រាំងតាចាន់ មិនបានដឹងជាកន្លែងសម្លាប់មនុស្សទេ។ លុះដល់ខ្ញុំចេញពីរៀនសូត្រនៅង១២៣ ទៅគេហៅទៅធ្វើបុណ្យនៅក្រាំងតាចាន់ បានឃើញ ភ្ញាក់ព្រើតតែម្តងបាទ។ អានេះជាការពិត។

**ស៖** ដូច្នេះចម្លើយរបស់លោកគឺថា នៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ លោកដឹងថាមានមន្ទីរអប់រំសម្រាប់ស្រុក១០៥ ប៉ុន្តែលោកដឹងថាមានគេសម្លាប់មនុស្ស<ទេ ទើបតែ>ដល់<>ក្រោយឆ្នាំ១៩៧៩ ទើបលោកដឹង។ អ៊ីចឹងទេ?

[១១:៣៥:០១]

**ឆ៖** បាទ ក្រោយ៧៩ ខ្ញុំឃើញ បានដឹងពិតប្រាកដ ហើយក៏មានកំហឹង។ ដូចខ្ញុំបានជម្រាបពីដើមមកហើយ ចំពោះខ្ញុំហ្នឹងគេចាប់ប្អូនមួយទៅផង ប្អូនស្រីទេ ហើយកូនប្រុសរបស់ខ្ញុំទីស្រឡាញ់បាត់

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មួយដែរ។ ប៉ុន្តែមិនដឹង គេយកទៅទីកន្លែងណា បាត់រហូតទាល់បច្ចុប្បន្ន។ នេះគួរឲ្យឈឺចាប់ ហើយចងចាំជាទីបំផុត។ សូមអរគុណ។

**ស៖** លោកប្រធាន ខ្ញុំ<>សួរសំណួរចុងក្រោយទៅលើប្រធានបទនេះ។ តើត្រឹមត្រូវទេលោកសាក្សី ថាលោកបានដឹងក្រាំងតាចាន់<អាចជាកន្លែង>សម្លាប់មនុស្ស <នៅក្រោយពេលដែលវៀត-ណាមយកលោកទៅអប់រំអស់រយៈពេល៦ឆ្នាំនោះ>?

**ឆ៖** ខ្ញុំទៅបុណ្យនៅក្រាំងតាចាន់ហ្នឹងបានឃើញជាក់ស្ដែងបាទ។ ក្រោយខ្ញុំរួចពីមន្ទីរកែប្រែង១៦៣ នៅកោះអណ្ដែត ខ្ញុំទៅធ្វើជាអនុភូមិ គេហៅទៅក្រាំងតាចាន់ហ្នឹង ដើម្បីចូលរួមក្នុងពិធីបុណ្យបានឃើញពិតប្រាកដ។

[១១:៣៦:៤៤]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅរហូតដល់ម៉ោងមួយកន្លះថ្ងៃរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការបន្តសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាកថ្ងៃត្រង់ ហើយនឹងឲ្យអញ្ជើញគាត់ រួមនិងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងមួយ សាមសិបនាទី រសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅបន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយ សាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោមឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៧ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទអង្គជំនុំជម្រះ ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី។ ដំបូងនេះ គឺមេធាវីការពារក្តីលោក នួន ជា។ ហើយសូមជម្រាបថា មេធាវីការពារក្តីទាំងពីរក្រុមមានពេលវេលាសវនាការនៅរសៀលនេះនៅក្នុងការស្តាប់សាក្សីរូបនេះ។ បាទសូមអញ្ជើញ!

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។

**សួរដោយលោក វិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី មុនពេលដែលយើងឈប់សម្រាក យើងបាននិយាយអំពីចម្លើយដែលលោកបានផ្តល់។ ហើយខ្ញុំនឹងបន្តពីចំណុចទាំងអស់នេះ ដែលខ្ញុំសូមធ្វើការអានទូវចម្លើយមួយទៀតដែលលោកបានផ្តល់ទៅអ្នកស៊ើបអង្កេត គឺឯកសារ E3/5521 គឺសំណួរ១២៤ ហើយអ្នក<ស៊ើបអង្កេត>បានសួរ<លោក>ដូចតទៅនេះ៖ <"ស>៖ អស់រយៈពេល៣ឆ្នាំ តើលោកបានឃើញការចាប់ខ្លួនមនុស្សដែរឬទេ? <ឆ.១២៤>៖ <>ការចាប់ចងជាការលាក់ការសម្ងាត់របស់គេ ខ្ញុំមិនបានឃើញទេ។" ដូច្នេះខ្ញុំចង់សួរលោកថាតើលោកអាចពន្យល់បន្ថែមបន្តិចទៅលើសំណួរនេះ ថាតើលោកពិតជាមិនដែលបានឃើញការចាប់ចងមនុស្ស<សោះ>មែនដែរឬទេ?

[១៣:៣៥:៤៣]

**លោក នុត នូវ៖**

**ឆ៖** បាទអរគុណណាស់សំណួរនេះ ខ្ញុំបានឆ្លើយពិតប្រាកដថាមិនដែលបានឃើញទេ។ គេចាប់នេះ របៀបគេចាប់គេមកយប់ បាទគេមកយប់តាមរបាយការណ៍រួចរាល់ហើយ។ អ៊ីចឹងគេបានមកទាក់ទងជាមួយឈ្លប គេហៅមនុស្សទៅពេលយប់ស្ងាត់។បានខ្ញុំមិនបានឃើញ សូមអរគុណ។

**ស៖** តើលោកដឹងថា មូលហេតុអ្វីទើបគេធ្វើឡើង<ដោយស្ងៀមស្ងាត់បែបនេះ? ហើយតើមូលហេតុអ្វីបាន>គេធ្វើការចាប់ខ្លួននៅពេលយប់<ដូច្នេះ>?

**ឆ៖** តាមខ្ញុំយល់ ហើយដឹងអាចថា គេចាប់ពេលយប់នេះ ដើម្បីកុំឲ្យវាដឹងដល់ប្រជាជនទូទៅអាចជ្រាបច្បាស់ពីគេចាប់មនុស្សទៅ។

**ស៖** លោកសាក្សី តើលោកដឹងថាមានភាពខុសគ្នាយ៉ាងណានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

រវាង<"កំហុសតូចតាច"> និង<"កំហុសធ្ងន់ធ្ងរ">? តើវាមានភាពខុសគ្នាយ៉ាងដូចម្ដេចដែរ បើតាមដែលលោកដឹង?

[១៣:៣៧:២៥]

**ឆ៖** បញ្ហានេះ ខ្ញុំមិនអាចសន្និដ្ឋានបានថា ខុសគ្នាយ៉ាងម៉េចយ៉ាងម៉ាទេ ព្រោះខ្ញុំមិនយល់អំពីការវិនិច្ឆ័យលើបញ្ហានេះ។

**ស៖** ក្នុងពេលដែលលោក<ធ្វើជាមេ>ឃុំញ៉ែងញ៉ង<> តើ<មិនមានមនុស្ស>លួចដូង ឬក៏<លួចដំឡូងទេឬ>?

**ឆ៖** កាលខ្ញុំនៅឃុំញ៉ែងញ៉ង មិនមានជាមេឃុំទេ ជាមន្ទីរ។ អ៊ីចឹងនៅក្នុងដែនមន្ទីរសេដ្ឋកិច្ច អត់ដែលឃើញទេ មានការលួចដូង លួចអី អត់មានទេ។

**ស៖** តើ<លោក>ធ្លាប់ឮ<គេ>ថា<មនុស្ស>នៅក្នុងឃុំរបស់លោក ត្រូវបានគេចោទ<>ថាលួច<របស់របរ>ដោយសារតែពួកគាត់ស្រេកឃ្លានដែរឬទេ?

**ឆ៖** បញ្ហានេះ ខ្ញុំក៏មិនដែលបានឃើញ បានឮដែរ។

[១៣:៣៩:១៨]

**ស៖** ប្រធានបទមួយទៀត ដែលយើងបាននិយាយរួចមកហើយ ហើយបានបញ្ចាក់រួចទៅហើយ គឺទាក់ទងទៅនឹងការរៀនសូត្រ។ ឥឡូវនេះ ខ្ញុំមានសំណួរមួយចំនួនដែលខ្ញុំចង់សួរលោក<បន្តពីសំណួរមុនពេលសម្រាកនោះ>។ តើលោកដឹងអំពីករណីដែលមនុស្សមួយចំនួនត្រូវបានគេយកទៅរៀនសូត្រជាច្រើនដងដែរឬទេ? គឺខ្ញុំចង់និយាយពីមនុស្សដែលគេបញ្ជូនទៅរៀនសូត្រ ត្រឡប់មកវិញ ហើយគេបញ្ជូនទៅមួយសាទៀត ហើយត្រឡប់មកវិញ។ <លោកប្រហែលបានឆ្លើយសំណួរនេះរួចហើយ ក៏ប៉ុន្តែ>ខ្ញុំចង់ដឹង<>តាមបទពិសោធន៍របស់លោក តើលោកធ្លាប់ឮអំពីមនុស្សដែលត្រូវបានគេបញ្ជូនទៅរៀនសូត្រជាច្រើនដងដែរឬទេ?

**ឆ៖** សូមជម្រាបថា ការបញ្ជូនមនុស្សទៅរៀនសូត្រច្រើនដង ដូចមិនដែលឃើញមានទេ ហើយក៏មិនបានដឹងដែរ ឃើញតែចាប់យកទៅរៀនសូត្រហ្នឹង ថាយកទៅរៀនសូត្រហ្នឹង បាត់ហ្នឹង អាហ្នឹងធ្លាប់ឮធ្លាប់ដឹង។

[១៣:៤០:៣៥]

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរលោកទៅលើប្រធានបទមួយផ្សេងទៀត។ នោះគឺជាចម្លើយរបស់

លោក E3/5521 គឺលោកឆ្លើយទៅនឹងសំណួរ២៥ និង២៧៖ “<ស>៖ ក្នុងឆ្នាំ<១៩៧៥> តើលោកមានឃើញការជម្លៀសប្រជាជនដែរឬទេ? <ឆ.២៥>៖ ខ្ញុំឃើញគេជម្លៀសប្រជាជនចេញពីទីក្រុង ដោយធ្វើដំណើរតាមផ្លូវឆ្ពោះទៅកាន់ស្រុកកំណើតរៀងៗខ្លួន។ ក្នុងករណីអ្នកដែលគ្មានស្រុកកំណើត គឺពួកគេសុំមកស្នាក់នៅជាមួយប្រជាពលរដ្ឋក្នុងភូមិ ឬស្រុកនោះតែម្តង។ <ស>៖ នៅពេលដែលប្រជាជនមករស់នៅក្នុងភូមិ តើមានផែនការណែនាំដែរឬទេ? <ឆ.២៧>៖ ថ្នាក់<លើ>គេណែនាំមកថា ឲ្យ<ប្រមូល>ប្រជាជនទាំងនោះ<ទៅ>នៅមួយកន្លែងសិនតាមវត្តអារាម ឬសាលារៀន។ ក្រោយមកទើបគេចែកទៅតាមភូមិ។ ពេលប្រជាជនទៅដល់ភូមិ គឺហូបបាយរួមគ្នាជាមួយប្រជាជនមូលដ្ឋានតែម្តង។” ដូច្នេះសំណួរទី១របស់ខ្ញុំ គឺចង់សួរលោកអំពីប្រជាជនដែលចេញពីទីក្រុង ហើយធ្វើដំណើរឆ្ពោះទៅកាន់ “ស្រុកកំណើតរៀងៗខ្លួន” នោះ។ តើលោកអាចកំណត់ដោយរបៀបណាថា ប្រជាជនដែលចេញពីទីក្រុង<ទាំងនោះ>បានធ្វើដំណើរទៅកាន់ស្រុកកំណើត<របស់ពួកគេវិញ>?

[១៣:៤២:១៩]

**ឆ៖** បាទ អរគុណ។ ប្រជាជនដែលជម្លៀសចេញពីទីក្រុង ធ្វើដំណើរតាមផ្លូវមានការអូសរទេះ មានធ្វើជាដំណើរ ឬមានរថយន្តនាយអាយតិចតួចហ្នឹងទេ គឺគេប្រកាសថា ធ្លាប់នៅស្រុកណា ខេត្តណា ឲ្យអញ្ជើញទៅតាមកន្លែងដែលលោក ដែលអ្នកអញ្ជើញមកហ្នឹងធ្លាប់ស្គាល់ធ្លាប់ដឹងរៀងៗខ្លួន។

**ស៖** ប៉ុន្តែក្នុងពេលដែលលោកធ្វើ<ការនៅ>ឃុំញ៉ែងញ៉ង តើលោកអាចកំណត់ដោយរបៀបណាថា អ្នកដែលត្រូវបានជម្លៀសហ្នឹង <បានធ្វើ>ធ្វើដំណើរ<មក>ស្រុកកំណើត<វិញ>?

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំមិនដែលធ្វើមេឃុំញ៉ែងញ៉ងទេ ខ្ញុំនៅមន្ទីរ។ ប៉ុន្តែខ្ញុំកំណត់បានដោយប្រជាពលរដ្ឋធ្វើដំណើរតាមផ្លូវជាតិលេខ៣ មន្ទីរនៅជាប់ៗកន្លែងហ្នឹង។ អ៊ីចឹងឃើញគាត់ខ្លះសួរទៅថា ទៅស្រុកនៅកំពត នៅអ៊ីចឹងទៅ។ ខ្លះក៏ថានៅភូមិជិតៗហ្នឹងទៅ។ អ៊ីចឹងគេធ្វើដំណើរទៅរកឪពុកម្តាយរបស់គេកាលជំនាន់នោះ។

**ស៖** ខ្ញុំដឹងថាវាជាសំណួរលំបាក ប៉ុន្តែតើលោកអាចកំណត់<បានទេថា>ប្រជាជន<>មកពីភ្នំពេញ<មានប៉ុន្មានភាគរយ?> តើលោកឃើញថាមានប្រជាជនប៉ុន្មាន<នាក់>ដែលចាកចេញពីភ្នំពេញ ហើយបានត្រឡប់<មកដល់>ស្រុកកំណើត<វិញ>?

**ឆ៖** កាលជំនាន់នោះ មិនអាចស្ថិតិជាតួលេខឲ្យបានច្បាស់ប្រាកដបានទេ ឃើញតែធ្វើដំណើរហូរហែ។ មិនអាចកំណត់ថា ប៉ុន្មានគ្រួសារ ប៉ុន្មាននាក់បានទេ ព្រោះប្រសេចប្រសាច ខ្លះក៏ទៅតាមផ្លូវ

៣១ ទៅទូកមាស ខ្លះក៏ទៅលិចទៅតាមកំពតអ៊ីចឹងទៅ។ យើងមិនអាចកំណត់បានទេ។

[១៣:៤៥:១០]

**ស៖** ខ្ញុំយល់លោកសាក្សី ប៉ុន្តែមូលហេតុដែលខ្ញុំសួរហ្នឹងគឺថា ព្រោះខ្លួនលោក<ទេតើជាអ្នកបញ្ជាក់ពីភាពខុសគ្នានោះ>។ <តើ>លោក<អាច>បញ្ជាក់<បានទេ>ថាប្រជាជន<ភាគច្រើន>ដែលចេញពីភ្នំពេញ<ពិតជាបានទៅដល់>ស្រុក<កំណើតរបស់>ខ្លួន<មែន>?

**ឆ៖** សំណួរនេះ ខ្ញុំហាក់ដូចជាមិនយល់។ សុំបញ្ជាក់ម្តងទៀត។

**ស៖** ខ្ញុំនឹងបន្តទៅមុខទៀតលោកសាក្សី។ ប្រជាជនដែលចេញពីភ្នំពេញ ទោះបីថាគាត់ទៅ<ដល់> ស្រុកកំណើត ឬក៏<>ទៅ<មិនដល់ស្រុកកំណើត>ក៏ដោយ បើតាមដែលលោកដឹង <តើប្រជាជនទាំងនោះ> ត្រូវ<>គេរើសអើងដោយសារតែពួកគាត់គឺជាអ្នក<>មកពីទីក្រុងភ្នំពេញ<ដែរឬទេ>?

**ឆ៖** បាទ សុំជម្រាបថា កាលជាដំបូងគេមិនរើសអើងអ៊ីចឹងទេ បងប្អូនដែលអញ្ជើញមកពីទីក្រុងភ្នំពេញ ឬតាកែវក្តី គេឲ្យរស់នៅជាមួយក្នុងសហករណ៍ ដោយគេមិនទាន់បានរៀបចំកន្លែងលំនៅដ្ឋានឲ្យបាន ខ្លះមានឪពុកម្តាយ នៅជាមួយឪពុកម្តាយបណ្តោះអាសន្នទៅ ខ្លះក៏នៅតាមកន្លែងដូចជាសាលារៀន វត្តអារាម ដែលកន្លែងទំនេរហ្នឹងវានៅបណ្តើរៗហូបបាយជាមួយប្រជាពលរដ្ឋមូលដ្ឋានបាទ។

**ស៖** ប៉ុន្តែ តើ<គេមានណែនាំ>លោក<ឲ្យធ្វើបាបអ្នកទើបមកដល់ពីភ្នំពេញជាងអ្នក>នៅ<ទីនោះស្រាប់ដែរឬទេ?>។ ឧទាហរណ៍ ដូចជា<ម្ហូប>អាហារ ឬ<ការងារ> ឬ<តើ>ប្រជាជនទាំងអស់គឺត្រូវបានគេ<>ប្រព្រឹត្ត<>ដូចៗគ្នា?

**ឆ៖** បាទ ដូចខ្ញុំបានជម្រាបអ៊ីចឹង ពីដំបូងដែលទើបរំដោះហ្នឹងគឺគេហូបជាមួយគ្នា ស្មើៗគ្នាគេមិនទាន់មានផែនការរៀបចំជាប្រភេទទេ។

[១៣:៤៨:១០]

**ស៖** ដូច្នេះ គឺមានន័យថា មិនមានគោលនយោបាយ<បែបនោះ>ពីថ្នាក់លើ<ទេ? មែនដែរឬទេ?> បានន័យថា គេមិន<ណែនាំ>លោក<ឲ្យ>បែងចែក<ភាព>ខុសគ្នា<ក្នុងចំណោមប្រជាជនទេ> តើអ៊ីចឹងមែនទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប។ សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ខ្ញុំសូមជំទាស់លោកប្រធាន។ ចម្លើយគាត់ហ្នឹងឆ្លើយ គាត់និយាយពីរដងហើយ គាត់ថាពីដំបូង <>ប្រជាជនទាំងអស់ហ្នឹងត្រូវបានប្រព្រឹត្តស្មើ<ៗ>គ្នា<។> គាត់មិនបានបញ្ជាក់ថា ពេល<វេលា> ណា<មួយ>ឱ្យច្បាស់លាស់នោះទេ<។> ហើយឥឡូវនេះ ឃើញចោទសំណួរលក្ខណៈទូលាយទូទៅ <ស្ដីពីការប្រព្រឹត្តទៅលើអ្នកជម្លៀស>ដោយមិនព្រមបញ្ជាក់<>ពីរយៈពេលណាឱ្យពិតប្រាកដ<នោះទេ>។ អ៊ីចឹង វាជាការសំខាន់ណាស់ដែលយើងត្រូវដឹងថា<គាត់ចង់សួរនៅអំឡុងពេលណាមួយ>។ <សូមអរគុណ។>

**លោក វ៉ិចទ័រ កូប៉េ៖**

មិនជាថ្វីទេ លោកប្រធាន ខ្ញុំនឹងបញ្ជាក់ឱ្យបានច្បាស់ជាមួយនឹងសាក្សីរូបនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកបានផ្ដល់ចម្លើយថា មិនមានការប្រព្រឹត្តខុសគ្នារវាងប្រជាជនមូលដ្ឋាន និងប្រជាជន ១៧មេសា នោះទេ។ តើគេ<អនុវត្តការប្រព្រឹត្តលើប្រជាជនស្មើៗគ្នានោះនៅរៀងរាល់ឆ្នាំមែនដែរឬទេ? តើនៅក្នុងឆ្នាំ១៩៧៥, <ឆ្នាំ១៩៧៦, ឆ្នាំ១៩៧៧, ឆ្នាំ១៩៧៨ គេប្រព្រឹត្តលើប្រជាជនដូចៗគ្នា>ដែរឬទេ?

**លោក នុត នូវ៖**

**ឆ៖** បាទ សុំ -- ដូចខ្ញុំមិនយល់រឿងបញ្ហាសំណួរនេះ។ សុំពិភាក្សាជាមួយមេធាវីខ្ញុំ។

[១៣:៤៩:៥៨]

**ប្រធានអង្គជំនុំ៖**

មិនមែនជាប្រភេទសំណួរដាក់បន្ទុកលើសាក្សីទេ។ សាក្សីឆ្លើយ ព្រោះមិនមែនជាសំណួរដាក់បន្ទុកលើលោកទេ។ ចម្លើយរបស់លោកមិនអាចដាក់បន្ទុកលើលោកទេ។ ការពិភាក្សាលុះត្រាតែ នាំឱ្យចម្លើយលោកហ្នឹងដាក់បន្ទុកលើខ្លួនឯង។ លោកអាចសួរបញ្ជាក់នូវសំណួរឱ្យបានច្បាស់លាស់។ ហើយបើលោកស្ដាប់សំណួរច្បាស់ហើយ លោកអាចឆ្លើយបានហើយ។ ព្រោះសំណួរនេះ សំណួរ-ចម្លើយនេះ គេបានសួរលោក ហើយលោកបានឆ្លើយរួចហើយ។ អានេះជាផលវិបាក បច្ច័យដែលកើតចេញពី សំណួរ-ចម្លើយកាលពីលោកបានផ្ដល់ជាមួយនឹងអ្នកស៊ើបអង្កេតកន្លងមក។

**លោក នុត នូវ៖**

**ឆ៖** បាទ អរគុណសំណួរនេះ។ ដូចខ្ញុំបានជម្រាបពីដំបូង គឺរស់នៅជាមួយគ្នាធម្មតា ធ្វើការងារ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

រួម ហូបបាយរួមជាមួយគ្នា។ ក្រោយមកគេបានរៀបចំប្រជាជន១៧មេសា ហ្នឹងនៅម្តុំនៅមួយកន្លែងនៅមួយកងអ៊ីចឹងទៅ ដាច់អំពីប្រជាជនមូលដ្ឋានដែលរស់នៅពីមុន។ នេះសូមជ្រាប។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** សូមអរគុណលោកសាក្សី។ <ខ្ញុំយល់ហើយ។> ប៉ុន្តែសំណួររបស់ខ្ញុំគឺពាក់ព័ន្ធទៅនឹងវិធានការការរើសអើង គឺមានន័យថាគេប្រព្រឹត្តមិនល្អចំពោះក្រុមមួយ <ជាងក្រុមមួយទៀត>។ <ខ្ញុំជឿថា>តាមសក្ខីកម្មរបស់លោក <គឺមិនមានទេ។> ប៉ុន្តែខ្ញុំចង់ដឹងថាតើមានការ<ប្រែប្រួល>ទាក់ទងទៅនឹងការប្រព្រឹត្តចំពោះប្រជាជន<ដែរឬទេ? តើការប្រព្រឹត្តលើប្រជាជនមានលក្ខណៈដូចគ្នា>ក្នុងឆ្នាំ<១៩៧៥, ឆ្នាំ១៩៧៦, ឆ្នាំ១៩៧៧ រហូតមក អ៊ីចឹងមែនដែរឬទេ>?

**ឆ៖** ឆ្នាំ៧៥ គេរៀបចំ ដូចខ្ញុំបានជម្រាបរួចហើយ ដូចស្មើភាពគ្នា។ ដល់៧៦ អ៊ីចឹងទៅ ចុង៧៦អីទៅគេរៀបចំឲ្យប្រជាជនដែលទើបនឹងចេញពីតំបន់ហ្នឹងឲ្យនៅដោយខ្លួនរៀបជាកង។ រៀបជាកងនៅដោយឡែកអំពីប្រជាជនមូលដ្ឋាន។

**ស៖** លោកសាក្សី តើលោកមានចាំថានៅក្នុង<រដូវប្រាំង>ឆ្នាំ<១៩៧៨> មានការណែនាំ <ឲ្យបញ្ឈប់ការបែងចែក>ប្រជាជន១៧មេសា និងប្រជាជនមូលដ្ឋាន<ដែរឬទេ>?

[១៣:៥៣:១៣]

**ឆ៖** បាទ ក្នុងឆ្នាំ៧៨ ខ្ញុំអាចដឹងគឺគេរំលាយប្រជាជនទាំងអស់ បាទ ស្មើភាពគ្នាទាំងប្រជាជន១៧មេសា ទាំងប្រជាជនមូលដ្ឋានពីដើមមកគេទុកស្មើភាពគ្នាទាំងអស់នៅចុង៧៨ សូមជ្រាប។

**ស៖** ប៉ុន្តែតើចំណុចហ្នឹងអាចប្រៀបធៀបយ៉ាងដូចម្តេចជាមួយចម្លើយរបស់លោក<>ពីមុនថាអត់មានការរើសអើងទេ?

**ឆ៖** ពីដំបូងអត់មានរើសអើង យូរទៅគេបែងចែកប្រភេទ។ ដល់ចុងឆ្នាំ៧៨ ហ្នឹងគេឲ្យស្មើភាពគ្នាទាំងអស់មិន -- អ្នកណាហ៊ាននិយាយដល់ប្រជាជន១៧មេសា គេមិនឲ្យនិយាយទេ ឲ្យនិយាយប្រជាជនដូចប្រជាជនដែលរស់នៅពីមុន បាទ។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំមានសំណួរចុងក្រោយមួយ។ តើលោកដឹងទេថាមានមនុស្សប៉ុន្មាននាក់ដែលរស់នៅក្នុងឃុំញ៉ែងញ៉ង<ប្រហែលប៉ុន្មាននាក់ដែរ>ក្នុងឆ្នាំ<១៩៧៥-១៩៧៦>?<>

**ឆ៖** បាទ កាលនោះ ខ្ញុំមិនបានដឹងពិតប្រាកដទេ។ ប្រជាជន ឬមនុស្សប៉ុន្មាននាក់ហ្នឹង មិនមានតួលេខនៅនឹងដៃទេ នៅលើមេឃុំ បាទ ហើយគណៈឃុំគេអ្នកដឹង ចំពោះខ្ញុំនៅមន្ទីរ នៅញ៉ែងញ៉ងហ្នឹង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អត់បានដឹងថាប៉ុន្មាននាក់ ប៉ុន្មានគ្រួសារទេ សូមអង្គសវនាការជ្រាប។

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីលោក ខៀវ សំផន ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោកសាក្សី ខ្ញុំចង់សួរបញ្ជាក់ពីសំណួររបស់លោក ចម្លើយរបស់លោកអម្បាញ់មិញ ដែលលោកប្រៀបធៀបខុសគ្នារវាងគណៈឃុំ ហើយនិងមន្ទីរឃុំ។ លោកបានជម្រាបខាងដើមហើយថា លោកមានភារកិច្ចនៅក្នុងកិច្ចការសេដ្ឋកិច្ចផ្នែកស្បៀង ហើយម្ហូបអាហារ ប៉ុន្តែខ្ញុំចង់សួរលោកបញ្ជាក់ទៅលើមន្ទីរទាំងមូលតែម្តង មន្ទីរឃុំហ្នឹង។ តើមានកម្មាភិបាលធ្វើស្អីខ្លះនៅក្នុងមន្ទីរហ្នឹងដែរ ហើយវាខុសគ្នាពីគណៈឃុំយ៉ាងដូចម្តេច?

[១៣:៥៦:៤៩]

**លោក នុត នូវ៖**

**ឆ៖** បាទ សូមអរគុណ។ គណៈឃុំមានតួនាទីផ្នែករដ្ឋបាល គេគ្រប់គ្រងប្រជាពលរដ្ឋ ឯអ្នកនៅមន្ទីរ គឺមានតួនាទីត្រឹមហៅថាស្បៀងសម្រាប់ប្រជាពលរដ្ឋ ឬសម្រាប់កាលនោះ មានសរមភូមិមុខកងទ័ពទៅ ពេលហ្នឹងអត់ទាន់មានអ្វី គឺគេមកសុំតាមឃុំនីមួយៗ ប៉ុន្តែស្បៀងនេះ ដែលរកបានមក គឺមេឃុំអ្នកសម្រេច។ បាទ ហើយមេឃុំកាលជំនាន់នោះ ឈ្មោះលោក ប៊ុន ស៊ី ប៉ុន្តែសព្វថ្ងៃ ឮដំណឹងថានៅអីជាំក្សាន្តឯណោះ អីព្រះវិហារខ្ញុំមិនបានជួប បានដឹងទេ គ្រាន់តែឮ។

[១៣:៥៧:៤៥]

**ស៖** លោកសំដៅនៅឆ្នាំដែរ លោកអាចបញ្ជាក់ពីឆ្នាំចាប់ផ្តើម និងឆ្នាំបញ្ចប់បានទេ?

**ឆ៖** នៅឆ្នាំ១៩៧៥-៧៦ មិនដឹងជាចុង៧៦ ឬ៧៧ទេ គេឲ្យទៅនៅអីខេត្តកំពង់ចាម។ ហើយក្រោយមក គឺលោក តាស៊ិន់ ហៅ ស៊ឹម មកនៅធ្វើមេឃុំនៅកន្លែងហ្នឹង។ ខ្ញុំចេញពីឃុំហ្នឹងរួចហើយ

បាទ។

**ស៖** សំណួរខ្ញុំមិនអំមិញហ្នឹងលោកអត់ទាន់បានបញ្ជាក់អំពីសមាសភាពនៅក្នុងមន្ទីរ ថាតើមានអ្នកណាខ្លះ មានកម្មាភិបាលណាខ្លះ ឬក៏មានអ្នកដែលមានមុខងារទទួលខុសត្រូវអ្វីខ្លះក្រៅពីលោក ដែលធ្វើការនៅក្នុងមន្ទីរឃុំហ្នឹងទេ?

**ឆ៖** បាទ នៅក្នុងមន្ទីរឃុំមានតែខ្ញុំម្នាក់និងនីរសារពីរនាក់ សម្រាប់រត់សំបុត្រសុំសេដ្ឋកិច្ច ឬបន្តែបង្កាទៅតាមភូមិ។ ឯនៅក្នុងមន្ទីរក្នុងឃុំ កន្លែងឃុំ គឺគេមានស្មៀនសម្រាប់កត់ត្រា ជាលេខារបស់ឃុំម្នាក់ ហើយលេខាម្នាក់ហ្នឹងស្លាប់ហើយកាលរត់៧៩។

[១៣:៥៩:៤0]

**ស៖** បាទ សូមអរគុណ។ នៅក្នុងឋានៈរបស់លោក តើលោកជាសមាជិកម្នាក់នៃគណៈឃុំដែរទេ?

**ឆ៖** បាទ មិនទាន់មានតួនាទីជាសមាជិកនៅក្នុងគណៈឃុំទេ គ្រាន់តែទទួលខុសត្រូវមន្ទីរសេដ្ឋកិច្ចសម្រាប់ចែកចាយនូវអាអ្វីអាវត្ថុផងទាំងឡាយទៅដល់កងនីមួយៗនៅក្នុងឃុំ សម្រេចលើមេឃុំ។ ខ្ញុំបានជម្រាបរួចហើយ។

**ស៖** បាទ លោកអាចរៀបរាប់អំពីសមាសភាពគណៈឃុំបានទេ ដែលមានគណៈឃុំជាលេខាម្នាក់ ជាប្រធានម្នាក់ ហើយជាសមាជិក ឬក៏ជាយោធា ឬក៏អ្នកទទួលខុសត្រូវផ្នែកណាៗមួយ នៅក្នុងគណៈឃុំនោះ លោកអាចរៀបរាប់បានទេ ពីតួនាទី ឬក៏ឈ្មោះរបស់កម្មាភិបាលនោះ?

**ឆ៖** បាទ អរគុណ ខ្ញុំអាចជម្រាបបាន។ ទី១ គឺលោក ប៊ុន ស៊ី ប្រធានឃុំ។ អនុប្រធានឃុំ មិនស្គាល់ត្រកូលទេ គឺអ្នកស្រី ធឿន។ សមាជិក ទុយ ទាវ ហើយនិងសមាជិកមួយទៀត លោក តាឈឿន ។ ស្គាល់ទាំងអស់ហ្នឹង ហើយអ្នកសរសេររបាយការណ៍ជាប់ជាមួយឃុំគឺ លោក យូរ ស្លាប់ហើយកាលរត់ហ្នឹង។ មិនមែនជាសមាជិកឃុំទេ លោក យូរ ហ្នឹងជាអ្នកសរសេរកត់ត្រាផ្សេងៗ។

[១៤:0១:៤១]

**ស៖** បាទ សូមអរគុណ។ សម្រាប់ខ្លួនលោកផ្ទាល់ តើលោកធ្លាប់ធ្វើការផ្នែកយោធាឃុំដែរទេ?

**ប្រធានអង្គជំនុំ៖**

ឈប់កុំអាលទាន់ឆ្លើយតប!

**លោក នុត នូវ៖**

**ឆ៖** ដូចខ្ញុំបានជម្រាបពីមុនមកហើយ ខ្ញុំធ្លាប់ចូលយោធានៅសមរភូមិតាកែវហ្នឹង ឆ្នាំ១៩៧៣។ ៧៣អ៊ីចឹង ធ្វើនៅកន្លែងហ្នឹង ក្រោយមក ខ្ញុំមានជំងឺប្រចាំកាយ និងជំងឺគ្រុនចាញ់ បានគេមកនៅមន្ទីរពៀងញ៉ង ចុងឆ្នាំ ប្រហែលជាដើមឆ្នាំ៧៤ ឬក៏ពាក់កណ្ដាលឆ្នាំ៧៤ បាទ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំ សំណួររបស់ខ្ញុំគឺទាក់ទងទៅនឹងយោធាឃុំ។ តើលោកធ្លាប់ធ្វើជាយោធាឃុំ ជាប្រធាន ឬក៏មានឋានៈអីមួយនៅក្នុងឃុំដែរទេ ក្នុងឋានៈជាឃុំ មិនមែនជាយោធានៅក្នុងសមរភូមិមុខទេ?

**ឆ៖** ទទួលយោធាឃុំមានឈ្មោះ សេង គឺឈ្មោះ ឈឿន ជាប្អូនថ្លៃរបស់ ប៊ុន ស៊ី កាលនោះ។ សព្វរស់នៅភូមិនៀល ឃុំត្រាំកក់។

**ស៖** បាទ អ៊ីចឹង ខ្ញុំសូមបញ្ជាក់ឡើងវិញថា លោកមិនដែលធ្វើជាយោធាឃុំទេ។ អ៊ីចឹងត្រឹមត្រូវទេ?

[១៤:០៣:៥០]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

**លោក នុត នូវ៖**

**ឆ៖** យោធាហ្នឹង ខ្ញុំធ្លាប់ធ្វើ ដូចបានជ្រាបហើយ នៅសមរភូមិ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** អ៊ីចេះ ខ្ញុំចង់ឲ្យលោកបញ្ជាក់ពីយោធាឃុំ។ ខ្ញុំបានស្ដាប់យល់ហើយពីការងារយោធារបស់លោកក្នុងឆ្នាំ៧៣ នៅក្នុងសមរភូមិ ប៉ុន្តែសម្រាប់នៅក្នុងឃុំណាមួយវិញនោះ នៅក្នុងខេត្តតាកែវ លោកធ្លាប់ធ្វើជាប្រធានយោធាឃុំ ឬក៏មានឋានៈណាមួយនៅក្នុងឃុំដែលបន្ទុកផ្នែកយោធា។ លោកស្ដាប់សំណួរខ្ញុំបានទេ?

**ឆ៖** បាទខ្ញុំមិនដែលទេ នៅក្នុងឃុំ។

[១៤:០៤:៤៩]

**ស៖** មុននេះ ពេលដែលលោកចៅក្រម ឡាវ៉ែន៍ សួរអំពីឈ្មោះ តាហួញ ដែលលោកធ្លាប់ស្គាល់ ហើយខ្ញុំចង់សួរលោកថា តើលោកធ្លាប់ធ្វើការនៅជាមួយ តាហួញ ហ្នឹងដែរទេ?

**ប្រធានអង្គជំនុំ៖**

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

កុំៗអាលទាន់ឆ្លើយតប!

**លោក នុត នូវ៖**

**ឆ៖** តាហួញ គាត់កាលពីនោះ គាត់ធ្វើជាប្រធានឃុំលាយបូរ។ ក្នុងពាក់កណ្តាល ៧៦ ឬ៧៦ ខ្ញុំគេឲ្យទៅធ្វើជាសមាជិកតាហួញ។ ក្នុងនោះមានលោក តាហួញ ប្រធាន, លោកប៉ូ អនុប្រធាន, ខ្ញុំជាសមាជិក។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ ក្នុងនាមលោកជាសមាជិកហ្នឹង លោកទទួលបន្ទុកផ្នែកអីដែរ?

**ឆ៖** ក្នុងនាមជាសមាជិកទទួលបន្ទុក គេចាត់តាំងឲ្យធ្វើស្រែប្រាំងនៅកំពង់យោល ទួលសង្កែ កំពង់យោល ឯស្រុកទ្រាំងឯណោះ និងធ្វើប្រឡាយ ខែប្រាំងចុះធ្វើប្រឡាយជាមួយប្រជាពលរដ្ឋ ដឹកនាំប្រជាពលរដ្ឋធ្វើប្រឡាយ ជីកប្រឡាយ។ សូមអរគុណ។

[១៤:០៦:៣៥]

**ស៖** មានការទទួលខុសត្រូវណាមួយជាក់លាក់ទេ ឧទាហរណ៍ថា ជាសមាជិកទទួលបន្ទុកផ្នែកសេដ្ឋកិច្ច ឬក៏យោធា ឬក៏វប្បធម៌អីចឹង មានការចាត់តាំងណាមួយដែលថាឲ្យលោកក្នុងនាមជាសមាជិកឃុំរបស់ តាហួញ ហ្នឹងមានភារកិច្ចធ្វើអ្វី? លោកអាចបញ្ជាក់បានទេ?

**ឆ៖** មានរៀបចំបណ្តាញ ប្រធានទទួលបន្ទុកការងាររួម អនុប្រធានទទួលបន្ទុកសេដ្ឋកិច្ច សមាជិកទទួលបន្ទុកខាងវប្បធម៌។ ប៉ុណ្ណឹងមាន។

**ស៖** លោកចាំបានឬក៏ដឹងដោយរបៀបណាដែលថាលោកក្នុងនាមជាសមាជិកទទួលបន្ទុកផ្នែកវប្បធម៌ហ្នឹង។ លោកអាចពន្យល់បកស្រាយបានទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបសាក្សី!

**លោក នុត នូវ៖**

**ឆ៖** បាទ កាលសម័យនោះ គេរៀបចំអីចឹង។ គេបែងចែកភារកិច្ច តួនាទីនីមួយៗ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ចុះការងារជាក់ស្តែងរបស់លោកដែលលោកឆ្លើយថា ទទួលបន្ទុកផ្នែកវប្បធម៌ហ្នឹង លោកបានធ្វើអីខ្លះទាក់ទងនឹងវប្បធម៌ហ្នឹង?

**ឆ៖** ខាងវប្បធម៌នេះគឺបានណែនាំទៅតាមកងនីមួយឲ្យបង្រៀនដល់កុមារតូចៗ ហើយក្នុងការរៀនហ្នឹងមិនមានរៀនអីដូចជាថ្នាក់អីខ្ពស់បានទេ គឺគ្រាន់តែរៀនឲ្យចេះអាន ចេះសរសេរ។ ដូចខ្ញុំបានជម្រាបរួចហើយថារៀននៅតាមក្រោមផ្ទះ នៅតាមម្លប់ឈើ ហើយគ្រូបង្រៀនហ្នឹងគឺអ្នកដែលចេះអក្សរនាយអាយទេ មិនមានសញ្ញាប័ត្រ ឬបានអប់រំពីថ្នាក់លើទេ។ សូមអរគុណ។

**ស៖** បាទសូមអរគុណ។ តើលោកផ្ទាល់ជាអ្នកគ្រប់គ្រងគ្រូនៅក្នុងឃុំលាយបូរដែលលោកធ្វើការជាសមាជិករបស់តាហួញ ហ្នឹង ឬមួយក៏មានអ្នកផ្សេងទៀតទទួលខុសត្រូវ?

**ឆ៖** បាទ មានគ្រូផ្សេងទៀតជាអ្នកទទួលខុសត្រូវ ហើយអ្នកដែលទទួលខុសត្រូវគឺខាងប្រធាននារីដែលគេចុះជាប់។ ប្រធាននារីឃុំ។

**ស៖** ចុះសម្រាប់ការងាររបស់លោកវិញ ក្នុងនាមជាអ្នកទទួលខុសត្រូវផ្នែកវប្បធម៌ហ្នឹង លោកមានទំនាក់ទំនងយ៉ាងម៉េចជាមួយហ្នឹងគ្រូៗ ឬក៏កម្មាភិបាលដទៃទៀតដែលធ្វើកិច្ចការមានទំនាក់ទំនងជាមួយការងារវប្បធម៌ហ្នឹងដែរ?

[១៤:១០:២២]

**ឆ៖** ការទំនាក់ទំនងជាមួយគ្រូបង្ហាត់សិស្សហ្នឹងគឺណែនាំឲ្យលោកគ្រូអ្នកគ្រូហ្នឹងខិតខំបង្រៀនអក្សរសាស្ត្រ ដល់កុមារា កុមារី។ មានពេលគឺរៀបចំដូចខ្ញុំបានជម្រាបខាងដើមថាប្រមូលអាចម៍គោសន្សំធ្វើជាជីធម្មជាតិបាទ ក្នុង១ថ្ងៃហ្នឹងធ្វើ ពីរបីម៉ោងទៅ ហើយចន្លោះពេលគឺរៀនសូត្រ មួយម៉ោង ពីរម៉ោងបាទទៅតាមជាក់ស្តែង។

**ស៖** តើលោកមានបានទទួលរបាយការណ៍អំពីលទ្ធផលនៃការសិក្សារបស់កុមារទាំងអស់នោះដែរឬទេ?

**ឆ៖** បាទ ពិតជាបានការទទួលការសិក្សាពីកុមារតាមលោកគ្រូធ្វើរបាយការណ៍មក ការបង្រៀនជាក់ស្តែងទៅតាមសៀវភៅដែលជំនាន់នោះគេមានចែកជាសៀវភៅឲ្យរៀនសូត្រ។

**ស៖** ខ្ញុំអាចសួរបញ្ជាក់បន្ថែមបន្តិចទៀតដោយសារថាលោកបានទទួលរបាយការណ៍ អ៊ីចឹង ខ្ញុំចង់ដឹងថា តើសមត្ថភាពរបស់កុមារទាំងអស់នោះអាចចេះអាន ចេះសរសេរបានដូចម្តេចដែរ បើប្រៀបធៀបពីចំណុចចាប់ផ្តើមដំបូងដែលលោកទៅធ្វើការហើយនិងចុងក្រោយនៅពេលដែលលោកបញ្ចប់ការងារនោះវិញនោះ?

**ឆ៖** បាទ ខ្លះអាចចេះអានជាអក្សរហ្នឹងមានកម្រិតទាបទេ មិនកម្រិតខ្ពស់ទេក្នុងការរៀនហ្នឹង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរលោកពីសំណួរទូទៅមួយទាក់ទងទៅនឹងគោលការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា លោកបានឆ្លើយបញ្ជាក់ថាលោកជាសមាជិកត្រៀម ជាបក្ខជនត្រៀម។ ខ្ញុំចង់ដឹងថា លោកបានសិក្សាពីគោលការណ៍អ្វីខ្លះ ដែលជាគោលការណ៍សំខាន់ៗរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងសម័យនោះ លោកអាចបញ្ជាក់បានទេ?

[១៤:១៣:២៨]

**ឆ៖** ដូចខ្ញុំឆ្លើយទៅតាមសមត្ថភាពដែលខ្ញុំអាចចាំបាន។ គោលការណ៍ជាបក្ខជនត្រៀមគឺមានសិទ្ធិមិនស្មើនឹងបក្ខជនពេញសិទ្ធិទេ គឺនៅក្រោមសិទ្ធិរបស់បក្ខជនពេញសិទ្ធិ គ្រាន់តែយើងមានតួនាទីដឹកនាំការងារផ្សេងៗនៅក្នុងមូលដ្ឋានប៉ុណ្ណឹង។ ឯបក្ខជនពេញសិទ្ធិគេមានសិទ្ធិធ្វើរបាយការណ៍ឡើងទៅខាងស្រុក ទៅតំបន់ ទៅតាមថ្នាក់អីចឹងទៅបាទ។

**ស៖** បាទ ខ្ញុំចង់សួរពីគោលការណ៍ជានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ថាតើលោកចងចាំគោលការណ៍អ្វីខ្លះសំខាន់ៗរបស់បក្សដែរទេ?

**ឆ៖** គោលការណ៍សំខាន់ៗទាំងនោះ ដោយវ័យកាន់តែចាស់ មិនអាចចាំបានទេ មានការភ្លេចភ្លាំងខ្លះ ប៉ុន្តែគោលការណ៍គឺទី១ រៀបចំដោះស្រាយជីវភាពប្រជាជននៅក្នុងមូលដ្ឋាន, ទី២ គឺរៀបចំកិច្ចការផ្ទៃក្នុងបក្សឲ្យបានល្អ។

**ស៖** លោកអាចពន្យល់លម្អិតបន្តិចបានទេ តើការរៀបចំផ្ទៃក្នុងបក្សហ្នឹងលោកចង់សំដៅលើអ្វី?

**ឆ៖** រៀបចំគោលការណ៍នៅក្នុងផ្ទៃក្នុងបក្សហ្នឹង គឺចង់ឲ្យបក្សស្មោះត្រង់ជាមួយបក្សកុម្មុយ-នីស្តកម្ពុជា មិនងាករេ មិនប្រឆាំង គឺដើរតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។

[១៤:១៦:0១]

**ស៖** បាទ ចុះទាក់ទងបញ្ហាស្បៀង ហើយលោកមានប្រសាសន៍អំមិញ?

**ឆ៖** ទាក់ទងនឹងបញ្ហាស្បៀងនេះ គឺនៅក្នុងមូលដ្ឋានមួយៗ គឺគេឲ្យយើងខិតខំធ្វើម៉េចដោះ-ស្រាយជីវភាពប្រជាពលរដ្ឋឲ្យបាន កុំឲ្យមានការខ្វះខាត។

**ស៖** បាទ សូមអរគុណ។ មុននេះនៅពេលព្រឹកម៉ោង១១ និងប្រហែល១៩នាទី នៅព្រឹកមិញហ្នឹង លោកបានឆ្លើយថា ខ្ញុំសូមដក ពន្យល់សេចក្តីសម្រេចដែលខ្ញុំបានកត់ត្រា៖ “ថ្នាក់លើដាក់ផែនការឲ្យថ្នាក់ឃុំផ្តល់ម្ហូបអាហារដល់ប្រជាជនឲ្យបានគ្រប់គ្រាន់”។ ទាក់ទងទៅនឹងការរៀបចំផែនការឲ្យរកម្ហូបអាហារឲ្យគ្រប់គ្រាន់នេះ នៅថ្នាក់ឃុំនេះ ខ្ញុំចង់សួរថា តើលោកធ្វើដូចម្តេចខ្លះដើម្បីធានាថាក្នុងឃុំ

របស់លោកមានម្ហូបអាហារគ្រប់គ្រាន់?

**ឆ៖** បាទ អរគុណណាស់។ សំណួរនេះខ្ញុំដូចបានជម្រាបពីព្រឹករួចហើយ ថានៅក្នុងឃុំស្រែរនោងរបស់ខ្ញុំ កាលជំនាន់នោះមានរៀបជាកងដាំដំណាំ បន្លែបង្ការផ្សេងៗ និងរៀបអ្នកចិញ្ចឹមមាន់រៀបអ្នកចិញ្ចឹមជ្រូក ហើយនិងគោហ្នឹង មានគោតាមកង និងគោដាក់មួយដុំបាទ ព្រមទាំងចាត់ចែងឲ្យខាងសេដ្ឋកិច្ចរកត្រីយកមកដោះស្រាយប្រចាំថ្ងៃ រហូតដល់១០ថ្ងៃ ក៏មានពិធីរៀបចំឲ្យប្រជាពលរដ្ឋហូបបើថាត្រូវថ្ងៃគោ គឺសាច់គោ ត្រូវជ្រូកគឺសាច់ជ្រូក បើមាន់គឺសាច់មាន់។ ប៉ុន្តែជាប្រចាំមាន់ហ្នឹងមានប្រចាំថ្ងៃ ស្លជាមួយបន្លែ បាទបន្លែគ្រប់មុខ។ បាទ សូមអរគុណ។

**ស៖** បាទ សូមអរគុណ។ តើលោកអាចបញ្ជាក់បានទេអំពីការខ្វះខាតស្បៀងអាហារនៅក្នុងឃុំរបស់លោកហ្នឹង។ វាមានកម្រិតប៉ុនណា វាជាការខ្វះខាតធ្ងន់ធ្ងរ ជាការខ្វះខាតបន្តិចបន្តួច ឬក៏មានលក្ខណៈណាមួយដែលលោកអាចបញ្ជាក់ថាការខ្វះខាតនោះវាមិនគួរឲ្យកត់សម្គាល់ខ្លាំងទេ។ លោកអាចបញ្ជាក់បានទេ ថាតើវាគ្រប់គ្រាន់ ឬក៏ខ្វះខាតប៉ុនណាទាក់ទងនឹងបញ្ហាស្បៀងនេះ តាមការអនុវត្តផែនការដើម្បីធានាស្បៀងរបស់លោកនេះ?

[១៤:១៩:៣១]

**ឆ៖** បាទ ការដោះស្រាយមានការខ្វះខាត បើប៉ាន់ជាតួលេខអាចពី៣០ភាគរយឡើងទៅ អាចដោះស្រាយបាន៧០ភាគរយ។ អ៊ីចឹងពីមុនខ្ញុំទៅស្រែរនោង មេឃុំដែលមានឈ្មោះ តាខុន ដោះស្រាយប្រជាជន ឃើញជាក់ស្តែង មិនចោទទៅលើគេទេ ប៉ុន្តែជាក់ស្តែងគេដោះស្រាយមានកម្រិតទាប។ គ្រាន់តែតាមកងនីមួយៗ និយាយដោយត្រង់ទៅ ខ្ញុំដើរទៅមើលឃើញជ្រូកនៅធំៗណាស់ បាទក្រោយមកនេះខ្ញុំទៅដល់ភ្លាម គឺផ្តល់ម្ហូបអាហារទៅតាមកងនីមួយៗតាមសភាពជាក់ស្តែងដែលម្ហូបនៅសល់នៅក្នុងឃុំដែលគេត្រៀមចិញ្ចឹមដែរពីមុន មិនមែនគេមិនចិញ្ចឹម ចិញ្ចឹម ប៉ុន្តែមិនដោះស្រាយ នេះបានសូមជ្រាប។

**ស៖** លោកអាចបញ្ជាក់បន្ថែមបន្តិចបានទេ ពាក្យថា "មិនដោះស្រាយហ្នឹង" បានន័យថាចិញ្ចឹមបានហើយ មិនបានផ្តល់ទៅឲ្យប្រជាជនបរិភោគ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទនេះ គឺពិតប្រាកដមែន។

**ស៖** លោកដឹងថាមូលហេតុអីដែរ បានជាក្នុងឃុំដែលធ្វើការមុនលោកនោះ គេមិនបានផ្តល់ម្ហូបផ្តល់សាច់ជ្រូកសាច់អី ហើយលោកថាឃើញធំធាត់នៅចិញ្ចឹមទុក មិនឲ្យប្រជាជនហូបនោះ?

**ឆ៖** តាមខ្ញុំមើលទៅ គេដោះស្រាយមានកម្រិត។ សាច់ជ្រូកក្តី គេដោះស្រាយស្លជាមួយបន្លែ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បង្ការតិចតួចទេ។ ក្នុងមួយចានហ្នឹងវាមានពីរបីដុំ តាមជាក់ស្ដែង សាច់មាន់ក៏អ៊ីចឹង។ ម្ហូបអាហារមិនដឹងគេយល់ថាយ៉ាងម៉េចយ៉ាងម៉ាទេ ប៉ុន្តែខ្ញុំឃើញ សាកសួរប្រជាពលរដ្ឋដែលទៅដល់ភ្លាម សួរប្រជាជនតាមសហករណ៍នីមួយៗថា ហូបមិនឆ្អែតទេ ប៉ុណ្ណឹង។

[១៤:២២:០០]

**ស៖** បាទ ចុះនៅពេលដែលលោកទៅដល់ លោកទៅកាន់ការងារនៅក្នុងមូលដ្ឋានរបស់លោកទាំងឃុំទាំងឡាយដែលលោកបានធ្វើការហ្នឹង មានទាំងឃុំលាយបូរ ឃុំស្រែរនោង ឬក៏ឃុំញ៉ែងញ៉ង ហ្នឹង តើលោកមានបានទទួលការឆ្លើយតបពីប្រជាជនមកវិញថា គាត់ហូបបានគ្រប់គ្រាន់ ឬក៏អាចថា រួចផុតពីការស្រេកឃ្លានដែរទេ ឬមួយក៏ការខ្វះខាតហ្នឹង នៅតែដដែលដូចមុន? លោកអាចបញ្ជាក់ពីព័ត៌មាន ឬការវាយតម្លៃណាមួយពីប្រជាពលរដ្ឋណាមកលោកវិញទេ?

**ឆ៖** បាទ សូមអរគុណ។ នៅឃុំញ៉ែងញ៉ង ខ្ញុំមិនបានដឹងទេ។ ក្រោយមកទៅនៅលាយបូរ គឺចូលរួមជាមួយមេឃុំ ពីការហូប -- ដីនោះ ដីសមរភូមិ មានការខ្វះខាត។ មកដល់នេះគឺសុំតាមឃុំខាងលើ រួចមកខ្ញុំបានធ្វើជាស្រូវស្រែដើមឆ្នាំ ស្រែរដូវ បានដោះស្រាយជាបណ្ដើរៗ បងប្អូនមានការខ្វះខាតនៅតែមានឲ្យដាំ រៀបចំកងដាំដំណាំ ជាដំឡូងមី ជាដំឡូងជ្វា លាយជាមួយបាយ ដោះស្រាយស្ទើរហូបជាបណ្ដើរៗ។

[១៤:២៣:៤១]

លុះដល់ឆ្នាំ៧៨ ខ្ញុំមកស្រែរនោង គឺងាយដោះស្រាយបាទ ព្រោះប្រឹងដោះស្រាយ។ ងាយដោះស្រាយ ពាក្យថា “ងាយដោះស្រាយ”នេះ ព្រោះសេដ្ឋកិច្ចនៅក្នុងឃុំស្រែរនោង វាមាន មិនមែនថា អ្នកមុនមិនធ្វើទេ មាន ប៉ុន្តែគេមិនដោះស្រាយឲ្យប្រជាពលរដ្ឋហូបឲ្យគ្រប់គ្រាន់។ ហេតុនេះបានឃុំស្រែរនោងទាំងមូល ប្រជាពលរដ្ឋចូលចិត្តខ្ញុំ ដោយ តាឃុន កាលនៅហ្នឹងកាចមែនទែនបាទ។ គ្រាន់តែប្រជាពលរដ្ឋតាមសហករណ៍ឃើញ តាឃុន ដើរទៅ រត់គេចអស់ហើយ។ នេះតាមប្រជាពលរដ្ឋឲ្យព័ត៌មានដល់ខ្ញុំ។ បាទសូមអរគុណ។

**ស៖** បាទសូមអរគុណ។ ខ្ញុំចង់សួរសំណួរថ្មីមួយទៀត ថានៅពេលដែលលោកនៅលាយបូរ លោកអាចបញ្ជាក់ពីពេលវេលាបានទេ នៅពេលដែលលោកធ្វើជាសមាជិកឃុំរបស់ តាហ្វូញ ហ្នឹង? គឺចាប់ពីពេលណា ហើយចប់វិញនៅពេលណា?

**ឆ៖** នៅឃុំលាយបូរពីឆ្នាំ -- ប៉ុនស្មានមិនត្រូវ ពាក់កណ្ដាលជិត៧៦ មកចុង៧៧ បាទប៉ុណ្ណឹង។

ហើយ៧៨ គឺខ្ញុំ ខែ៣ មក ឬខែ៥ទេ ខ្ញុំមកកាន់កាប់ គេឲ្យមកកាន់កាប់នៅស្រែរនោង។ ដល់ស្រែរនោង បានចុងឆ្នាំនេះទៀត គេប្ដូរខ្ញុំមកនៅឃុំអង្គតាសោមបានតែ២ខែទេ បានរំដោះ៧មករាទៅ បាទ។

**ស៖** បាទ ខ្ញុំចង់សួរបញ្ជាក់លោក លោកដឹងថា មានគណៈប្រតិភូពីថ្នាក់មជ្ឈិម ឬពីថ្នាក់លើទៅទស្សនកិច្ចនៅតំបន់លាយបូរសហករណ៍ ឬក៏ឃុំលាយបូររបស់លោកហ្នឹងដែរទេ ក្នុងអំឡុងពេលដែលលោកធ្វើការនៅទីនោះ?

**ឆ៖** បាទ កាលខ្ញុំធ្វើការនៅទីនោះ មាន-- ក្រោយពីលោកតាម៉ុកឲ្យធ្វើជារោងសហករណ៍មួយយ៉ាងធំ អ៊ីចឹងទៅ កាលនោះជំនាន់ហ្នឹង មេឃុំតាហួញ គាត់ផ្លាស់មកភូមិភាគឧត្តររួចហើយ គឺនៅតាកិឈ្មោះតាកិ មានគណៈប្រតិភូចិន អ៊ឹង យ៉ុងគួយ មកទស្សនកិច្ចនៅសហករណ៍ហ្នឹង ហើយមានលោកតាសាន ជាអ្នកទទួលខុសត្រូវរៀបចំក្នុងការទាក់ទទួលហ្នឹង។ នេះពិតប្រាកដ។

[១៤:២៧:០៩]

**ស៖** បាទ សូមអរគុណ។ លោកមានដឹង មានគណៈប្រតិភូផ្សេងទៀតទេ?

**ឆ៖** គណៈប្រតិភូផ្សេងទៀត ខ្ញុំមិនបានដឹងទេ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងឯកសារ E1/253.1 ដែលជាកំណត់ហេតុសវនាការថ្ងៃទី១០ -- ២៧ ខែមករា ឆ្នាំ២០១៥ នៅក្រោយម៉ោង១៤:០៣:៤៦វិនាទី ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់បានឆ្លើយនៅចំពោះអង្គជំនុំជម្រះ ដោយបញ្ជាក់ពីវត្តមានរបស់លោកសាក្សីដែលជា -- ដែលគាត់ហៅឈ្មោះថា តានូវ ហើយមិនៗបានស្គាល់ពីត្រកូលពេញទេ ហើយគាត់បានឆ្លើយបញ្ជាក់ថា លោកជាយោធា មានមុខងារ ហើយគាត់ -- ខ្ញុំសូមអានជូន សំណួរសួរថា៖ លោកស្រីបានហៅឈ្មោះ តានូវ នៅកថាខណ្ឌ២៥ហ្នឹង មានសរសេរហ្នឹង។ អ៊ីចឹង ខ្ញុំសូមប្រាប់ដល់អ្នកបកប្រែនេះជាសំណួរ -- សុំរំលង។ អ៊ីចឹងសួរសំណួរដដែលទេ តើគាត់ឈ្មោះពេញ គាត់អីគេ ហើយគាត់មានមុខងារធ្វើអ្វី? ឆ្លើយ៖ គាត់ឈ្មោះ តានូវ ហ្នឹង គាត់មុខងារគាត់ គាត់ធ្វើការនៅឃុំជាមួយតាហួញ តែឈ្មោះពេញខ្ញុំអត់ដឹង ដឹងថាគេហៅគាត់ថា តានូវៗអ៊ីចឹងទៅ។ ឲ្យតែឃើញតានូវ ម្នាក់ៗខ្លាចតែម្ដង គឺខ្ញុំធ្វើការប្រឹបៗ ខ្លាចព្រោះថាតានូវហ្នឹងគាត់រាងកាច"។ បាទ ហើយនៅក្នុង -- សូមបញ្ឈប់ការដកស្រង់។ ហើយក្នុងចំណុចនេះ ខ្ញុំចង់សូមទោស ខ្ញុំសូមបន្ថែមកន្លែងនេះបន្តិចទៀត សូមដកស្រង់កន្លែងនេះបន្តិចទៀត ទាក់ទងទៅនឹងឯកសារដដែល ហើយនៅខាងលើហ្នឹងបន្តិច។ សំណួរ -- បាទ លើហ្នឹងតែពីរបីបន្ទាត់ទេបាទ។

[១៤:៣០:០៩]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

"សំណួរ៖ លោកស្រីក៏បានរៀបរាប់ឈ្មោះ តាហឿន (ដោយសារខ្ញុំនិយាយមិនសូវច្បាស់ សូមអភ័យទោស)។ បាទ ឈ្មោះតាហ្វួញ។ បើអ៊ីចឹង លោកស្រីដឹងថាគាត់មានមុខតំណែងអីទេកាលនោះ? ឆ្លើយ៖ ខ្ញុំដឹង តាហ្វួញ។ ឈ្មោះគាត់តាហ្វួញ នៅជាមេឃុំៗក្ដោបក្ដាប់លើតានូវ។ តានូវ ផ្នែកយោធា តាហ្វួញគាត់មេឃុំ។" បាទ សូមបញ្ចប់។

ខ្ញុំចង់សួរលោកបញ្ជាក់ឡើងវិញថា តើលោកធ្លាប់ធ្វើជាយោធានៅក្នុងឃុំដែរទេ ឬក៏មានការទទួលខុសត្រូវណាមួយដែលទាក់ទងទៅនឹងផ្នែកយោធាដែរទេកាលលោកនៅជាសមាជិករបស់តាហ្វួញនោះ?

**ឆ៖** កាលនៅជាសមាជិករបស់តាហ្វួញ ខ្ញុំអត់មានធ្វើទទួលខាងយោធាទេ។ គឺមានឈ្មោះ សូត ជាអ្នកទទួលខាងយោធា។ ខ្ញុំជាសមាជិកឃុំ ហើយការខ្លាច វាតែងតែមានហើយ ព្រោះតាណាក៏ដូចតាណាជំនាន់នោះ តែឃើញដើរទៅនឹងគេចេះតែហៅលោកតាៗអ៊ីចឹងទៅ។ បាទ យើងមិនអាចសន្និដ្ឋានថាប្រជាជនមួយចំនួនអាចចូលចិត្តអ៊ីចឹងទៅ មួយចំនួនអាចខ្លាចទៅតាមជាក់ស្ដែង។ បាទ សូមអរគុណ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ចំណុចទាក់ទងនឹងការខ្លាចនេះបានទេ? តើលោកមានប្រតិកម្ម ឬក៏ការបកស្រាយណាមួយទាក់ទងទៅនឹងអំពើ ឬក៏ការប្រព្រឹត្តរបស់លោកចំពោះប្រជាពលរដ្ឋដែលនាំឱ្យពួកគាត់ខ្លាចដែរទេ?

**ឆ៖** សុំជម្រាបថា ការខ្លាចនេះ ខ្ញុំច្រើនសំឡេងធំៗ ក្នុងពិធីឃោសនាក្ដី និយាយលេងសើចអីសំឡេងធំៗ ប៉ុន្តែការលេងជាមួយប្រជាពលរដ្ឋហ្នឹង លេងសើចធម្មតា ប៉ុន្តែដល់ពេលប្រជុំនិយាយពាក្យសម្ដីហ្នឹង និយាយធំៗ ហើយឮៗ។ អ៊ីចឹងបាន ប្រហែលបានជាវាមានអ្នកខ្លាចយ៉ាងហ្នឹង។ បើនិយាយអ្វីគឺនិយាយពិតប្រាកដហើយឮៗ។ បាទ សូមអរគុណ។

**ស៖** បាទ ខ្ញុំចង់សួរបញ្ជាក់បន្ថែមថាតើលោកធ្លាប់ស្ដីបន្ទោស ឬក៏ការដាក់វិន័យ ឬក៏ការធ្វើណាមួយដែលបង្ហាញនូវភាពឃោរឃៅ ដែលនាំឱ្យប្រជាជនខ្លាចដែរទេ? ក្នុងរយៈពេលដែលលោកធ្វើការនៅក្នុងលាយបូរហ្នឹង ឃុំលាយបូរ?

**ឆ៖** បាទ ខ្ញុំមិនដែលដាក់បញ្ហាឬកម្រិតអីទេ គ្រាន់តែដូចបានជម្រាបហើយ និយាយឮៗ ខំធ្វើការទាំងអស់គ្នាដើម្បីដោះស្រាយជីវភាពខ្លួនយើងទាំងអស់គ្នា។ មិនមានលើបុគ្គលណាមួយទេ ប៉ុន្តែការនិយាយហ្នឹងវានិយាយវា សម្ដីវាឮបន្តិច។ កាលណាមានមីក្រូទៅរឹតតែឮឡើង អ៊ីចឹងទៅបានប្រហែលជាបណ្ដាលឱ្យប្រជាពលរដ្ឋខ្លាច។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៤:៣៤:០៥]

**ស៖** បាទសូមអរគុណ។ ទាក់ទងនឹងសំណួរចម្លើយមុននេះ ពេលលោកមេធាវី កូប៉េ សួរលោក លោកបានឆ្លើយកន្លងមកថា នៅពេលដែលលោកទៅកាន់ការឃុំ ជាមេឃុំ លោកមិនដែលមានការចាប់ចងប្រជាជនទេ។ ប៉ុន្តែនៅពេលដែលលោកមេធាវី កូប៉េ សួរទាក់ទងទៅនឹងការចាប់ចងនេះ លោកឆ្លើយថាមានការចាប់ជាសម្ងាត់ស្ងាត់ៗពេលយប់។ លោកនៅចាំចំណុចនេះទេ? ខ្ញុំចង់សួរថាតើការចាប់ស្ងាត់ៗពេលយប់នេះ ចាប់នៅពេលដែលលោកធ្វើជាគណៈឃុំ ឬក៏ជាអំពើមួយ ជាការចាប់មុនពេលដែលលោកទៅដល់ដែលលោកសន្និដ្ឋានអំពីការចាប់ពីមុនលោកទៅធ្វើជាគណៈឃុំ?

**ឆ៖** ចំណុចនេះ ខ្ញុំបានជម្រាបពិតប្រាកដ។ ការចាប់នេះគឺកាលសម័យ តាយុន គេមានចាប់អីចឹងដែរ ខ្ញុំបានសាកសួរលួចសួរប្រជាជនទៅថា មានយប់ៗគេចាប់យកទៅបាត់ កាលពីសម័យតាយុនដែលនៅ។ ប៉ុនជំនាន់ដែលខ្ញុំទៅនៅស្រែរនោង មិនដែលមានចាប់ចង ឬបញ្ជូនមនុស្សទៅរៀនសូត្រទេសូមជ្រាប។

**ស៖** សូមឲ្យលោកបញ្ជាក់ម្តងទៀតថា លោកមិនដែលចាប់ចងប្រជាជនណាម្នាក់ ឬក៏បញ្ជូនទៅរៀនសូត្រ ឬក៏នៅក្នុងឃុំរបស់លោកទាំងមូលហ្នឹងគឺគ្មានការចាប់ចង គ្មានការបញ្ជូនទៅរៀនសូត្រទាល់តែសោះ ក្នុងរយៈពេលដែលលោកធ្វើជាគណៈឃុំនៅឃុំស្រែរនោងនេះ?

**ឆ៖** បាទ នៅឃុំស្រែរនោងចំពោះខ្ញុំគឺអត់មានទេ មានតែទៅធ្វើនៅទួលគ្រួស ជីកប្រឡាយ ជីកអីហ្នឹងឃើញមានបាត់ម្នាក់ ឬពីរនាក់អីចឹងដែរ ខ្ញុំមិនចាំច្បាស់ទេ។ កាលនោះគេគ្រប់គ្រងលើហ្នឹង គឺកងស្រុក និងកងតំបន់គេនៅត្រួតត្រាធ្វើទំនប់ទួលគ្រួស បាទនៅឃុំអូរសារ៉ាយឯណោះ។ ឆ្ងាយពីឃុំ ស្រែរនោង។

**ស៖** បាទ ចុះទាក់ទងនឹងឃុំស្រែរនោងនេះ លោកមានដឹងពីសមាសភាពដែលគេចាប់ ដែលលោកមិនបានជាប់ពាក់ព័ន្ធ ជាអ្នកបញ្ជាឬក៏មិនមែនជាអ្នកចូលរួមនៅក្នុងការចាប់ ប៉ុន្តែលោកបានដឹងថាមានការចាប់នៅពេលដែលលោកធ្វើជាគណៈឃុំហើយដែរទេ ចំពោះប្រជាពលរដ្ឋនៅឃុំស្រែរនោង?

**ឆ៖** ដូចខ្ញុំបានជម្រាបក្នុងសវនាការរួចហើយ ពីមុនហ្នឹងមាន តែក្រោយដែលខ្ញុំទៅកាន់កាប់ គឺអត់មានទេ។

[១៤:៣៧:៥៣]

**ស៖** បាទសូមអរគុណ ខ្ញុំយល់ច្បាស់ហើយ។ លោកអាចបញ្ជាក់បានទេថា ហេតុអីបានជាមាន

ភាពខុសគ្នារវាងការគ្រប់គ្រងរបស់អ្នកដទៃ ជាមួយការគ្រប់គ្រងរបស់លោកនៅក្នុងឃុំស្រែរនោងហ្នឹង?

**ឆ៖** ការគ្រប់គ្រងនេះ ទៅតាមចិត្តរបស់មនុស្សម្នាក់ៗ។ មនុស្សម្នាក់ៗចិត្តមិនដូចគ្នាទេ។ ដូចអ្នកគ្រប់គ្រងមុនអ៊ីចឹង ចិត្តគេវាហៅថាដាច់ខាត មហាលោតផ្លោះ មហាអស្ចារ្យអ៊ីចឹងទៅ។ ឯចិត្តខ្ញុំមានការអាណិតអាសូរ បណ្តើរៗ។ អ៊ីចឹងការគ្រប់គ្រងប្រជាពលរដ្ឋវាខុសប្លែកគ្នា។ នៅឃុំស្រែរនោង គឺខ្ញុំទទួលកិច្ចការរួមអ៊ីចឹងទៅ កិច្ចការអ្វីលើខ្ញុំ។ អាហ្នឹងកំណត់សន្និដ្ឋានអ្វីៗពាក់ព័ន្ធទាំងឡាយគឺលើខ្ញុំតែម្តង។ ហើយឃុំដទៃ ខ្ញុំជាសមាជិក គឺតាមគេប្រធាន។ បាទ សូមអរគុណ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់បញ្ជាក់ឡើងវិញទាក់ទងទៅនឹងចម្លើយរបស់លោក ដែលលោកបញ្ជាក់ថាការដឹកនាំខុសគ្នានេះ វាអាស្រ័យទៅលើបុគ្គលម្នាក់ៗអំពីទឹកចិត្តរបស់គេ។ ខ្ញុំចង់សួរលោកបញ្ជាក់បន្ថែមថា តើវាមានគោលការជារួម ឬក៏ការណែនាំជាការបញ្ជាពីថ្នាក់លើ ទាក់ទងទៅនឹងការគ្រប់គ្រងរដ្ឋបាលនេះដែរទេ រដ្ឋបាលក្នុងឃុំនេះ ឬមួយក៏ឃុំហ្នឹងមានសិទ្ធិសម្រេចទៅតាមឆន្ទានុសិទ្ធិរបស់បុគ្គលដែលមានសិទ្ធិសម្រេចទៅតាមឆន្ទានុសិទ្ធិរបស់បុគ្គលដែលជាមេឃុំម្នាក់ៗហ្នឹង?

[១៤:៤០:១៦]

**ឆ៖** បាទ ការនេះពិតណាស់ គឺបញ្ជាពីថ្នាក់លើ ពីមជ្ឈិមរហូតភូមិភាគ មកតំបន់ មកស្រុក។ ឯសំខាន់ខាងឃុំខ្លះក៏អាចមិនធ្វើតាមទាំងអស់ដែរ ពីព្រោះអ្នកនៅជាប់នឹងមូលដ្ឋាន ជាប់ជាមួយប្រជាពលរដ្ឋ ហើយបើធ្វើតាមកំណត់ពីថ្នាក់លើទាំងអស់ វាអាចហៅថាច្របូកច្របល់ក្នុងបញ្ហាហ្នឹង។ អ៊ីចឹងយើងមានវិធីលាក់ការណ៍ខ្លះ ដោះស្រាយដោយសម្រួលដោយសន្តិវិធីទៅ។ ឯឃុំដទៃអីគេច្រើនដាច់ខាត ប៉ុន្តែអាហ្នឹងបច្ចេកទេសលុះត្រាតែយើងដឹកនាំហ្នឹងមានយុទ្ធវិធីច្បាស់លាស់ក្នុងការគ្រប់គ្រងរបស់ប្រជាពលរដ្ឋ។ សូមអរគុណ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងនឹងសម្តីរបស់លោកអម្បាញ់មិញ លោកមានប្រសាសន៍ថាមានបញ្ហាពីថ្នាក់មជ្ឈិមចុះមក។ លោកដឹងថាជាបញ្ហាអ្វីទេដែលលោកមានប្រសាសន៍នេះថាជាបញ្ជាពីថ្នាក់លើមកហ្នឹង លោកអាចលើកឧទាហរណ៍មួយចំនួនទាក់ទងទៅនឹងបញ្ហាទាំងនោះបានទេ?

[១៤:៤១:៥៣]

**ឆ៖** បញ្ហាពីលើមកឲ្យយើងដឹកនាំនៅក្នុងសហករណ៍ ក្នុងឃុំនីមួយៗ ឲ្យខិតខំដោះស្រាយជីវភាពរបស់ប្រជាពលរដ្ឋ ធ្វើស្រែឲ្យបាន៣តោន ពីព្រោះម្យ៉ាងទៀតឲ្យសម្រេចការងារធ្វើយ៉ាងណាឲ្យបានក្នុងឆ្នាំ១៥ អង្គាល់នោះ គេប្រើដល់ឆ្នាំ១៥ហ្នឹងឲ្យបានដោះស្រាយប្រជាជនឲ្យបាន និងឲ្យមានប្រជា

ពលរដ្ឋកើនឡើង។ នេះខ្ញុំចាំបានតែប៉ុណ្ណឹងទេ។ ចំពោះឃុំណាដែលដោះស្រាយមិនបាន អាហ្នឹងគេថាមានបញ្ហាដោយស្នាក់ស្នើរមិនជ្រះស្រឡះជាមួយមាគ៌ារបស់បក្ស។ អ៊ីចឹងចំពោះរូបខ្ញុំភ័យខ្លាចដែរហ្នឹង។ ខំធ្វើការទាំងយប់ទាំងថ្ងៃ ហូបជាមួយប្រជាពលរដ្ឋអ៊ីចឹងទៅ។ បាទ ក្នុងរយៈកាលគ្រួសារដែលនៅជាមួយហ្នឹង គឺដល់ទៅប្រជាពលរដ្ឋមានកំណត់ថ្ងៃគេកំណត់អ៊ីចឹងទៅ បានទៅជួបគ្រួសារនៅបែកគ្នាដដែល ដោយសារខ្លាច។ សំខាន់ គឺខ្លាចតែម្តង។

**ស៖** បាទ--

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។

បាទ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៤ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០២:៥២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោក នួវ មុនសម្រាកយើងបានពិភាក្សាគ្នាអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្ត

កម្ពុជាដែលលោកមានប្រសាសន៍ទាក់ទងទៅនឹងគោលការណ៍ណែនាំអំពីការរកស្បៀងអាហារសម្រាប់ប្រជាជន។ ខ្ញុំចង់សួរលោកបន្ថែមទាក់ទងទៅនឹងបញ្ហាជំហរខុសគ្នារវាងកម្មាភិបាលដែលកាន់កាប់មូលដ្ឋាន ជាពិសេសនៅក្នុងថ្នាក់ឃុំរបស់លោក ដែលលោកបានបញ្ជាក់រួចហើយ។ ខ្ញុំចង់សួរបន្ថែមថា តើលោកបានដឹងអំពីការគ្រប់គ្រងនៅថ្នាក់ស្រុកទេ វាមានលក្ខណៈ ឬក៏ការប្រកាន់ជំហរខុសគ្នាដូចម្ដេចដែរ ចំពោះគណៈស្រុកនីមួយៗនោះ ហើយនិងរវាងពីស្រុកមួយទៅស្រុកនោះ មានភាគខុសគ្នាដូចម្ដេចដែរ លោកអាចបញ្ជាក់បានទេ?

[១៥:០៤:២៥]

**លោក នុត នូវ៖**

**ឆ៖** បាទ សូមអរគុណ។ បញ្ហានេះ ខ្ញុំមិនអាចបញ្ជាក់បានទេ នៅក្នុងស្រុកនីមួយៗ។

**ស៖** បាទ សូមអរគុណ។ ចុះបើប្រៀបធៀបចំពោះស្រុកទាំងឡាយ ដែលលោកបានធ្វើជាមួយពីព្រោះលោកធ្វើការនៅក្នុងឃុំផ្សេងៗ យ៉ាងហោចណាស់ក៏ចំនួនបីឃុំ។ តើលោកធ្វើការជាមួយនឹងកម្មាភិបាលថ្នាក់ស្រុក មនុស្សផ្សេងគ្នាដែរទេក្នុងចន្លោះពេលហ្នឹង?

**ឆ៖** ខ្ញុំបានចូលរួមមានមនុស្សផ្សេងគ្នានៅក្នុងស្រុកដូចបានជម្រាបខាងដើម។ ទី១ ដំបូងគឺ តាគាវ, ក្រោយមក តាជឹម, ក្រោយមកទៀតបាទ តាជឹម ហើយ<តាកិត> មានយក តាសាន ពី១០៨ មកហើយនិង -- បាទ ប៉ុណ្ណឹងនាក់តាមដែលស្គាល់។ តាជឹម <តាកិត> និងតាសាន។ បាទ សូមអរគុណ។

**ស៖** បាទ សូមអរគុណ។ ចុះលោកអាចយល់ពីជំហរពីការអនុវត្តការងាររបស់អ្នកទាំងអស់នោះទេ វាខុសគ្នាដូចម្ដេចដែរពីរវាងកម្មាភិបាលម្នាក់ទៅកម្មាភិបាលម្នាក់ទៀត? បាទសូមអធ្យាស្រ័យក្រែងលោកកអត់យល់សំណួររបស់ខ្ញុំ។ គឺសំណួររបស់ខ្ញុំ គឺផ្ដោតទៅលើការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលលោកបានមានប្រសាសន៍ពីខាងដើមរួចមកហើយបាទ។

**ឆ៖** បាទ ខ្ញុំមិនអាចសន្និដ្ឋានបានទេ ប៉ុន្តែតាមមើលពាក្យសម្ដីខាងក្រៅក្នុងការដឹកនាំហ្នឹង តាជឹម និងតាសាន ហ្នឹងមាត់ប្រែបន្តិចបាទ ព្រោះគាត់ប្រើបច្ចេកទេសច្រើន ព្រោះគាត់អនុធនសិស្ស ជាសាស្ត្រាចារ្យពីដើមផង តាសាន ហ្នឹង បាទគាត់និយាយរាងម៉ឺងម៉ាត់ប៉ុន្តែមានការលែងសើចធម្មតា អ៊ីចឹងទៅជួប ពេលជួប។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងគោលនយោបាយរបស់បក្ស តើលោកធ្លាប់ជួបប្រទះ ឬក៏ដឹងពីការណែនាំណាមួយដែលលោកយល់ថាជានយោបាយខុសឆ្គងមិនត្រឹមត្រូវដែលៗត្រូវឲ្យលោក

អនុវត្តដែរទេ ទាក់ទងទៅនឹងភារកិច្ចរបស់លោកជាគណៈឃុំ?

**ឆ៖** បញ្ហានេះ ខ្ញុំមិនអាចសន្និដ្ឋានបានទេ ព្រោះវាខ្វះជំនាញខាងគិតគូរសន្និដ្ឋានក្នុងការវិនិច្ឆ័យផ្សេងៗ។

[១៥:០៨:២២]

**ស៖** បាទ សូមអរគុណ។ ចុះទាក់ទងទៅនឹងបុគ្គលមួយចំនួន ជាពិសេសលោកបានធ្វើការប្រៀបធៀបក្នុងឃុំរបស់លោកដែលលោកមកធ្វើជាគណៈឃុំនៅឃុំស្រែរនោងក្រោយ ហើយមិនមានការចាប់ឬក៏ការបញ្ជូនទៅកសាងអីជាដើមហ្នឹង ហើយដែលលោកបានឆ្លើយបញ្ជាក់ថាមានបុគ្គលមួយចំនួនដែលអនុវត្តភាពដាច់ខាត។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា តើការអនុវត្តភាពដាច់ខាតនោះ គឺការអនុវត្តតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ឬមួយក៏ជាបុគ្គលដែលមិនគោរពតាមគោលនយោ-បាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលលោកបាននិយាយអំពីការខិតខំឲ្យរកស្បៀងអាហារជូនប្រជាជនជាដើមនេះបាទ?

**ឆ៖** បាទ បើតាមខ្ញុំយល់គឺវាជាចិត្តរបស់បុគ្គលម្នាក់ដែលគេមានគេហៅថាដាច់ខាតជាមួយបក្សកុម្មុយនីស្តកម្ពុជាផង ហើយជាចិត្ត។ ឧទាហរណ៍ដូចប្រៀបបានថាមកពីនោះប៉ុណ្ណោះ ដល់បុគ្គលអនុវត្តទៅលើសផែនការទៅទៀតបាទ។ នេះជាគំនិតចិត្តរបស់បុគ្គលមួយនោះទេ។

**ស៖** បាទសូមអរគុណ។ ខ្ញុំចង់មានសំណួរចុងក្រោយមួយទាក់ទងទៅនឹងគណៈប្រតិភូ។ ខ្ញុំបានសួរមុនហើយ ហើយលោកបានឆ្លើយថា មានគណៈប្រតិភូចិនមកចូលរួម។ ខ្ញុំចង់សួរបញ្ជាក់បន្ថែមទៀតថា តើក្នុងអំឡុងពេលដែលលោកនៅជាសមាជិកឃុំលាយបូរ លោកដែលឃើញ ប៉ុល ពត ដឹកនាំគណៈប្រតិភូមកសហករណ៍ ឬក៏ក្នុងឃុំលាយបូររបស់លោកដែរទេ?

**ឆ៖** បាទខ្ញុំមិនដែលឃើញ ប៉ុល ពត មកទេ ប៉ុនអង្កាល់មកទស្សនកិច្ចហ្នឹង គឺឮ តាសាន គាត់និយាយថា អៀង សារី ហើយ អៀង សារី ហ្នឹង ខ្ញុំមិនដែលស្គាល់មុខផង គ្រាន់តែឃើញមនុស្សពីរបីនាក់ហ្នឹង ប៉ុន្តែ តាសាន គាត់ប្រាប់ខ្ញុំថា តា អៀង សារី! នេះសូមជ្រាប។

**ស៖** បាទសូមអរគុណ។ ចុះលោក ខៀវ សំផន! លោកធ្លាប់ឃើញលោក ខៀវ សំផន មកចូលរួមនៅក្នុងគណៈប្រតិភូណាមួយ ទស្សនកិច្ចក្នុងសហករណ៍ ឬក៏ឃុំលាយបូររបស់លោកដែរទេ?

[១៥:១១:៥៨]

**ប្រធានអង្គជំនុំ៖**

សាក្សី កុំអាលទាន់ឆ្លើយតប។

**លោក នុត នូវ៖**

**ឆ៖** បាទលោក ខៀវ សំផន ខ្ញុំឮតែឈ្មោះ បាទថា ខៀវ សំផន ៗហ្នឹង ប៉ុន្តែមិនដែលបានឃើញ ឬបានស្គាល់ទេ គ្រាន់តែឮតែឈ្មោះបាទ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទសូមអរគុណ។ ទាក់ទងទៅនឹងទស្សនកិច្ចសំណួររបស់ខ្ញុំថា តើលោក ខៀវ សំផន ធ្លាប់មកទស្សនកិច្ចក្នុងសហករណ៍លាយបូរ ឬក៏ឃុំលាយបូររបស់លោកហ្នឹងដែរទេ ក្នុងអំឡុងពេលដែលលោកធ្វើជាសមាជិកឃុំលាយបូរនោះ?

**ឆ៖** បាទមិនដែលមកទេ។

**លោក គង់ សំអុន៖**

បាទសូមអរគុណ។ សាក្សី ខ្ញុំអស់សំណួរ។ លោកប្រធាន សូមសហភាគារបស់ខ្ញុំបន្តបាទ។

[១៥:១២:៥៣]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ លោកមេធាវី។ សូមអញ្ជើញ លោក វែកគែន !

**លោក អាកទូរ វែកគែន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំជា<សហ>មេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។ ខ្ញុំមានសំណួរខ្លីទេ ដើម្បីបញ្ចប់សវនាការយើងនៅថ្ងៃនេះ។ កាលពីអម្បាញ់មិញនេះលោកបានឆ្លើយថា បក្ស បានសុំឲ្យលោកបង្កើនចំនួនប្រជាជន ហើយនិងផ្តល់អាហារហូបចុក។ បន្ទាប់មកលោកនិយាយអំពីកម្មាភិបាលដែលមាន "អំណាចដាច់ខាត"។ នេះជាពាក្យដែលខ្ញុំស្តាប់ឮជាភាសាបារាំង។ អ៊ីចឹងខ្ញុំចង់ដឹងថាតើអ្នកដែលមានអំណាចដាច់ខាតនេះ <>ធ្វើតាមមាគ៌ានយោបាយបក្ស គឺថា<ការណែនាំឲ្យ>បង្កើនចំនួនប្រជាជន <និងផ្តល់របបអាហារដល់ប្រជាជន>ឬក៏<ពួកគេអនុវត្ត>ខុសពីមាគ៌ាបក្ស<ដែរឬ>ទេ?

**ឆ៖** អ្នកដែលធ្វើហ្នឹង គឺគេធ្វើតាមមាគ៌ារបស់បក្ស គេដាច់ខាតជាមួយបក្ស សូមជ្រាប។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៥:១៤:២០]

**ស៖** អ៊ីចឹងហេតុអីបានជាលោកនិយាយថាអ្នកទាំងអស់<នោះ>មានអំណាចដាច់ខាត<>? តើលោកចង់មានន័យថាម៉េចដែរដែលប្រើពាក្យថា "ដាច់ខាត"ហ្នឹង?

**ឆ៖** ខ្ញុំបានជម្រាបរួចហើយថា អ្នកដែលដាច់ខាតហ្នឹង គេដឹងការងារពីលើមកប៉ុន្មានគេធ្វើប៉ុណ្ណឹងណា៎! សូមជ្រាប។

**ស៖** ក៏ប៉ុន្តែអ្វីដែលខ្ញុំមិនយល់ច្បាស់នោះគឺថា ប្រសិនបើយើងនិយាយអំពី<>មាគ៌ាបក្សហ្នឹង ដើម្បីបង្កើនចំនួនប្រជាជន និងឲ្យប្រជាជនហូបចុក<សមរម្យ>នោះ<>អ៊ីចឹងមានន័យថាអំណាចដាច់ខាតនោះ ជាៗរឿងល្អទេ<។> អ្វីដែលលោកចង់និយាយ<គឺចង់មានន័យអ៊ីចឹងមែនដែរឬទេ>?

**ឆ៖** បាទ ពិតហើយ។

**ស៖** លោកសាក្សីខ្ញុំចង់ត្រឡប់មកនិយាយអំពីការ<ដែលលោក>ប្រឡូកក្នុងនយោបាយ<>។ កាលពីឆ្នាំ២០០៩ នៅពេលដែលអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតសួរលោកនោះ លោកបានឆ្លើយថាលោកត្រូវបានគេតែងតាំងជាមេ<ក្រុមប្រវាស់ដៃ>នៅពេលដែលខ្មែរក្រហមចូលមកដល់នៅក្នុងតំបន់របស់លោក<រស់នៅ>។ អ៊ីចឹង ខ្ញុំចង់ដឹងថាហេតុអ្វីបានជាគេជ្រើសលោកយក<> លោក<?> តើលោកធ្លាប់ពីមុនមកធ្លាប់ធ្វើនយោបាយស្និទ្ធជាមួយនឹងខ្មែរក្រហមទេ<?> ឬក៏<លោកមាននិន្នាការមនោគមន៍វិជ្ជាទៅខាងខ្មែរក្រហម? ឬក៏>មានមូលហេតុផ្សេងទៀត ដែលគេចាត់តាំងលោកជាមេក្រុមនោះ?

**ឆ៖** បាទ កាលជំនាន់នោះគេចាត់តាំងជាមេក្រុម គឺពីដើមមកខ្ញុំមិនដែលមានចូលប្រឡូក ក្នុងនយោបាយរបស់ពួកខ្មែរក្រហមទេ ប៉ុន្តែមកដល់កាលនោះគេជ្រើសរើស១២គ្រូអ៊ីចឹងគេរកអ្នកដែលមានសមត្ថភាពចេះសរសេរ ចេះអាន ទៅវាឲ្យធ្វើជាមេក្រុមដឹកនាំក្រុមការងារប្រវាស់ដៃ បាទ។

[១៥:១៧:៣៥]

**ស៖** តើត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថា ក្រុមប្រវាស់ដៃនេះ គឺជា<ជាអ្វីដែលកើតមុន> សហករណ៍<នោះមែនដែរឬទេ>?

**ឆ៖** នេះកើតមុនសហករណ៍បាទ គឺគេរៀបចំដោយយោងកាលនោះ មានប្រជាជនកូនចៅធ្វើទ័ព អ៊ីចឹងទៅម៉ែឪចាស់ជរា អ៊ីចឹងគេរៀបចំធ្វើប្រវាស់ដៃ។ ឯកម្មសិទ្ធិដីធ្លីនៅដដែលទេ គេមិនទាន់ប្រមូលទេកាលនោះ ប្រវាស់ដៃហ្នឹងបាទ។

**ស៖** ដូច្នេះ ខ្មែរក្រហមហ្នឹង តែងតាំងលោកជាមេក្រុមហ្នឹងគឺថាអត់មានហេតុផល<អ្វីជាងហ្នឹង>ទេ<។> ហើយចំពោះលោកផ្ទាល់ហ្នឹងក៏លោកមិនយល់ដែរ ថាហេតុអ្វីបានជាគេចាត់តាំងលោកឲ្យធ្វើជាមេក្រុមនោះ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ពេលនោះ ក្រោយពីរដ្ឋប្រហារសម្តេចសីហនុទៅនៅតំបន់នោះគឺខ្មែរក្រហមចូលកាន់កាប់ អត់មានទាហានលន់នល់ទេ គឺខ្មែរក្រហមកាន់កាប់ នៅតំបន់ខ្ញុំអ៊ីចឹងគេរៀបចំទាំងបង្ខំទេ ឲ្យធ្វើមេកងដឹកនាំហ្នឹង បាទ។ ហើយយើងខ្លាចគេចេះតែធ្វើទៅ។

**ស៖** <អគុណលោកណាស់។> ដូច្នេះ <ដើម្បីឲ្យកាន់តែច្បាស់នោះ>គឺថាលោកមិនដឹងទេថាមូលហេតុអ្វីបានជាគេជ្រើសរើសយកលោកនោះ<ទេ> អ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំមិនបានដឹងទេ។ គេមកដល់គេចាត់តាំងអ៊ីចឹងទៅ គេរើសឲ្យធ្វើអ៊ីចឹងទៅ។

**ស៖** តើ<ត្រឹមត្រូវដែរទេ>ក្រុមប្រវាស់ដៃនេះមានភារកិច្ច<>ចែក<ស្បៀង>អាហារទៅឲ្យប្រជាជន<>?

**ឆ៖** ក្រុមប្រវាស់ដៃនេះ មានការចែកផល បាទផលស្រូវដែលធ្វើបាន ប៉ុនកាលនោះនៅហូបឯកជនទៅតាមគ្រួសារទេ។ ប្រជាជនហ្នឹងគេចែក ប្រជាជនកម្លាំងទី១ មានកម្លាំងទី២ និងកម្លាំងទី៣ បាទ ចែកទៅតាមប្រភេទកម្លាំង។ ទី១ បានពេញទៅ, ទី២ បានជាងពាក់កណ្តាល, ទី៣ បាទ បានតិចអ៊ីចឹងទៅ តាមជាក់ស្តែង។

[១៥:២១:១៦]

**ស៖** <តើលោកបានស្បៀងអាហារច្រើននៅពេលលោកពេញកម្លាំង ឬក៏លោកបានស្បៀងអាហារច្រើននៅពេលដែលលោកខ្សោយកម្លាំង>?

**ឆ៖** បាទ ពិតប្រាកដណាស់ គឺអ្នកពេញកម្លាំងបានស្រូវហ្នឹងច្រើនជាងគេ។ គេប៉ាន់ប្រមាណស្រូវបានប៉ុន្មានក្នុងមួយក្រុមហ្នឹងអ៊ីចឹងទៅ គេចែកទៅតាមជាក់ស្តែង។

**ស៖** នៅពេលដែលសហចៅក្រមស៊ើបអង្កេតសួរលោកនៅឆ្នាំ២០០៩ លោកបានលើកឡើងអំពីការលំបាកពាក់ព័ន្ធទៅនឹងការបែងចែកផលស្រូវនៅក្នុង<ក្រុម>ប្រវាស់ដៃនេះ។ លោកបានឆ្លើយថាប្រព័ន្ធបែងចែកនេះគឺវាមិន<ស្មើភាព>គ្នា<ទេ>។ អ៊ីចឹង តើលោកអាចពន្យល់បានទេ ដែលលោកថាប្រព័ន្ធបែងចែក<>ភោគផលហ្នឹងវាមិនមានភាពស្មើគ្នា<អ៊ីចឹង>?

[១៥:២២:៥៥]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ បញ្ហានេះ ដូចខ្ញុំបានជម្រាបថាអ្នកដែលគេកម្លាំងពេញ គ្នាតិច ប៉ុន្តែគេបានភោគផលច្រើន ឯអ្នកបានភោគផលតិច គ្នាច្រើន ប៉ុន្តែកម្លាំងពលកម្មតិច អ៎! ពលកម្មហ្នឹងចូលរួមជាមួយគេតិច។ បាទ មានក្មេងច្រើនអីចឹងទៅ កូនចៅវាច្រើន នៅតូចៗមិនអាចធ្វើបាន អីចឹងសរុបផលទៅបានតិចជាងអ្នកដែលមានកម្លាំងតិច គេសុទ្ធតែមនុស្សពេញកម្លាំង។ បាទ សូមអរគុណ។

**ស៖** តើពេលនោះមានការស្វែងរកដំណោះស្រាយ<ចំពោះ>បញ្ហាហ្នឹងទេ? ហើយប្រសិនបើមាននោះ បើតាមការសង្កេតរបស់លោក<>តើគេ<ដោះ>ស្រាយ<ការបែងចែកស្មៀងមិនស្មើគ្នានោះដោយរបៀបណា>?

**ឆ៖** កាលជំនាន់នោះ ដូចគ្នាអីដំណោះស្រាយទេ ព្រោះប្រទេសនៅសង្គ្រាមជាមួយ លន់ នល់។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី សំណួរហ្នឹងដូចជាក្រៅអង្គហេតុទេ ក្រៅយុត្តាធិការចោទប្រកាន់ណាស់។ សូមមេធាវីតម្រង់នូវសំណួរដែលពាក់ព័ន្ធជាមួយនឹងអង្គហេតុ ហើយនៅក្នុងវិសាលភាពនៃយុត្តាធិការពេលវេលា ១៧ មេសា ៧៥ រហូតដល់ថ្ងៃ០៦ មករា ៧៩។ នេះជាអង្គហេតុពេលវេលា ដែលត្រូវដោះស្រាយនៅក្នុងសាលាក្តីនេះ។

[១៥:២៤:០៥]

**លោក អាកទូរ វែកកែន៖**

បាទ គឺខ្ញុំចង់ធ្វើអីចឹងហើយលោកប្រធាន <គឺ>នៅ<>សំណួរបន្ទាប់ទៅទៀតនេះ។

**សួរដោយលោក អាកទូរ វែកកែន៖**

**ស៖** លោកសាក្សីតើ<លោកយល់ថា>ការបង្កើតសហករណ៍<>គឺថាមានគោល<បំណង>ដើម្បីដោះស្រាយបញ្ហាលំបាកក្នុងការបែងចែក<ភោគផល>គ្នា<នៅក្នុងក្រុមប្រវាស់ដៃ>នោះ<មែនដែរឬទេ បើតាមលោកជួបប្រទះនោះ?>

**លោក នុត នូវ៖**

**ឆ៖** ការបង្កើតជាសហករណ៍ ខ្ញុំមិនបានយល់ផងដែរទេ ដោយថ្នាក់លើគ្រាន់ឱ្យរៀបចំហូបបាយរួមគ្រាន់តែដឹងថាឱ្យហូបបាយរួម ពីព្រោះប្រជាពលរដ្ឋកាលជំនាន់នោះមានកូនចៅទៅធ្វើទ័ពអីចឹងទៅ អ្នកនៅសមរភូមិក្រោយឪពុកម្តាយចាស់អីចឹងទៅ បានគេឱ្យហូបបាយរួម ហើយមានប្រជាជនជម្លៀសមកពីទីក្រុងទៀត។ អីចឹងបានហូបបាយរួមទៅ គឺជីវភាពវាស្មើភាពគ្នាតាមគ្រួសារនីមួយៗ។

កាលយើងនៅប្រវាស់ដៃភោគផលមិនស្មើគ្នា ហូប អ្នកខ្លះមានម្ហូបទៅ អ្នកខ្លះក៏មិនអាចដើររកម្ហូបដោយខ្លួនឯងដោយយោងទៅតាមមនុស្សចាស់ ក្នុងក្រុមគ្រួសារហ្នឹងច្រើនមិនអាចរកម្ហូបបាន ហើយយើងជាអ្នកកាន់ព្រះពុទ្ធសាសនាកាលជំនាន់នោះ អ៊ីចឹងមិនអាចដើររកត្រីសាច់អីបានដូចគេអ្នកមានកម្លាំងពលំហើយនៅក្មេងទេ។ សូមអរគុណ។

**ស៖** តើនៅពេលដែលគេហូបរួមមកនោះ គឺមានន័យថា<ការបែងចែក>របបអាហារហ្នឹងគឺមានលក្ខណៈ<ស្មើភាពគ្នា ដែរឬ>ទេ?

**ឆ៖** បាទ ឃើញថាប្រជាពលរដ្ឋមានការហូបពិតប្រាកដមែន។ និយាយនេះគឺបានហូបរួមស្មើភាពគ្នាទាំងអស់គ្នា។

**ស៖** ដូច្នេះ <ការ>បែងចែករបប<អាហារ>នេះ មាន<លក្ខណៈ>ប្រសើរជាងមុន។ <ត្រឹមត្រូវដែរឬ>ទេ?

**ឆ៖** ប្រៀបធៀបការហូបចុក ការនៅហូបឯកជន អ្នកខ្លះ -- ដល់មកបែរជាហូបរួមវិញ អ្នកខ្លះគេថាហូបឯកជនស្រួលជាង អ្នកខ្លះដែលគ្មានកម្លាំងពលំនោះថាហូបរួមស្រួលជាង។ អ៊ីចឹង ខ្ញុំមិនអាចសន្និដ្ឋានថាត្រឹមត្រូវយ៉ាងម៉េចយ៉ាងម៉ាបានទេ។

[១៥:២៩:០៨]

**ស៖** បាទ សូមអរគុណ។ ឥឡូវនេះ ខ្ញុំចូលទៅប្រធានបទផ្សេងពាក់ព័ន្ធទៅនឹងឈ្លបឃុំ<តែគេបកប្រែអ៊ីចឹងថា "ឈ្លបឃុំ"> ហើយនិងការចាប់ខ្លួនមនុស្ស។ នៅក្នុងកំណត់ហេតុឆ្នាំ២០០៩នោះលោកបានប្រើពាក្យថា "ឈ្លប" នោះគឺជា<>"សន្តិសុខ" <ផងដែរ តែស្ដាប់ទៅដូចចម្លែក>។ ខ្ញុំចង់ដឹងថា <ពេលមានសំបុត្របញ្ជាឲ្យចាប់ខ្លួន>តើ<នរណា>ជាអ្នក<ទទួល>សំបុត្រ<នោះ>? <តើសំបុត្របញ្ជានោះផ្ញើទៅកាន់ទៅឈ្លបផ្ទាល់តែម្ដងឬក៏យ៉ាងម៉េចដែរ? ខ្ញុំជឿថា>លោក<បាន>ឆ្លើយនៅក្នុងកំណត់ហេតុ<នៃការស្ដាប់ចម្លើ>របស់លោក<ហើយ>។<>

**ឆ៖** បាទ នេះជាការពិតណាស់។

**ស៖** អ៊ីចឹងតើសំបុត្រហ្នឹងចេញមកពី<នរណា>?

**ឆ៖** សំបុត្រខ្ញុំមិនបានឃើញទេ គ្រាន់តែអាចចេញពីចៅហ្វាយស្រុក ឬចេញពីសន្តិសុខៗ។ អានេះតាមខ្ញុំប៉ាន់ទេ មិនមានឃើញពិតប្រាកដចេញពីអ្នកណាឈ្មោះណាទេ។

**ស៖** អ្វីដែលធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលនោះគឺថា នៅក្នុងកំណត់ហេតុ<នៃការស្ដាប់>ចម្លើយលោកនៅ

ឆ្នាំ២០០៩ គឺ<ឯកសារ>E3/5521 នៅសំណួរចម្លើយ៤២ គេសួរលោកថា<>ហេតុអ្វីបានលោកដឹង<បើថាលោកមិនបានឃើញ>លិខិតទាំងអស់ហ្នឹង<ផង។ លោកឆ្លើយ> ឥឡូវខ្ញុំសូមដកស្រង់៖<“ឆ.> ៤២៖ ខ្ញុំដឹងដោយឈ្លប<>ជាអ្នករាយការណ៍ប្រាប់ឃុំ”។ <ចប់ការដកស្រង់។> ដូច្នេះខ្ញុំចង់ដឹងថាហេតុអីបានជាឈ្លប<មិន>របាយការណ៍<>ទៅអ្នកដែលចេញបញ្ជាឲ្យចាប់នោះ <ជាជាងរាយការណ៍ឲ្យឃុំដែលមិនដឹងរឿងអ្វីផងនោះ>?

**ឆ៖** បញ្ហានេះ របាយការណ៍ឈ្លបឃុំរាយការណ៍មកឃុំមួយសន្លឹក រាយការណ៍ទៅខាងសន្តិ-សុខមួយសន្លឹក។ អាហ្នឹងគេឲ្យខាងឃុំដឹងអំពីសភាពការណ៍នៅក្នុងឃុំ។

**ស៖** ហើយខាងសន្តិសុខ<ដែលលោកនិយាយហ្នឹងគឺជាសន្តិសុខ>ស្រុកមែន<ដែរឬ>ទេ<>?

**ឆ៖** ខាងសន្តិសុខអ្នកគ្រប់គ្រងទទួលបន្ទុក។ កាលនោះ ខ្ញុំមិនបានដឹងស្រុក ឬតំបន់ទេ។ ប៉ុន្តែដឹងថានៅក្រាំងតាចាន់។ មិនដឹងច្បាស់ថាអ្នកណាអ្នកទទួល ប៉ុនការពិត គឺនៅស្រុកត្រាំកក់។

**ស៖** បាទ សូមអរគុណ។ ខ្ញុំនឹង<ត្រឡប់មក>និយាយអំពី<របបហូបវិញ>។ កម្មាភិបាលមូលដ្ឋានដូចជា<រូប>លោក<> តើលោកទទួលបានរបបអាហារដូចប្រជាជនដទៃទៀតដែរឬទេ? <គឺថាដូចពលករនៅក្នុងកងអីចឹងដែរឬទេ?>

[១៥:៣៣:៤២]

**ឆ៖** កម្មាភិបាល និងប្រជាជន គឺហូបបាយនៅក្នុងសហករណ៍តែមួយ គឺបានសេចក្ដីថាហូបដូចគ្នា។ មានពេលពិសេសដូចជាប្រជុំអីចឹងទៅមានលើសដែរម្ហូបអាហារ។

**ស៖** <តើរបប>លើសហ្នឹង គឺគេសម្រាប់តែកម្មាភិបាលទេ អីចឹងមែនទេ?

**ឆ៖** បាទ វាពិតប្រាកដហើយសម្រាប់ពេលប្រជុំ មានការងារតិចតួចតិចទេ លើសហ្នឹងមិនមានជាញឹកញាប់ទេ។

**ស៖** តើលោកធ្លាប់ឮគេនិយាយអំពីទីផ្សារ<ងងឹតដើម្បីទិញអាហារ>នៅ<>របបខ្មែរក្រហម<ដែរឬទេ>? មានន័យថាវាជាការ<>ដោះដូរអាហារហ្នឹងដោយសម្ងាត់។

**ឆ៖** បាទ ខ្ញុំអត់ធ្លាប់ឮទេ បញ្ហាហ្នឹង។

**ស៖** លោកបាន<ជម្រាបអង្គជំនុំជម្រះ> -- <ខ្ញុំត្រឡប់មកក្រោយបន្តិច ដោយសារ គេប្រាប់ខ្ញុំថាសំណួរ>ពាក់ព័ន្ធទៅនឹងទីផ្សារងងឹតហ្នឹងមិនច្បាស់ទេ។ អីចឹង ខ្ញុំសួរឡើងវិញដើម្បីឲ្យច្បាស់។ ខ្ញុំចង់ដឹងថានៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យចន្លោះពីឆ្នាំ<១៩៧៥ ដល់ ឆ្នាំ១៩៧៩> នៅក្នុងឃុំបី

ដែលលោកបាន<ទៅធ្វើការ>ហ្នឹង តើលោកធ្លាប់ស្ដាប់ឮគេនិយាយអំពី<>ការលួចដោះដូរអាហារ<ដែរឬទេ? តើមានការដោះដូរម្ហូបអាហារ>ជាមួយនឹងវត្ថុផ្សេងៗ<ដែរឬទេ? តើមានសកម្មភាពបែបនោះកើតឡើងដែរឬទេ?> យើងដឹងហើយថាពេលនុ៎ងគឺអត់មានលុយ<>ទេ អ៊ីចឹងខ្ញុំចង់ដឹងថាតើ<គេមានប្រើប្រាស់អ្វីដើម្បីដូរយក>អាហារហូបចុកនោះ?

**ឆ៖** បាទ ខ្ញុំមិនដែលបានឮ បាទ។

[១៥:៣៦:៣០]

**ស៖** នៅក្នុងសវនាការនេះ ក៏ដូចជាចំពោះមុខអ្នកស៊ើបអង្កេត លោកបាននិយាយថា លោកលាក់ភោគផលដែលនៅសល់មួយផ្នែកនៅក្នុងឃុំរបស់លោក។ អ៊ីចឹងខ្ញុំចង់ដឹងពីរបៀបដែលលោកធ្វើពីព្រោះលោក<>ថាលោកត្រូវរាយការណ៍ពាក់ព័ន្ធទៅនឹងការបង្កបង្កើនផលស្រូវទៅថ្នាក់ស្រុក<ផង>។ <លោករៀបរាប់>ថាលោកភូតកុហកនៅក្នុងរបាយការណ៍ហ្នឹង <តែ>ខ្ញុំគិតថា<ប្រាកដជាមានអ្នកមកពីថ្នាក់ស្រុកមក>ពិនិត្យ<មើលជាពុំខាន។ ជាក់ស្ដែង តើលោកអាចលាក់ស្រូវដែលមិនរាយការណ៍នោះ>យ៉ាងម៉េចទៅ? <>

**ឆ៖** បាទ ស្រូវដូចខ្ញុំបានជម្រាបពីព្រឹកមិញហើយ។ ឧទាហរណ៍ថាដូចធ្វើបាន១០០០ អ៊ីចឹងទៅក្នុងវស្សាឆ្នាំនីមួយៗហ្នឹងទៅ ខ្ញុំរាយការណ៍ទៅលើតែ៧០០ប៉ុណ្ណឹង។ ឯកសារលាក់ទុកនេះ ទុកក្នុងជង្រុកហើយគ្មាននរណាមកពិនិត្យទេ ខាងស្រុកក្ដី ខាង -- អត់ដែលមកពិនិត្យទេ។ យើងទុកតាមកងនីមួយៗសម្រេចទុកប៉ុន្មានសម្រាប់ដោះស្រាយប្រជាពលរដ្ឋហ្នឹង ស្រូវហ្នឹង ស្រូវដែលយើងលាក់ហ្នឹងទុកជាមួយគ្នាដើម្បីឱ្យប្រជាពលរដ្ឋបានហូបគ្រប់គ្រាន់ ប៉ុន្តែបើខាងលើដឹង -- បាទ ខ្ញុំខ្លាចតែខាងលើដឹង។ ប៉ុន្តែដូចខ្ញុំបានជម្រាបថាប្រជាពលរដ្ឋនៅកន្លែងនោះ គឺរាប់អានស្រឡាញ់ខ្ញុំ ក្នុងការដែលមានការលាក់ទុកស្រូវនេះ ហើយខាងស្រុកមិនដែលចុះទៅពិនិត្យទេ។ យើងរាយការណ៍ប៉ុន្មានគឺប៉ុណ្ណឹងហើយ។

[១៥:៣៨:៤៣]

**ស៖** ខ្ញុំយល់ច្បាស់ពីចំណុចនេះ ក៏ប៉ុន្តែនៅក្នុងកំណត់ហេតុ<នៃការស្ដាប់ចម្លើយ>ដដែលហ្នឹង គឺ E3/5521 គឺនៅក្នុង<សំណួរ>ចម្លើយ៨១ លោកពន្យល់ថាថ្នាក់ស្រុកមក<រកមើល>ស្រូវ បន្ទាប់ពីលោករាយការណ៍អំពីភោគផលស្រូវដែលធ្វើបាន<>។ អ៊ីចឹងហើយបានជាខ្ញុំសួរសំណួរលោកបែបហ្នឹងនោះ បើសិនស្រុកមក<រក>ស្រូវពីឃ្លាំងនោះ ហើយលោក<ទុកស្រូវដែល>មិនបានរាយការណ៍<នៅឃ្លាំងនោះដែរ។> អ៊ីចឹងមានន័យថាថ្នាក់ស្រុកហ្នឹងក៏<>ធ្វើខ្វាក់<ទៅនឹងទង្វើរបស់លោក ឬគេមិនដឹង

ឬក៏លោកលាក់ស្រូវនោះនៅកន្លែងផ្សេងទៀត>។ <តើ>លោកអាចពន្យល់ឲ្យបានច្បាស់បន្តិច<>អំពីរបៀបដែលលោកលាក់ស្រូវនេះ<ផងបានដែរឬទេ>?

**ឆ៖** បាទ ស្រូវនេះក្រោយមកខាងស្រុក ឬតំបន់ទៅយកហ្នឹងតាមរបាយការណ៍ដែលគេកំណត់បែងចែកថាឃុំនេះប្រជាពលរដ្ឋប៉ុណ្ណោះ អាចទទួលភោគផលប៉ុណ្ណោះ ត្រូវយកទៅប៉ុណ្ណោះ។ អ៊ីចឹងគេទៅប្រមូលស្រូវហ្នឹង គឺគេយកកំណត់ស្រូវដែលគេកំណត់ថាប៉ុន្មាន យកប៉ុន្មានរយៗអ៊ីចឹងទៅ តែប៉ុណ្ណឹងទេ គេអត់មានដល់ឆែកឆេរអីមើលទេ។

**ស៖** ខ្ញុំចង់ឲ្យ<ប្រាកដថាខ្ញុំ>យល់ច្បាស់អំពី<ចម្លើយរបស់លោក>។ លោកកំពុងតែនិយាយថាគេដឹងពីបញ្ហារបស់លោក ហើយ<> ថ្នាក់តំបន់ <ឬថ្នាក់ស្រុកបាន>មកយកស្រូវដែលលោកមិនបានរាយការណ៍ទៅខាងគេ។ អ៊ីចឹងមែនទេ?

**ឆ៖** សូមបញ្ជាក់ម្តងទៀតមិនច្បាស់សំណួរនេះ។ ស្តាប់មិនបានច្បាស់។

**ស៖** ខ្ញុំសួរអំពីរបៀបរបបនៃការអនុវត្តដែលលោកលាក់ស្រូវនេះ មួយភាគដែល<>ឃុំ<ធ្វើបាន>ដើម្បី<ទុក>ឲ្យប្រជាជន<ហូប>។ លោកបានឆ្លើយថា លោកបានធ្វើរបាយការណ៍ទៅថ្នាក់ស្រុក< ដើម្បីលាក់ស្រូវទុកខ្លះ លោករាយការណ៍ថាទិន្នផលបានតិចជាងទិន្នផល>ជាក់ស្តែង<ដែលឃុំធ្វើបាន>។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើលោកលាក់ទុក<ស្រូវសល់នោះនៅ>កន្លែងណា? <>លោកបានឆ្លើយថាស្រូវហ្នឹងនៅក្នុងឃ្លាំង<ជាមួយគ្នានឹងស្រូវដែលលោករាយការណ៍ទៅលើ> ហើយលោកក៏ឆ្លើយផងដែរថាថ្នាក់ស្រុកហ្នឹង មក<>យកស្រូវដែលបានរាយការណ៍។ អ៊ីចឹងនៅពេលដែលថ្នាក់ស្រុកចុះមកយកស្រូវនោះ ខ្ញុំគិតថាថ្នាក់ស្រុកគេអាចសង្កេតឃើញ<ថា>លោកលាក់<>ស្រូវ <ហើយគេប្រាកដជាសួរនាំលោកពីស្រូវដែលនៅសល់នោះជាពុំខាន>។ អ៊ីចឹងខ្ញុំ<សួរលោកថា>លោកលាក់<ស្រូវនោះដោយ>របៀប<ណា>?

[១៥:៤២:៥២]

**ឆ៖** ខ្ញុំចង់បញ្ជាក់ឲ្យកាន់តែច្បាស់។ ស្រូវ ដូចខ្ញុំបានជម្រាបរួចហើយពីខាងដើម។ អ៊ីចឹងស្រូវហ្នឹងយើងទុកទៅតាមឃ្លាំង ឃ្លាំងតាមសហករណ៍នីមួយៗ។ អ៊ីចឹងខាងស្រុកគេ ហៅថាមានតួលេខគិតគូរស្រូវដែលត្រូវដោះស្រាយជីវភាពប្រជាជននិងស្រូវដែលកំណត់យកទៅឲ្យតំបន់។ អ៊ីចឹង គេមកដឹកតែស្រូវគេហ្នឹងទេ កងនារី កងចល័តអី ឡានមក ថាឃុំស្រែរនោងហ្នឹង យក២០០តោន អ៎! យក១តោន អ៊ីចឹងទៅគេយកតែប៉ុណ្ណឹង។ ឯស្រូវនៅហ្នឹងគេដឹងសន្និដ្ឋានថាទុកដោះស្រាយប្រជាពលរដ្ឋហើយ។ បាទ

សូមអរគុណ។

**ស៖** <ខ្ញុំយល់ចម្លើយរបស់លោកច្បាស់ហើយ ខ្ញុំគ្រាន់តែសង្ខេបឡើងវិញដូចតទៅថា> អ្នកដែលមកយកស្រូវហ្នឹងគឺមិនខ្វល់ថាស្រូវមានប៉ុន្មាន <ដែលនៅសល់នោះ>ទេ។ <តើត្រឹមត្រូវដែរឬ>ទេ?

[១៥:៤៤:២០]

**ឆ៖** បាទ គេមិនតាមយកស្រូវដែលរាយការណ៍ទាំងអស់ទេ គឺគេយកតែស្រូវដែលគេកំណត់ថាក្នុងឃុំមួយនេះយកប៉ុន្មានប៉ុណ្ណឹងទេ។

**ស៖** ខ្ញុំប្រធានបទពីរទៀតដើម្បីពិភាក្សាជាមួយលោក។ ទី១ ពាក់ព័ន្ធនឹង "ទង់បដិវត្ត"។ តើលោកអាចជម្រាប<អង្គជំនុំជម្រះ>បានទេថាទង់បដិវត្តហ្នឹងជាអ្វី<>? <តើលោកបានទទួលវាជាញឹកញាប់ដែរឬទេ? ឬក៏លោកទទួលបានវា>ម្តងម្កាល<ដែរ>?

**ឆ៖** ការពិតទៅទង់បដិវត្តនេះ ខ្ញុំមិនអាចដែលបានឃើញទេ ហើយក៏មិនអាចយល់ដែរ។

**ស៖** បើទោះបីជាលោកមិនដឹងថាទង់បដិវត្តហ្នឹងគេប្រើសម្រាប់អី<ក៏ដោយ> ក៏លោកដឹងដែរថាទង់បដិវត្តហ្នឹងជាអ្វី<ដែរ មែនដែរឬទេ>?

**ឆ៖** បាទ មិនអាចដឹងជាអ្វីទេ ខ្ញុំធ្លាប់ប្រើតែទង់ប្រាសាទ ទង់ជាតិប្រាសាទកំពូលបីបាទ ជំនាន់នោះ ដូចទង់នោះអ៊ីចឹង។

**ស៖** ខ្ញុំនឹងបញ្ជាក់សំណួរឲ្យបានច្បាស់លោកសាក្សី <ដោយសារ ខ្ញុំគិតថា មានភាពច្របូកច្របល់ហើយ>។ នៅពេលដែលខ្ញុំនិយាយពី "ទង់បដិវត្ត" ខ្ញុំសំដៅទៅទស្សនាវដ្តីខ្មែរក្រហមដែលមាន<ឈ្មោះថា>ទស្សនាវដ្តី<> "ទង់បដិវត្ត" មិនមែនទង់ជាតិទេ។ អ៊ីចឹង ខ្ញុំចង់ដឹងថាតើលោកធ្លាប់<ដឹងថាមានទស្សនាវដ្តីនេះដែរឬទេ? តើលោកបានអាន>ទស្សនាវដ្តីហ្នឹង<ដែរឬ>ទេ? <តើគេនិយាយអំពីអ្វី? តើលោកបានទទួលទស្សនាវដ្តីនោះញឹកញាប់ទេ>?

[១៥:៤៦:៤៣]

**ឆ៖** មិនដែលបានទេកាលជំនាន់នោះគេអត់ដែលចែកទេបាទ បើថ្នាក់លើៗប្រហែលជាមានប៉ុនចំពោះខ្ញុំមិនដែលបានអានទេ។

**ស៖** សំណួរចុងក្រោយពាក់ព័ន្ធទៅនឹងប្រធានបទដែលលោកបានពិភាក្សាកាលពីព្រឹកមិញហើយ<>ពាក់ព័ន្ធនឹងលេខាឃុំ។ កាលពីព្រឹកមិញនេះ លោកឆ្លើយថាខ្លួនលោកផ្ទាល់មានជំនួយការ<ឃុំ

ម្នាក់។ នៅឃុំនីមួយៗដែលលោកបានទៅធ្វើការលោកសុទ្ធតែមានជំនួយការម្នាក់។ លោកប្រាប់ថាលោកត្រូវការជំនួយការម្នាក់ ក៏ដោយសារ>ថាលោកនៅការដ្ឋាន<ជាប់រហូត។ ខ្ញុំចង់ឱ្យលោកជួយពន្យល់បន្តិចថាការងារដែលជំនួយការធ្វើនោះភាគច្រើនគឺព្រាងរបាយការណ៍ដែលមានតួលេខ។ សំណួរខ្ញុំគឺថា> នៅពេលដែលលោកត្រឡប់មកពីការដ្ឋានវិញនៅពេល<ល្ងាច>នោះ <ដូចអ្វីដែលលោកនិយាយ> តើលោកមានពេលអានរបាយការណ៍ហ្នឹង ហើយកែសម្រួល<>មុននឹងបញ្ជូនទៅថ្នាក់លើនោះ<ដែរឬទេ>?

**ឆ៖** ការពិតនោះ របាយការណ៍ដែលស្មៀនបានសរសេរនេះ ខ្ញុំមិនដែលបានអាននិងមើលពិនិត្យពិច័យទេ បើថាត្រឹមត្រូវហើយ ឱ្យគេបញ្ជូនរបាយការណ៍ទៅស្រុកតែម្តង។

**ស៖** អ៊ីចឹង នរណាជាអ្នកផ្ទៀងផ្ទាត់ថារបាយការណ៍នោះ<ប្រាកដជាត្រឹម>ត្រូវ?

**ឆ៖** អ្នកសរសេរគេផ្ទៀងផ្ទាត់ថាគ្រប់គ្រាន់ហើយ។

**ស៖** <តើត្រឹមត្រូវទេបើខ្ញុំនិយាយថាជំនួយការ>មានស្វ័យភាព<ខ្លះដែរ>ក្នុងការធ្វើការងាររបស់ខ្លួននោះ<>?

**ឆ៖** បាទ ពិតជាត្រឹមត្រូវ។

**លោក អាកទ្វរ វែកគែន៖**

លោកប្រធានសូមអរគុណ ខ្ញុំអស់សំណួរហើយ។

[១៥:៤៩:៤៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអរគុណចំពោះលោក នុត នូវ ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សីក្នុងរយៈពេល២ថ្ងៃកន្លះកន្លងមកនេះ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ការផ្តល់សក្ខីកម្មរបស់លោកដល់ទីបញ្ចប់ហើយ ហើយវត្តមានរបស់លោកនៅអ.វ.ត.កនេះ លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ ហើយសូមលោកធ្វើដំណើរប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកអង្គភាពគាំពារសាក្សីនិងអ្នកជំនាញក្នុងការជូនលោក នុត នូវ វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅដែលគាត់មានបំណងចង់ទៅបាន

ហើយ។ ហើយអង្គជំនុំជម្រះក៏អរគុណចំពោះលោក ផារី ដែរដែលមេធាវីប្រឹក្សាសាក្សី ហើយលោកអាចអង្គុយនេះបាន ព្រោះអង្គជំនុំជម្រះមានបំណងចង់សួរបឋមចំពោះសាក្សីបម្រុងនៅរសៀលនេះ។

ហើយលោក នុត នូវ អញ្ជើញទៅចុះ!

ហើយមន្ត្រីរដ្ឋបាលតុលាការ បន្ទាប់មកអញ្ជើញសាក្សីបម្រុងចូលមកកន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១៥:៥៣:១៤]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួរស្តីលោកសាក្សី តើលោកឈ្មោះអី?

**លោក វៀល សន៖**

**ឆ៖** ខ្ញុំឈ្មោះ វៀល សន។

**ស៖** បាទអរគុណ លោក វៀល សន ហើយលោកអាចប្រាប់ដល់អង្គជំនុំជម្រះបានដែរទេថាលោកកើតនៅថ្ងៃឆ្នាំណា?

លោក វៀល សន លោកផ្អាកបន្តិច បន្ទាប់ពីស្តាប់សំណួរ ហើយរកនឹកឆ្លើយតបនឹងសំណួរផងហើយជាការងារសម្រួលដល់ក្បាលមីក្រូហ្វូនហ្នឹងប្រតិបត្តិការ ពីព្រោះនៅទីនេះមានការបកប្រែភាសារហូតដល់បីភាសាឯណោះ។ ហើយការបកប្រែភាសាហ្នឹងទម្រាំតែបកឲ្យចប់ចុងចប់ហ្នឹងគឺត្រូវទាមទារពេលវេលាមួយចំនួនទៀតបន្ទាប់ពីអ្នកនិយាយ និយាយ។ ដូច្នេះសូមលោកបង្អង់បន្តិច ហើយរង់ចាំរហូតដល់ក្បាលមីក្រូហ្វូនឲ្យសញ្ញាភ្លើងក្រហម មានន័យថាក្បាលមីក្រូហ្វូនប្រតិបត្តិការសឹមលោកឆ្លើយតប។ សូមអញ្ជើញបាទ!

[១៥:៥៤:២៤]

**ឆ៖** ខ្ញុំកើតនៅថ្ងៃ៣០ ខែ០១ ឆ្នាំ៣៨។

**ស៖** បាទអរគុណ ឆ្នាំ១៩៣៨ ។ អ៊ីចឹងដែរ -- អ៊ីចឹងពិតមែនទេ?

**ឆ៖** បាទ។

**ស៖** បាទអរគុណ ហើយលោក វៀល សន តើលោកមានទីកន្លែងកំណើតនៅភូមិឃុំស្រុកណា

ដែរ?

**ឆ៖** ខ្ញុំ បាទកើតនៅភូមិធំ ឃុំស្រែរនោង ស្រុកត្រាំកក់ ខេត្តតាកែវ។

**ស៖** បាទ អរគុណ។ ចុះទីលំនៅសព្វថ្ងៃរបស់លោក តើលោករស់នៅទីកន្លែងណា?

**ឆ៖** ទីលំនៅខ្ញុំបាទសព្វថ្ងៃនៅភូមិព្រៃតាឡី ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ។

**ស៖** លោកប្រកបមុខរបរធ្វើអ្វីដែរសព្វថ្ងៃនេះ?

**ឆ៖** បាទមុខរបរសព្វថ្ងៃចាំផ្ទះ។

**ស៖** បាទអរគុណ។ ហើយឪពុកបង្កើតរបស់លោកឈ្មោះអី? ម្ដាយបង្កើតរបស់លោកគាត់ឈ្មោះអី?

**ឆ៖** ឪពុកខ្ញុំបាទ ឈ្មោះ រៀល សុទ្ធ ម្ដាយឈ្មោះ គាវ សយ។

**ស៖** អរគុណ។ ចុះហើយឪពុក -- ប្រពន្ធរបស់លោកគាត់ឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធរបស់ខ្ញុំបាទ ឈ្មោះ យ៉ា យឺន មានកូនប្រាំនាក់ ស្រី១នាក់។

**ស៖** អរគុណ ហើយលោក រៀល សន តើលោកអាចប្រាប់ដល់អង្គជំនុំជម្រះបានដែរឬទេថា នៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ ១៩៧៩ តើរូបលោករស់នៅទីកន្លែងណា? ហើយលោកធ្វើការងារអ្វីដែរ?

**ឆ៖** ខ្ញុំបាទ កាលក្នុងរបបនោះចាប់ពីឆ្នាំ១៩៧៥ មករហូតដល់ ៧៩ ពីដំបូងនៅធ្វើស្រែ នៅផ្ទះនៅក្នុងភូមិទេ ដល់បានយូរបន្តិចប្រហែលជាបីបួនខែ របបហ្នឹងបង្កើតបានបីបួនប្រាំខែ ខ្ញុំបានទៅធ្វើជាជាង១នៅស្រុក១០៥ ស្រុកត្រាំកក់ហ្នឹង ស្រុក១០៥។ ហើយដល់ក្រោយពីធ្វើជាងហ្នឹងមក ធ្វើជាងបាន ១ឆ្នាំជាងក៏គណៈស្រុកគេចាត់តាំងឲ្យមកជា ឲ្យមកធ្វើពេទ្យជាសង្គមកិច្ចនៅពេទ្យស្រុក១០៥ហ្នឹង។ ជាអនុប្រធានពេទ្យស្រុក១០៥។ រហូតដល់ឆ្នាំ៧៩ បានចប់តែម្ដង។

[១៥:៥៨:១១]

**ស៖** បាទ អរគុណលោក រៀល សន។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការថាកាលពីព្រឹកមិញ ថាតាមសមត្ថភាពដែលលោកអាចដឹង គឺថាលោកមិនមានឪពុកម្ដាយ បុព្វញាតិ កូន ឬបច្ឆាញាតិ បងប្អូនប្រុសស្រី បងប្អូនថ្លៃ ប្រពន្ធត្រូវបានទទួលស្គាល់យកជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះទេ។ តើពិតមែនដែរឬទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ ពិតមែន។

**ស៖** អរគុណ ហើយលោកបានស្បថរួចហើយឬនៅ មុននឹងចូលមកកន្លែងផ្តល់សក្ខីកម្មនៅចំពោះអង្គជំនុំជម្រះនាពេលនេះ?

**ឆ៖** ខ្ញុំបាទបានស្បថរួចហើយ។

**ស៖** អរគុណលោករៀល សន ក្នុងនាមលោកជាសាក្សី យើងសូមប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមជាសាក្សីចំពោះមុខអង្គជំនុំជម្រះដូចខាងក្រោមនេះ។

អំពីសិទ្ធិលោក រៀល សន ក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការសុំឱ្យលោកធ្វើអត្ថាធិប្បាយណាមួយឬច្រើនដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ មានន័យថាដោយសារតែចម្លើយឬការសុំឱ្យធ្វើអត្ថាធិប្បាយនោះនាំឱ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។ អំពីករណីយកិច្ច លោក រៀល សន ក្នុងនាមលោកជាសាក្សី ត្រូវផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះនេះ លោកត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក លើកលែងតែសំណួរដែលនាំឱ្យឆ្លើយតបរបស់លោក ឬការអត្ថាធិប្បាយមួយឬច្រើនដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងបានប្រាប់អំពីសិទ្ធិរួចហើយអម្បាញ់មិញនេះ។ ក្នុងនាមលោកជាសាក្សីត្រូវតែឆ្លើយឱ្យការណ៍ណាដែលពិតដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ តើលោកយល់អំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមជាសាក្សីដែរឬទេ?

**ឆ៖** បាទ យល់។

**ស៖** លោក រៀល សន តើលោកធ្លាប់បានផ្តល់សក្ខីកម្ម ឬផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេក្នុងអំឡុងពេលប៉ុន្មានឆ្នាំកន្លងមកនេះ? ហើយប្រសិនបើមាន តើធ្វើប៉ុន្មានដង? ធ្វើនៅទីកន្លែងណាខ្លះ?

[១៦:០១:៣៤]

**ឆ៖** បាទធ្វើពីរដង។ ម្តងនៅសាលាឃុំត្រពាំងធំខាងជើង លើកទី២ ធ្វើនៅសាលាក្តីខ្មែរក្រហមហ្នឹង។

**ស៖** បាទ អរគុណ។ ហើយលោក រៀល សន មុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ តើលោកបានពិនិត្យមើល ឬបានអានទូវកំណត់ហេតុដែលលោកបានផ្តល់សក្ខីកម្មកាលពីពេលមុនជាមួយនឹងអ្នកស៊ើបអង្កេត ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** បាទ បានមើលដែរ។

**ស៖** ហើយតាមសមត្ថភាពដែលលោកអាចដឹង និងចងចាំ តើលោកអាចបញ្ជាក់បានដែរឬទេកំណត់ហេតុស្តាប់ចម្លើយដែលលោកបានអានដើម្បីរំឭកការចងចាំហ្នឹងគឺពិតជាត្រឹមត្រូវ ឬក៏វាស៊ីចង្វាក់ស្របគ្នាទៅនឹងចម្លើយដែលលោកបានធ្វើសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពីរដងលើកមុននោះដែរឬទេ?

**ឆ៖** បាទ ស៊ីចង្វាក់គ្នា ត្រឹមត្រូវ។

**ស៖** បាទ អរគុណលោក រៀល សន។ ឥឡូវហ្នឹង ក៏ពេលសមស្របសម្រាកហើយសម្រាប់ថ្ងៃនេះ។ ដូច្នេះប្រកាស តុលាការប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះហើយសវនាការលើកបន្តធ្វើនៅថ្ងៃស្អែក។ ថ្ងៃស្អែកនេះអង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី រៀល សន ដែលនឹងចាប់ផ្តើមដោយសហព្រះរាជអាជ្ញាមុនភាគីដទៃទៀតនៃរឿងក្តី។ ហើយសវនាការនៅថ្ងៃស្អែកហ្នឹងចាប់ផ្តើមវេលាម៉ោងប្រាំបួនព្រឹក សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

ហើយអង្គជំនុំជម្រះសូមអរគុណចំពោះលោក រៀល សន ហើយឥឡូវនេះដំណើរការស្តាប់សក្ខីកម្មរបស់លោកគឺទើបតែអង្គជំនុំជម្រះបានសួរនូវសំណួរបឋមប៉ុណ្ណោះ។ អ៊ីចឹងសំណួរជាសារវ័ន្តគឺមិនទាន់បានស្តាប់សក្ខីកម្មរបស់លោកនៅឡើយទេ។ អង្គជំនុំជម្រះលើកបន្តទៅធ្វើនៅថ្ងៃស្អែកទៀត ដែលចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ដូច្នេះ អង្គជំនុំជម្រះកោះអញ្ជើញលោកមកចូលរួមផ្តល់សក្ខីកម្ម នៅថ្ងៃស្អែកនេះ នៅទីនេះ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយលោកមេធាវីប្រឹក្សាដូចគ្នា អង្គជំនុំជម្រះអញ្ជើញមកប្រឹក្សាសាក្សីក្នុងពេលសាក្សីនេះផ្តល់សក្ខីកម្ម។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក -- នាំសាក្សី រួមជាមួយនឹងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញជូនគាត់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញចុះ ហើយនិងបង្គាប់ឲ្យនាំគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅថ្ងៃស្អែក នៅវេលាម៉ោងប្រាំបួនព្រឹក ហើយរួមទាំងមេធាវីផង។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅព្រឹកថ្ងៃស្អែកវិញ ឲ្យបានម៉ោងៗ -- មុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៤ នាទី)*